# ថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២៣

## ឯកឧត្តម កើត រិទ្ធ ណែនាំឲ្យមន្ត្រីក្នុងវិស័យយុត្តិធម៌ទាំងអស់ម៉ឺងម៉ាត់ តឹងរ៉ឹងចំពោះ បទល្មើសគ្រឿងញៀន, ជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ, បទល្មើសឆក់ប្លន់និង ក្មេងទំនើង

https://information.gov.kh/articles/117041 *ចេញផ្សាយ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២៣*

*ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ណែនាំឲ្យមន្ត្រីក្នុងវិស័យយុត្តិធម៌ទាំងអស់ម៉ឺងម៉ាត់ តឹងរ៉ឹងចំពោះ បទល្មើសគ្រឿងញៀន, ជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ, បទល្មើសឆក់ប្លន់ និង ក្មេងទំនើង ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ។*

*ការលើកឡើងរបស់ឯកឧត្តមរដ្ឋមន្ត្រី បានធ្វើឡើងនៅរសៀលថ្ងៃចន្ទ ១រោច ខែអស្សុជ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ ក្នុងពិធីប្រកាសផ្ទេរ តែងតាំង និងចូលកាន់មុខតំណែងរបស់ឯកឧត្តម ឌិន ស៊ីវុទ្ធី ជាប្រធានសាលាដំបូងខេត្តស្ទឹងត្រែង ជំនួស ឯកឧត្តម យ៉ា ណារិន ដែលត្រូវបានតែងតាំងជាអនុប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ និងឯកឧត្តម កែវ សុធា ដែលត្រូវបានតែងតាំងជា ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង ជំនួសឯកឧត្តម ជេត ខេមរា ដែលត្រូវបានតែងតាំងជាអគ្គព្រះរាជអាជ្ញារង នៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ។*

*តាមប្រភពព័ត៌មានពីក្រសួងយុត្តិធម៌ បានឲ្យដឹងថា ឯកឧត្តម កើត រិទ្ធ បានណែនាំ និងផ្តាំផ្ញើ ដល់ ឯកឧត្តមប្រធានសាលាដំបូង និងឯកឧត្តមព្រះរាជអាជ្ញាថ្មី ព្រមទាំងចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី និងមន្ត្រីក្នុងវិស័យយុត្តិធម៌ទាំងអស់ ដូចខាងក្រោម៖*

*(១)-ត្រូវពង្រឹងប្រសិទ្ធភាពចំណាត់ការសំណុំរឿង ឱ្យបានម៉ឺងម៉ាត់ តឹងរ៉ឹង ត្រឹមត្រូវ និងតម្លាភាព ជាអាទិ៍ បទល្មើសគ្រឿងញៀន, ជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ, បទល្មើសឆក់ប្លន់, ក្មេងទំនើង ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ។*

*(២)-នៅពេលជំនុំជម្រះក្តី ចៅក្រមត្រូវរក្សាភាពមិនលំអៀង ដោយវៀរចាកអគតិទាំង ៤ ប្រការគឺ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ និងត្រូវប្រកាន់យកសុគតិធម៌ទាំង ៥ គឺ វិរិយសម្បយុត្តិ សុចរិតយុត្តិធម៌ បញ្ញត្តិគារវៅ សមទណ្ឌោ និង បញ្ញាវុធវិនិច្ឆ័យ។*

*(៣)-ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីក្រោមឱវាទ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ តាមគ្រប់មធ្យោបាយ, រៀបចំសមាសភាពមន្ត្រីដើម្បីទទួលការបណ្តុះបណ្តាលបន្ត ហើយមន្ត្រីគ្រប់រូបក្នុងវិស័យយុត្តិធម៌ ក៏ត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនជាប់ជាប្រចាំ។*

*(៤)-ត្រូវពង្រឹងគុណភាពនៃការតាក់តែងសាលក្រម/សាលដីកា ឱ្យបានត្រឹមត្រូវតាមក្បួនខ្នាត, ត្រូវមានសំអាងហេតុ និងសំអាងច្បាប់ជាមូលដ្ឋានរឹងមាំ ងាយយល់ ច្បាស់លាស់ គ្រប់គ្រាន់ ត្រឹមត្រូវ*

និងយុត្តិធម៌ ជាសាលក្រម/សាលដីកាគំរូ ស្របតាមច្បាប់ និងនីតិវិធីជាធរមាន ហើយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ក៏ស្នើសុំឱ្យមន្ត្រីអនុវត្តច្បាប់ដែលមានការពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច សូមមេត្តាផ្តល់កិច្ចសហការពេញលេញ ជានាឱ្យសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តពេញលេញ និងប្រកបដោយប្រសិទ្ធភាពដើម្បីរួមចំណែកក្នុងការពង្រឹងគោលការណ៍នីតិរដ្ឋនៅកម្ពុជា។

(៥)-ត្រូវប្រកាន់ភ្ជាប់នូវអភិក្រមដ៏ថ្លៃថ្លាទាំង ៥ របស់ សម្តេចតេជោ ហ៊ុន សែន គឺ"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់" និងអភិក្រមទាក់ទងនឹងការកែទម្រង់ទាំង ៤ របស់ សម្តេចធិបតីនាយករដ្ឋមន្ត្រី គឺ "ត្រូវមានចក្ខុវិស័យច្បាស់លាស់ មានការប្តេជ្ញាចិត្តខ្ពស់ មានការចូលរួមដោយស្មោះត្រង់ និងការលះបង់" ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ជាពិសេស ការត្រៀមលក្ខណៈគ្រប់បែបយ៉ាង និងការបង្ហាញនូវភាពជាអ្នកដឹកនាំ ដើម្បីចូលរួមអនុវត្តយុទ្ធនាការសំខាន់ៗទាំង ៣ ដែលនឹងដាក់ចេញដោយក្រសួងយុត្តិធម៌នាពេលខាងមុខ។

ឯកឧត្តម កើត រិទ្ធ បានបញ្ជាក់ថា ផ្អែកតាមមការប្រគល់ភារកិច្ចរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ប្រមុខរាជរដ្ឋាភិបាល, ក្រសួងយុត្តិធម៌ បាននិងកំពុងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តវិធានការគន្លឹះទី៥ សំដៅពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ដើម្បីសម្រេចឱ្យបានចេញជាលទ្ធផលនៅក្នុងនីតិកាលទី ៧ នៃរដ្ឋសភា នូវកិច្ចការអាទិភាព គឺ

(ទី១)-ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីជួយសម្រុះសម្រួលដោះស្រាយវិវាទឱ្យបានឆាប់រហ័ស ជាពិសេសវិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន, (ទី២)-ការជំរុញ និងពន្លឿនការដោះស្រាយសំណុំរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័សនិង (ទី៣)-ការត្រួតពិនិត្យ និងការដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ សំដៅជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជា ការលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវ ក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។ ឆ្លើយតបនឹងការផ្តល់ទំនុកចិត្តដ៏ខ្ពង់ខ្ពស់របស់សម្តេចធិបតីនាយករដ្ឋមន្ត្រី, ក្រសួងយុត្តិធម៌បានរៀបចំផែនការសកម្មភាពសម្រាប់យុទ្ធនាការសំខាន់ៗចំនួន ៣ ដែលត្រូវបានចាត់ទុកជាបទបញ្ជា និងទិសដៅការងារដ៏មុតស្រួចដែលត្រូវអនុវត្ត គឺ៖

(ទី១)-យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ, (ទី២)-យុទ្ធនាការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង(ទី៣)-យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ។ ជារួម យុទ្ធនាការដ៏មានសារៈសំខាន់ទាំង ៣ នេះមានសសរស្តម្ភ ចំនួន ២ គឺ សសរស្តម្ភទី១-ការកែទម្រង់លើការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ និង

សសរស្តម្ភទី២-ការកែទម្រង់លើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលសសរស្តម្ភទាំងពីរនេះមាននៅក្នុងច្បាប់ ហើយស្របច្បាប់៕ ដោយៈ កន ចំណាន

## ប្រទេសថៃបានបញ្ចុះតម្លៃសេវាផ្សេងៗសម្រាប់ពលករចំណាកស្រុកខ្មែរ

https://www.khmertimeskh.com/501384319// October 31, 2023

ក្រសួងការងាររបស់ប្រទេសថៃ បានចេញប្រកាស ស្តីពីការកំណត់តម្លៃសេវាអធិការកិច្ច និងលិខិតអនុញ្ញាតការងារថ្មីសម្រាប់ពលករមកពីកម្ពុជា។ តម្លៃសេវាផ្សេងៗ ត្រូវបានកាត់បន្ថយ ដើម្បីលើកកម្ពស់ការងារស្របច្បាប់ និងដោះស្រាយបញ្ហាពលករបរទេស ដែលចូលមកក្នុងប្រទេសថៃ។ ជាពិសេសតម្លៃទិដ្ឋាការត្រូវបានកាត់បន្ថយពី ២,០០០ បាតទៅ ៥០០បាត ហើយតម្លៃសម្រាប់ការដាក់ពាក្យសុំស្នាក់នៅបណ្តោះអាសន្នត្រូវបានកាត់បន្ថយពី ១,៩០០ បាតទៅ ៥០០បាត។

ប្រកាសរបស់ក្រសួងចូលជាធរមាននៅថ្ងៃទី១០ ខែវិច្ឆិកា ឬ ១៥ថ្ងៃ បន្ទាប់ពីការបោះពុម្ពផ្សាយក្នុងព្រះរាជក្រឹត្យ ចុះថ្ងៃទី២៧ ខែតុលា។ ប្រកាសនេះមានប្រសិទ្ធភាពរយៈពេលបួនឆ្នាំ និងត្រូវបានអនុវត្តចំពោះពលករបរទេសមកពីកម្ពុជា មីយ៉ាន់ម៉ា វៀតណាម និងឡាវ ដែលចូលប្រទេសថៃ ដើម្បីធ្វើការដោយផ្អែកលើកិច្ចសន្យាការងារ ឬអនុស្សរណៈ នៃការយោគយល់គ្នា (MOU) ទាក់ទងនឹងការជ្រើសរើសពលករ។ វិធានការនេះមានគោលបំណងធានាថា ពលករបរទេសមានការងារស្របច្បាប់ និងរួមចំណែកដល់សេដ្ឋកិច្ចរបស់ប្រទេសថៃ ដោយចូលរួមដោះស្រាយបញ្ហាពាក់ព័ន្ធនឹងអន្តោប្រវេសន៍ខុសច្បាប់ និងស្ថិរភាពទីផ្សារការងារ។

«ប្រកាសនេះ គឺស្របតាមវិធីសាស្ត្ររបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងការងាររបស់ពលករបរទេស ដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ប្រទេស និងគាំទ្រដល់ការស្តារឡើងវិញនៃសេដ្ឋកិច្ចបន្ទាប់ពីរងផលប៉ះពាល់ដោយសារជំងឺCOVID-19។ ការកាត់បន្ថយថ្លៃសេវាគឺជាមធ្យោបាយមួយដើម្បីសម្រាលបន្ទុកហិរញ្ញវត្ថុរបស់កម្មករ និងនិយោជក»។

យោងតាមព័ត៌មានរបស់នាយកដ្ឋានរដ្ឋបាលការងារបរទេសបានឱ្យដឹងថា ក្នុងខែកញ្ញា ប្រទេសថៃ មានពលករបរទេសសរុបចំនួន ២.៥៩៣.៤៣៩ នាក់ ហើយនៅមានពលករប្រមាណ ១លាននាក់ទៀតកំពុងស្នើសុំប័ណ្ណការងារ ដោយយោងតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣។ Khaosod English

# ថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ២០២៣

## ក្រសួងការងារ និងIOM
## នឹងបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការគាំពារពលករទេសន្តរប្រវេសន៍

https://www.kampucheathmey.com/local-news/606431 ថ្ងៃសុក្រ ៣ វិច្ឆិកា ២០២៣ Ngoeul Narath

*រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក ហេង សួរ និងលោកស្រី* KRISTIN PARCO *ប្រធានបេសកកម្មអង្គការទេសន្តរប្រវេសន៍អន្តរជាតិ* (IOM)*ប្រចាំនៅកម្ពុជា បានឯកភាពគ្នាបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការគាំពារពលករទេសន្តរប្រវេសន៍នៅកម្ពុជា។*

*ក្នុងជំនួបដែលធ្វើឡើងនាថ្ងៃរសៀល ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ភាគីទាំងពីរ បានលើកឡើងពីវឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការសំខាន់ៗ ដែលអង្គការ* IOM *បានគាំទ្រទាំងកម្រិតកម្ពុជា និងកម្រិតតំបន់ទន្លេមេគង្គដើម្បីធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌ និងសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍។ ក្នុងនោះ រដ្ឋមន្ត្រីក្រសួងការងារ បានថ្លែងអំណរគុណដល់អង្គការ* IOM *ដែលគាំទ្រដល់កម្ពុជាលើគម្រោង* PROMISE *ក៏ដូចជាគម្រោងផ្សេងៗទៀត ដើម្បីឱ្យពលករទេសន្តរប្រវេសន៍កម្ពុជាទទួលបានលក្ខខណ្ឌការងារល្អ មានការគោរពសិទ្ធិនិងការពង្រឹងសមត្ថភាពជំនាញជាដើម។*

*បន្ថែមពីនេះ លោក ហេង សួរ បានបង្ហាញទស្សនៈវិស័យរបស់ក្រសួងក្នុងអាណត្តិទី៧ក្នុងនាមជាសេនាធិការឱ្យរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ដែលបានចង្អុលបង្ហាញឱ្យមានការយកចិត្តទុកដាក់ខ្ពស់ លើការបណ្តុះបណ្តាលជំនាញដល់យុវជន និងកម្លាំងពលកម្មក្នុងទីផ្សារដែលមានស្រាប់ ក៏ដូចជាការពង្រីកនូវការថែទាំសុខភាពតាមរយៈរបបភាគទានស្ម័គ្រចិត្តសម្រាប់បុគ្គលស្វ័យនិយោជន៍ និងសមាជិកក្នុងបន្ទុករបស់កម្មករនិយោជិតដែលជាយុទ្ធសាស្ត្រពង្រឹងសុខុមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយការចំណាយ។*

*ប្រធានបេសកកម្មអង្គការទេសន្តរប្រវេសន៍អន្តរជាតិ* (IOM) *បានគាំទ្រ លើកសរសើរ និងវាយតម្លៃខ្ពស់ចំពោះគោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលលោកស្រីថា បានគិតគូពីផលប្រយោជន៍ពលរដ្ឋ៕*

# ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចូលរួមលើកកម្ពស់សមភាពយេនឌ័រ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការទប់ស្កាត់អំពើហឹង្សាលើស្ត្រី និងកុមារតាមប្រព័ន្ធអនឡាញ នៅខេត្តព្រះវិហារ

https://freshnewsasia.com/index.php/en/localnews/316420-2023-11-02-12-08-04.html 2023-11-02 07:08pm

(ព្រះវិហារ)៖ នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគារ លី ហួត ខេត្តព្រះវិហារ លោកស្រី ប្រាក់ ច័ន្ទណយ រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាស្តីពី «ការលើកកម្ពស់សមភាពយេនឌ័រ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការទប់ស្កាត់អំពើហឹង្សាលើស្ត្រីនិងកុមារតាមប្រព័ន្ធអនឡាញ»។

ពិធីមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង លោកស្រី ប៉ាង រ៉ាវី អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ ប្រធានមន្ទីរកិច្ចការនារីខេត្តព្រះវិហារ លោក លោកស្រី មន្ត្រីរាជការនៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តចំនួន៧ រួមមាន ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តប៉ៃលិន ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តកណ្ដាល ព្រមទាំងសាខាប្រតិបត្តិករផ្តល់សេវាប្រៃសណីយ៍ និងសាខាប្រតិបត្តិករផ្តល់សេវាអុីនធឺណិត សរុបប្រមាណ ៩០រូប។

សិក្ខាសាលានេះមានគោលបំណងចែករំលែកចំណេះដឹងជូនសិក្ខាកាម ជាមន្ត្រីរាជការមកពីមន្ទីរ ប.ទ.ខេត្ត អង្គភាពពាក់ព័ន្ធក្នុងការចូលរួមលើកកម្ពស់សមភាពយេនឌ័រ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការទប់ស្កាត់អំពើហឹង្សាលើស្ត្រី និងកុមារតាមប្រព័ន្ធអនឡាញ ដោយផ្តោតលើប្រធានបទ៖

ការផ្សព្វផ្សាយអនុសាសន៍១២ ចំណុច របស់ សម្តេចអគ្គមហាសេនាធីបតីតេជោ ហ៊ុន សែន និងអនុសាសន៍ ៦ចំណុចរបស់ សម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងការងារលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ, ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, ស្ត្រីក្នុងភាពជាអ្នកដឹកនាំ, ការទប់ស្កាត់អំពើហឹង្សាលើស្ត្រី និងកុមារតាមប្រព័ន្ធអនឡាញ, និងការជំរុញសកម្មភាពស្ត្រីក្នុងការចាប់យកជំនាញឌីជីថល។

នៅក្នុងឱកាសនោះ លោកស្រីរដ្ឋលេខាធិការ ប្រាក់ ច័ន្ទណយ បានមានប្រសាសន៍ថា ការផ្តល់ឱកាសនិងការជំរុញភាពអង់អាចដល់ស្ត្រី គឺជាយន្តការសំខាន់ក្នុងការកាត់បន្ថយវិសមភាពយេនឌ័រ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់គុណភាពជីវិត និងឈានទៅសម្រេចឱ្យបានចំណាត់ថ្នាក់ ជាប្រទេសមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។

ស្របជាមួយគ្នានេះ លោកស្រីរដ្ឋលេខាធិការ បានសំណូមពរដល់ថ្នាក់ដឹកនាំទាំងអស់បន្តយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីធ្វើឱ្យប្រសើរឡើង នូវ សិទ្ធិ ឋានៈ តួនាទី និងជីវភាពរស់នៅរបស់មន្ត្រីរាជការនារី នៅក្នុងអង្គភាពរបស់ខ្លួនតាមរយៈ៖ ១).បន្តលើកកម្ពស់សមធម៌យេនឌ័រ ជំរុញភាពអង់អាចរបស់ស្ត្រីក្នុងសេដ្ឋកិច្ច ក្នុងការបណ្តុះបណ្តាលបំពាក់បំប៉នជំនាញបច្ចេកទេស ដើម្បីបង្កើនសមត្ថភាពរបស់ស្ត្រីក្នុងការផ្តល់ឱកាសដល់ស្ត្រីឱ្យទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេសថ្មីៗបន្ថែមទៀត និង ២).បន្តបង្កើនសមាមាត្រការចូលរួមរបស់ស្ត្រីឱ្យបានកាន់តែច្រើនឡើង តាមរយៈការលើកកម្ពស់សិទ្ធិ និងឋានៈ របស់ស្ត្រី ក្នុងគ្រប់ថ្នាក់ ដើម្បីឱ្យស្ត្រីបានចូលរួមកាន់តែសកម្មក្នុងការធ្វើសេចក្តីសម្រេចនានា។

ឆ្លៀតឱកាសនេះ លោកស្រីរដ្ឋលេខាធិការ បានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំក្រសួងដែលតែងតែឧបត្ថម្ភគាំទ្រក្នុងការលើកកម្ពស់សមភាពយេនឌ័រ ហើយលោកជំទាវក៏បានថ្លែងអំណរគុណដល់វាគ្មិនដែលបានចំណាយពេលក្នុងការចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ថ្មីៗជូនសិក្ខាកាម និងមានសង្ឃឹមថា សិក្ខាកាមទាំងអស់ នឹងបានយល់ដឹងបន្ថែមនូវចំណុចសំខាន់ៗក្នុងការលើកកម្ពស់សមភាពយេនឌ័រ ព្រមទាំងបន្តផ្សព្វផ្សាយនៅតាមអង្គភាពរៀងៗខ្លួន ដើម្បីចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិយើងអោយកាន់តែរីកចម្រើនថែមទៀត៕

# ថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ២០២៣

## ស្ថាប័នពាក់ព័ន្ធនានា

## កំពុងធ្វើការលើផែនការជាតិ ដើម្បីអនុវត្តកតិកាសញ្ញាពិភពលោកទេសន្តរប្រវេសន៍

https://www.postkhmer.com/national/2023-11-03-1014-255726.html ដោយ សុខនី। Publication date 03 November 2023 | 10:14 ICT

ភ្នំពេញៈ ក្រសួងពាក់ព័ន្ធ និងស្ថាប័នអន្តរជាតិ កំពុងពិនិត្យ និងសម្រេចផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដើម្បីធ្វើយ៉ាងណាឱ្យទេសន្តរប្រវេសន៍ទាំងក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងទៀត មិនរងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។

មុននឹងអនុវត្តផែនការជាតិនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស (គ.ជ.ប.ជ.) កាលពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០២៣ បានបើកកិច្ចប្រជុំបច្ចេកទេសថ្នាក់ជាតិ ស្តីពីការពិ

និត្យ និងសម្រេចផែនការជាតិសម្រាប់ការអនុវត្តកតិកាសញ្ញាពិភពលោកដែលមានការចូលរួមពីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ក្រសួង ស្ថាប័ន អង្គការដៃគូជាតិ និងអន្តរជាតិផងដែរ។

លោកស្រី ជួ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ. បានថ្លែងប្រាប់នៅថ្ងៃទី ២ ខែវិច្ឆិកានេះថា នៅក្នុងកិច្ចប្រជុំបច្ចេកទេសថ្នាក់ជាតិនេះមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន ដើម្បីធ្វើការត្រួតពិនិត្យ ព្រោះកម្ពុជា ជាប្រទេសហត្ថលេខី ១ នៅក្នុងចំណោមប្រទេស ១៨៣ នៅលើពិភពលោកដែលចូលជាសមាជិកនៃកតិកាសញ្ញាពិភពលោកនេះ។ លោកស្រីបន្តថា ដូច្នេះដើម្បីអាចអនុវត្តកតិកាសញ្ញាពិភពលោកនេះបាន គឺត្រូវរៀបចំផែនការជាតិសំខាន់ៗក្នុងនោះរួមមាន ទី១- ប្រមូល និងប្រើប្រាស់ជាមូលដ្ឋាននូវទិន្នន័យដែលសុក្រឹតសម្រាប់គោលនយោបាយផ្អែកលើភស្តុតាង។ ទី២- គ្រប់គ្រងព្រំដែនរួមគ្នា ដោយសុវត្ថិភាព និងស៊ីចង្វាក់គ្នា និងទី៣- ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូសកលស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។ លោកស្រីបញ្ជាក់ថា៖ «ការអនុវត្តកតិកាសញ្ញាពិភពលោកហ្នឹង គឺវាមានសារៈសំខាន់ណាស់សម្រាប់ឱ្យយើងជួយគ្នា រៀនសូត្រពីគ្នាទៅវិញទៅមក ដើម្បីធ្វើយ៉ាងណាឱ្យទេសន្តរប្រវេសន៍ទាំងប្រទេសយើង និងប្រទេសគេ ប្រកបដោយសុវត្ថិភាព»។លោកស្រី ជួ ប៊ុនអេង ថ្លែងថា នៅក្នុងឆ្នាំ ២០២៤ កម្ពុជានឹងបង្ហាញលទ្ធផលមួយចំនួនដែលខ្លួនអាចធ្វើបាននៅក្នុងគោលបំណងផែនការជាតិសម្រាប់អនុវត្តកតិកាសញ្ញាពិភពលោកនេះ។

លោក មឿន តុលា ប្រធានអង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា អង្គការសង់ត្រាល់ បានថ្លែងថា បទដ្ឋានគតិយុត្តិអន្តរជាតិនេះ ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស គឺវាជាកាតព្វកិច្ចរបស់រដ្ឋ ពីព្រោះនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ក៏ដូចជារដ្ឋធម្មនុញ្ញនៅឆ្នាំ ១៩៩៣ កម្ពុជាបានប្រកាសផ្តល់សច្ចាប័ន និងដាក់ជាកាតព្វកិច្ចទទួលគោរពសិទ្ធិមនុស្សជាសកលដែលមានចែងនៅក្នុងអង្គការសហប្រជាជាតិ។ ដូច្នេះសិទ្ធិពលករចំណាកស្រុក ឬក៏ទេសន្តរប្រវេសន៍នេះ វាជាផ្នែកមួយនៃសិទ្ធិមនុស្សជាសកលផងដែរ ខណៈដែលកម្ពុជា ជាប្រទេសបញ្ជូនពលករទៅធ្វើការនៅប្រទេសក្រៅមានដូចជា ប្រទេសថៃ កូរ៉េ ជប៉ុន និងម៉ាឡេស៊ីជាដើម។

លោកបានឱ្យដឹងទៀតថា ក្រៅពីនេះកម្ពុជាក៏ជាប្រទេសទទួលពលករ ឬទេសន្តរប្រវេសន៍មកធ្វើការក្នុងប្រទេសខ្លួនដែរ ហើយកន្លងមកកម្ពុជា ធ្លាប់ទទួលពលករពីប្រទេសមីយ៉ាន់ម៉ា ចិន និងបង់ក្លាដែស ដើម្បីបំពេញការងារក្នុងវិស័យសំណង់ ហេតុនេះវាជារឿងមួយចាំបាច់ដែលកម្ពុជាត្រូវអនុវត្តកតិកាសញ្ញាពិភពលោកនេះ សម្រាប់គោរព និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍។ លោក ថ្លែងថា៖ «យើងមើលឃើញពលករយើងដែលទៅធ្វើការនៅថៃ ឬក៏ម៉ាឡេស៊ី តែងតែទទួលរងការកេងប្រវ័ញ្ចកម្លាំងពលកម្មហ្នឹងច្រើន ខណៈដែលកម្ពុជាផ្តោតតែការចុះ MoU លើជំនួញទេ មិន

ដែលចរចាលក្ខខណ្ឌកិច្ចគាំពារលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ឡើយ។ អ៊ីចឹង បើសិនជាយើងអាចអនុវត្តអាហ្នឹងឱ្យបានប្រសិទ្ធភាព មានន័យថា យើងបានកាត់បន្ថយហានិភ័យនៃការកេងប្រវ័ញ្ច»។ លោក មឿន តុលា បន្ថែមថា កាលណាមិនមែនការកេងប្រវ័ញ្ច ឬបញ្ហាទៅលើពលករទេសន្តរប្រវេសន៍ វាក៏ជួយលើកកម្ពស់មុខមាត់កម្ពុជានៅលើឆាកអន្តរជាតិឱ្យបានប្រសើរឡើង ជាពិសេសវាក៏កសាងទំនុកចិត្តទៅដល់ទាំងប្រទេសទទួល ហើយប្រទេសដែលបញ្ជូនផងដែរ៕

## មន្ត្រីព្រំដែន ជួយសង្គ្រោះជនជាតិវៀតណាម២នាក់ ពីការជួញដូរមនុស្សនៅកម្ពុជា

https://www.khmertimeskh.com/501387083//?p=1387083 November 5, 2023

មន្ត្រីច្រកទ្វារព្រំដែនក្នុងខេត្តគៀនយ៉ាង (Kien Giang) ជាប់ទន្លេមេគង្គ បានជួយសង្គ្រោះពលរដ្ឋវៀតណាមពីរនាក់ពីកាស៊ីណូមួយក្នុងប្រទេសកម្ពុជាកាលពីថ្ងៃសុក្រ បន្ទាប់ពីពួកគេត្រូវបានលក់ទៅប្រទេសជិតខាងឱ្យធ្វើការដោយបង្ខំ។ នៅថ្ងៃដដែល អាជ្ញាធរវៀតណាមបានបញ្ចប់នីតិវិធីពាក់ព័ន្ធទាំងអស់ ដើម្បីទទួលយកជនរងគ្រោះទាំងពីរនាក់នោះពីក្រុមឆបោកនៃការជួញដូរមនុស្ស។ ពួកគេត្រូវបានគេស្គាល់ថាឈ្មោះ Hoang Dinh Thuong អាយុ២៥ឆ្នាំរស់នៅខេត្តYen Bai និង ឈ្មោះ Nguyen Manh Tuan អាយុ ២០ឆ្នាំមានដើមកំណើតនៅទីក្រុងហាណូយ។ Hoang Dinh Doi បងប្រុសរបស់ Thuong បានស្នើសុំអោយមន្ត្រីច្រកទ្វារព្រំដែនក្នុងខេត្តជួយរំដោះប្អូនរបស់គាត់ចេញពីកាស៊ីណូមួយក្នុងប្រទេសកម្ពុជា។

Doi បានរៀបរាប់ថា អ្នកស្គាល់គ្នារបស់ Thuong នៅលើបណ្ដាញសង្គមឈ្មោះLoc Thai Son បានណែនាំគាត់ឱ្យមកប្រទេសកម្ពុជាដើម្បីធ្វើការ។ ពីរខែបន្ទាប់ពីចាកចេញពីផ្ទះមកប្រទេសកម្ពុជា Thuongបានទូរស័ព្ទទៅបងប្រុសរបស់គាត់កាលពីថ្ងៃសុក្រសប្តាហ៍មុន ដើម្បីប្រាប់ Doiថាគាត់ត្រូវបានគេបោកប្រាស់ ហើយអ្នកជួញដូរការងារបានទាមទារប្រាក់លោះខ្លួនចំនួន៦០ លានដុង (២៤៤០ ដុល្លារអាមេរិក) ។

ដោយទទួលបានដំណឹងពីឧបទ្ទវហេតុនេះ មន្ត្រីនៅច្រកទ្វារព្រំដែនអន្តរជាតិ Ha Tien បានសហការជាមួយភ្នាក់ងារកម្ពុជាយ៉ាងរហ័ស ដើម្បីស៊ើបអង្កេតលើក្រុមជួញដូរការងារ។ លទ្ធផលស៊ើបអង្កេតបានបង្ហាញថា Thuong ត្រូវបានគេបង្ខាំងទុកនៅកាស៊ីណូKhnhomចម្ងាយពីរគីឡូម៉ែត្រពីច្រកទ្វារព្រំដែន។ បន្ទាប់មកគាត់ និងដៃគូរបស់គាត់ឈ្មោះ Tuan ត្រូវបានជួយសង្គ្រោះចេញពីកន្លែងនោះ។ Tuoi Tre

# អភិបាលខេត្ត យកចិត្តទុកដាក់ចំពោះភ្ញៀវទេសចរ និងពលករឆ្លងដែនច្រកអន្តរជាតិព្រំ

https://kohsantepheapdaily.com.kh/article/1829420.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ប៉ៃលិន០៩ ខែ វិច្ឆិកា ឆ្នាំ ២០២៣ ម៉ោង ១៩:២៨

ខេត្តប៉ៃលិន ៖ រហូតដល់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ ច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន ស្ថិតនៅក្នុងភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ជាប់នឹងច្រកបានផាកាត ស្ថិតក្នុងភូមិបានផាកាត ឃុំខ្ទង់យៃ ស្រុកពោងណាំរ៉ន ខេត្តចាន់បុរី ព្រះរាជាណាចក្រថៃ ហើយបានក្លាយជាច្រកអន្តរជាតិផ្លូវការ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៣ ក្នុងចំណោមច្រកអន្តរជាតិជាច្រើនរបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានភ្ញៀវទេសចរ ពលករ និងការដឹកជញ្ជូនទំនិញចេញ-ចូលឆ្លងកាត់ព្រំដែនយ៉ាងសកម្ម ព្រមទាំងមានកិច្ចសហប្រតិបត្តិការល្អ រវាងមន្ត្រីជួរមុខទាំងទ្វេភាគីកម្ពុជា និង ថៃ ផងដែរ ។

លោកជំទាវបណ្ឌិត បាន ស្រីមុំ អភិបាល នៃគណៈអភិបាលខេត្តប៉ៃលិន បានយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធនានា សម្រាប់មន្ត្រីជំនាញ និងសមត្ថកិច្ច ផ្តល់សេវាបានយ៉ាងឆាប់រហ័ស និងងាយស្រួលជូនដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ ប្រជាពលរដ្ឋ អាជីវករ ពលករ និងការដឹកទំនិញឆ្លងកាត់ព្រំដែន ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងលើកកម្ពស់សោភ័ណភាពព្រមទាំងសណ្តាប់ធ្នាប់ នៅមាត់ច្រកទ្វារព្រំដែនអន្តរជាតិ ដែលជាមុខមាត់របស់ប្រទេសជាតិ ។ ក្រោមការទទួលខុសត្រូវខ្ពស់ចំពោះមុខជាតិ និងប្រជាជន លោកជំទាវបណ្ឌិតអភិបាលខេត្ត តែងតែក្រើនរំលឹកដល់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់ ដែលកំពុងបំពេញការងារនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំ ត្រូវខិតខំអនុវត្តតួនាទី ភារៈកិច្ច និងសិទ្ធិរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ ជាពិសេសត្រូវមានកិច្ចសហការល្អជាមួយស្ថាប័ននានា ដែលបានឈរជើងនៅច្រកទ្វារព្រំដែនអន្តរជាតិ ទាំងកម្ពុជា និងថៃ ដើម្បីសម្របសម្រួលនូវភាពងាយស្រួលដល់ប្រជាពលរដ្ឋ និងភ្ញៀវជាតិ-អន្តរជាតិ ឆ្លងកាត់ព្រំដែន និងការធ្វើពាណិជ្ជកម្មទៅវិញទៅមក ។

ដោយអនុវត្តតាមគោលនយោបាយបញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេច មហាបវរធិបតី ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រី លោកជំទាវបណ្ឌិត បាន ស្រីមុំ ក្នុងនាមជាអាជ្ញធរខេត្ត បានរៀបចំក្រុមការងារ និងមន្ត្រីជំនាញប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំ ដើម្បីជួយសម្របសម្រួលសេវាជូនដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិចេញចូល ជាពិសេសបងប្អូនពលករនៅពេលដែលខក ឬយឺតពេលក្នុងការឆ្លងព្រំដែនទៅធ្វើការងារ គឺរដ្ឋបាលខេត្ត បានត្រៀមរៀបចំកន្លែងស្នាក់នៅជូនដោយឥតគិតថ្លៃ។

ដោយឡែកប្រជាពលរដ្ឋជាទេសចរណ៍ ឬបងប្អូនពលករ បើមានបញ្ហាអ្វីកើតឡើង ឬក្នុងករណីបន្ទាន់ណាមួយ ហើយត្រូវការក្រុមការងារជួយសង្គ្រោះ និងជួយសម្របសម្រួល ដូចជា ៖ ករណីអ្នកជំងឺត្រូវការសង្គ្រោះបន្ទាន់, ករណីពលរដ្ឋខ្មែរ និងបងប្អូនពលករ មានគ្រោះថ្នាក់ ឬ ជួបបញ្ហាណាមួយ សូមទំនាក់ទំនងមកកាន់ក្រុមការងារប្រចាំការរបស់រដ្ឋបាលខេត្ត២៤ម៉ោង/២៤ម៉ោង តាមរយៈលេខទូរស័ព្ទ ៖ 071 9 621 610 ដើម្បីក្រុមការងារធ្វើការជួយសង្គ្រោះ និងជួយសម្របសម្រួលផ្តល់សេវាជូនបងប្អូនប្រជាពលរដ្ឋគ្រប់រូបបានទាន់ពេលវេលា៕

## ចិន ១០នាក់អាចប្រឈមជាប់គុក ២០ឆ្នាំ រឿងផលិតវីដេអូអាសអាភាសនិងអំពើហិង្សាផ្លូវភេទ

https://www.rfa.org/khmer/news/social-economy/of-the-10-chinese-some-could-face-up-to-20-years-in-prison-for-making-pornographic-videos-and-sexual-violence-11032023021911.html

ដោយ ជាតិ ចំណាន 2023.11.03

ក្នុងចំណោមជនជាប់ចោទជនជាតិចិនចំនួន ១០នាក់ ពួកគេមួយចំនួន អាចប្រឈមការកាត់ទោសពីតុលាការឱ្យជាប់ពន្ធនាគារ ២០ឆ្នាំ ក្រោយពីចៅក្រមសាលាដំបូងរាជធានីភ្នំពេញរកឃើញថា ពួកគេបានផលិតវីដេអូអាសអាភាស និងធ្វើទារុណកម្មលើអ្នកធ្វើពេស្យា។

ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ លោក លិ សុខា កាលពីរសៀលថ្ងៃទី៣១ ខែតុលា បានចេញដីកាបង្គាប់ឱ្យសមត្ថកិច្ចឃុំខ្លួនជនជាប់ចោទជនជាតិចិន ១០នាក់នៅពន្ធនាគារព្រៃស ក្រោយពីតំណាងអយ្យការសម្រេចចោទប្រកាន់ពួកគេពីបទស្ថានទម្ងន់ទោសនៃសញ្ចារកម្ម សញ្ចារកម្មដោយមានអំពើហិង្សា និងការដឹកនាំពេស្យាចារ ដែលស្របតាមមាត្រា ២៧ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រា២៩ ស្តីពីសញ្ចារកម្មដោយមានការធ្វើទារុណកម្មកំណត់ថា សញ្ចារកម្ម ឬមេពេស្យា បានធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើឃោរឃៅចំពោះបុគ្គលដែលធ្វើជាពេស្យា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ២០ឆ្នាំ។

កម្លាំងអគ្គស្នងការដ្ឋាននគរបាលជាតិ កាលពីយប់ថ្ងៃទី២៤ ខែតុលា ចុះឆ្មក់បង្ក្រាបទីតាំងផលិតវីដេអូអាសអាភាសមួយកន្លែងនៅអគារក្រុមហ៊ុនដឹកជញ្ជូនម្ហូបអាហារ វ៉ាយ ណាវ (Wow Now) ក្នុងខណ្ឌបឹងកេងកង រាជធានីភ្នំពេញ និងបានឃាត់ខ្លួនមនុស្ស ៤៥នាក់។ ក្រោយការសាកសួរសមត្ថកិច្ចបានដោះលែងមនុស្ស ៣៥នាក់វិញ កាលពីថ្ងៃទី២៥ ខែតុលា ដោយអះអាងថា ពួកគេពុំមានជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសឡើយ៕

# ថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ២០២៣

## ស្ត្រីខ្មែររងការបោកប្រាស់គេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទនៅចិន «កំពុងកើនឡើង»

https://www.rfa.org/khmer/news/human-rights/ngos-report-the-deception-of-cambodian-women-to-exploit-labor-and-sex-trafficking-in-china-does-not-decrease-11062023103346.html *ដោយ ថា ថៃ2023.11.06*

*អង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាលកត់សំគាល់ឃើញថា រយៈពេល១០ឆ្នាំចុងក្រោយនេះ អំពើបោកបញ្ឆោតមនុស្ស និងស្ត្រីពីកម្ពុជាយកទៅជួញដូរផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងនៅប្រទេសចិន កំពុងកើនឡើង ដោយមិនមានការថយចុះទេ។ ពួកគាត់មើលឃើញថា ការកើនឡើងនេះដោយសារតែមន្ត្រីពុករលួយមួយចំនួនមានជាប់ពាក់ព័ន្ធ និងសកម្មភាពនេះ ព្រមទាំងប្រព័ន្ធតុលាការក៏មានវិធានការយឺតយ៉ាវក្នុងការចាប់ខ្លួនជនល្មើសជាដើម។*

*ក្រុមអង្គការសង្គមស៊ីវិលមួយចំនួន កំពុងតែខិតខំជួយសង្គ្រោះជនរងគ្រោះដោយសារអំពើជួញដូរកម្លាំងពលកម្ម និងជួញដូរផ្លូវភេទ ពីប្រទេសចិនឱ្យត្រឡប់មកមាតុភូមិ ព្រមទាំងធ្វើយុទ្ធនាការតាមមូលដ្ឋាន ដើម្បីផ្សព្វផ្សាយកុំឱ្យប្រជាពលរដ្ឋចាញ់បោក មេខ្យល់ ហើយធ្វើចំណាកស្រុកចេញទៅរកការងារធ្វើ នៅក្រៅប្រទេសដោយប្រថុយប្រថាន។ ការប្រឹងប្រែងរបស់អង្គការសិទ្ធិមនុស្សនេះ ខណៈបច្ចុប្បន្នអំពើបោកបញ្ឆោតមនុស្សពីកម្ពុជាយកទៅជួញដូរកម្លាំងពលកម្មនិងជួញដូរផ្លូវភេទនៅឯប្រទេសចិនកំពុងកើនឡើង។*

*នាយកប្រតិបត្តិអង្គការសង់ត្រាល់* (Central) *លោក មឿន តុលា មានប្រសាសន៍ថា ក្នុងរយៈពេលជាង ១០ឆ្នាំចុងក្រោយនេះ ក្រុមជនខិលខូច ដែលដើរបោកបញ្ឆោតមនុស្ស និងស្ត្រីពីកម្ពុជាយកទៅជួញដូរកម្លាំងពលកម្ម និងទៅរៀបការជាមួយបុរសចិន កំពុងកើតមានយ៉ាងខ្លាំង មិនថយចុះទេ។ លោក មឿន តុលា ឱ្យដឹងទៀតថា ក្នុងរយៈពេលជាង១០ឆ្នាំមកហើយ ដែលអង្គការរបស់លោកតែងតែជួយសង្គ្រោះពលរដ្ឋខ្មែរ និងស្ត្រីពីប្រទេសចិន ឱ្យត្រឡប់មកស្រុកវិញ ដោយយ៉ាងហោចណាស់ ក៏ចំនួនពី៧ទៅ១០នាក់ដែរក្នុង១ឆ្នាំៗ។ បច្ចុប្បន្ននេះមានជនខិលខូចខ្លះតែងតែដើរទៅតាមតំបន់ដាច់ស្រយាលតាមបណ្ដាខេត្តមួយចំនួន ហើយបោកបញ្ឆោតមនុស្ស ដែលពេញកម្លាំងធ្វើការព្រមទាំងស្ត្រីក្មេងៗមានរូបសម្រស់ស្អាតថា ទៅធ្វើការនៅប្រទេសចិន គឺបានប្រាក់ខែថ្ងៃ ២ ទៅ ៣ ពាន់ដុល្លារក្នុងមួយខែ ហើយស្របពេល ដែលមនុស្សជាច្រើនកំពុងតែមានជីវភាពខ្វះខាតចង់បានការងារធ្វើផងនោះ ក៏ត្រូវមេខ្យល់ធ្វើលិខិតឆ្លងដែន និងទិដ្ឋាការ តាមរូបភាព ជាអ្នកទេសចរណ៍ទៅដើរកំសាន្តនៅប្រទេសចិន។ ក៏ប៉ុន្តែពេលទៅដល់ប្រទេសចិន គេក៏ដកលិខិតឆ្លងដែនរបស់គាត់ ហើយខ្លះលក់ទៅឱ្យធ្វើការដោយមិនមានប្រាក់ខែ និងស្ត្រីខ្លះទៀតត្រូវគេបង្ខំឱ្យរៀបការជាមួយបុរស*

ចិន ដែលភាគច្រើនគឺជាមនុស្សមិនសូវគ្រប់លក្ខណៈដើម្បីបង្កើតកូនឱ្យគេ ព្រមទាំងបង្ខំឱ្យបំរើគ្រួសាររបស់គេ និងធ្វើការងារដោយមិនគិតថ្លៃ។

លោក មឿន តុលា៖ «បើតាមជនរងគ្រោះគាត់លើកឡើងថា មានស្ត្រីច្រើនមានបុរសខ្មែរខ្លះដែរប៉ុន្តែស្ត្រីច្រើនជាង ហើយនៅខេត្តក្ងាងចូវ ក៏ច្រើនជាងគេដែរ»។ បើសិនជាស្ត្រី គឺគេយកទៅឱ្យរៀបការជាមួយបុរសជនជាតិចិនដោយបង្ខំ។ ពីព្រោះនៅស្រុកចិនកន្លងមកមានគោលនយោបាយគ្រួសារមួយកូន១ ដូច្នេះចិនមានអតិផរណា នៃចំនួនបុរសច្រើនជាងស្ត្រីធ្វើឱ្យបុរសចិនពិបាករកប្រពន្ធណាស់ដោយសារស្ត្រីតិចជាងអីចឹង ហើយបានជាអ្នកអត់មានកាយសម្បទាគ្រប់គ្រាន់ប្រឹងរកប្រពន្ធពីប្រទេសផ្សេងៗ យកស្ត្រីពីភូមា ពីកម្ពុជា វៀតណាម ឡាវជាដើម។ លោក មឿន តុលា បញ្ជាក់ទៀតថា ភាគច្រើនមេខ្យល់តែងនាំកម្លាំងពលកម្ម និងស្ត្រីយកទៅជួញដូរនៅប្រទេសចិននោះ តាមជើងយន្តហោះ និងផ្លូវគោកតាមច្រករបៀងព្រំដែនឆ្លងកាត់ប្រទេសវៀតណាម។

ជនរងគ្រោះជាស្ត្រីវ័យក្មេងម្នាក់ឈ្មោះ ឱ សុជី អាយុប្រហែល ១៧ឆ្នាំ នៅឃុំប៉ាលហាល នៃស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ រៀបរាប់ថា នាងបាន ចាញ់បោកមេខ្យល់តាំងពីឆ្នាំ២០២១។ ជនរងគ្រោះរូបនេះ ក៏បានថ្លែងប្រាប់បន្ថែមទៀត អំពីការធ្វើទុក្ខបុកម្នេញលើរូបនាងនៅឯប្រទេសចិនតាមបណ្ដាញសង្គម (Facebook) ដោយទទូចសុំឱ្យរដ្ឋាភិបាលខ្មែរជួយរំដោះរូបនាងបានវិលត្រឡប់មកស្រុកកំណើតជួបជុំគ្រួសារវិញ។ យុវតី ឱ សុជី៖ «ខ្ញុំចាញ់បោកមេខ្យល់គេយកមកលក់នៅប្រទេសចិន។ គេវាយដំ ទះទាត់ និងឃុំឃាំងខ្ញុំនៅក្នុងបន្ទប់ ហើយលក់ខ្ញុំពីម្នាក់ទៅម្នាក់ ខ្ញុំមានតែលើកម្រាមដៃ១០ទេ ឱ្យបងប្អូនអ្នកស្រុកខ្មែរជួយយកខ្ញុំទៅផ្ទះផង។ សូមជួយ Share ដើម្បីឱ្យអ្នកជំបានឃើញខ្ញុំនិងជួយខ្ញុំ»។ ប៉ុន្តែគួរឱ្យស្តាយអង្គការសិទ្ធិមនុស្ស និងសង្គមស៊ីវិលជាច្រើនមិនអាចតាមរកនាង ឱ សុជី ឃើញឡើយដោយសារតែក្រុមគ្រួសាររបស់នាងមិនសហការព្រមទាំងផ្លាស់ប្ដូរទីលំនៅចេញបាត់ពីភូមិដែលធ្លាប់រស់នៅ។

មន្ត្រីសមាគមការពារសិទ្ធិមនុស្សអាដហុក (ADHOC) ទទួលបន្ទុកការងារស្ត្រី និងកុមារប្រចាំខេត្តព្រះវិហារអ្នកស្រី ហ៊ូ ម៉ាបូណ្ណី មានប្រសាសន៍ថា សមាគមអាដហុកបានព្យាយាមខ្នះខ្នែងជួយក្មេងស្រី ឱ សុជី នេះក៏ប៉ុន្តែម្ដាយរបស់នាងដែលជាប់ចោទពីបទលក់កូនស្រីរបស់ខ្លួននោះ មិនព្រមសហការជាមួយក្រុមអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្ដល់ព័ត៌មានពីកន្លែងដែលកូនរបស់គាត់ស្នាក់នៅក្នុងប្រទេសចិនទេ។ អ្នកស្រី ហ៊ូ ម៉ាបូណ្ណី៖ «អត់ទាន់ជួយបានមកដល់ទេកូនហ្នឹង ណាមួយយើងព្យាយាមជួបម្ដាយ ដើម្បីឱ្យដឹងថា តើអាដហុកអាចជួយបានយ៉ាងដូចម្ដេច ប៉ុន្តែក្រុមគ្រួសារបែរជាផ្លាស់ទីលំនៅមិនដឹងទៅរស់នៅទីណា? ហើយមេខ្យល់ក្នុងរឿងហ្នឹង ក៏បានចាប់ខ្លួនយកទៅដាក់ពន្ធនាគាររួចហើយដែរ»។

ជនរងគ្រោះជាស្ត្រីខ្មែរម្នាក់ទៀតសុំមិនបញ្ចេញឈ្មោះ រស់នៅស្រុករវៀង ខេត្តព្រះវិហារដែលទើបតែជួយសង្គ្រោះឱ្យវិលត្រឡប់ពីប្រទេសចិនវិញ នាង បានប្រាប់វិទ្យុអាស៊ីសេរីថា មេខ្យល់បានបោកបញ្ឆោតរូបនាងយកទៅស្រុកចិន តាំងតែពីចុងឆ្នាំ២០១៥។ មេខ្យល់បានឱ្យប្រាក់ទៅម្ដាយរបស់នាងចំនួន១ពាន់ដុល្លារអាមេរិក ហើយប្រាប់ថា នាំរូបនាងទៅធ្វើការនៅប្រទេសចិនបានប្រាក់ខែច្រើន។ បន្ទាប់មក មេខ្យល់នាំរូបនាងឆ្លងព្រំដែនតាមប្រទេសវៀតណាម ហើយស្នាក់នៅក្នុងប្រទេសវៀតណាមប្រហែលជាកន្លះខែ។ ពេលស្នាក់នៅក្នុងប្រទេសវៀតណាមនោះនាងបានដឹងថា គេមិនមែននាំរូបនាងទៅធ្វើការនៅប្រទេសចិនទេ គឺយករូបនាងទៅលក់ឱ្យរៀបការជាមួយបុរសចិនម្នាក់ដែលជាប្រភេទមនុស្សមិនសូវគ្រប់ទឹក។

ស្ត្រីដដែលបញ្ជាក់ទៀតថា បើទោះបីជានាងដឹងថា បុរសដែលនាងត្រូវរៀបការជាមួយគឺជាមនុស្សដែលមិនគ្រប់លក្ខណៈក៏ដោយក៏រូបនាងមិនអាចប្រកែកបានទេ ពីព្រោះខ្លាចគេធ្វើបាប។ នាងមិនដឹងថា មេខ្យល់ដែលនាំនាងទៅនោះ គេទទួលបានប្រាក់ចំនួនប៉ុន្មានពីបុរសចិននោះទេ ប៉ុន្តែនាងដឹងត្រឹមតែថា ម្ដាយរបស់នាងទទួលបានប្រាក់តែ១ពាន់(១.០០០)ដុល្លារគត់ មុនពេលគេនាំរូបនាងចេញពីផ្ទះ។ ស្ត្រីរងគ្រោះម្នាក់ខាងលើ៖ «គេធ្វើបាបផ្លូវចិត្តណាស់ គេមិនចាត់ទុកខ្ញុំ ដូចជាប្រពន្ធទេគឺចាត់ទុកដូចជាស្ត្រីកំដរអារម្មណ៍។ និយាយទៅគេចង់បានតែកូន។ គេជេរ គេស្ដី គេស្អប់គេមិនវាយធ្វើបាបទេគ្រាន់តែគេមិនពេញចិត្ត ហើយខ្ញុំរស់នៅជាមួយគេមិនចុះសម្រុង។ ខ្ញុំកើតកូនបាន ១ខែមិនទាន់ទេ គឺគេចង់រួមភេទបង្ខំចង់បានកូនប្រុស ព្រោះអីកូនទី១ របស់ខ្ញុំជាកូនស្រី។ ខ្ញុំពិបាករស់នៅជាមួយដោយសារតែឱ្យបាយ ឱ្យចំណីហូប ប៉ុន្តែលុយមិនឱ្យទេ បញ្ហាមួយទៀតមិនឱ្យខ្ញុំទាក់ទងមកម៉ែពុកនៅស្រុកខ្មែរ សូម្បីតែទូរស័ព្ទក៏មិនឱ្យលេងដែរ»។

អ្នកស្រី ហ៊ួ ម៉ាបូណ្ណី ឱ្យដឹងថា ក្នុងឆ្នាំ២០២៣នេះ សមាគមការពារសិទ្ធិមនុស្ស ADHOC បានជួយសង្គ្រោះប្រជាពលរដ្ឋនៅក្នុងខេត្តព្រះវិហារ ដែលគេជួញដូរទៅប្រទេសចិនឱ្យវិលត្រឡប់មកផ្ទះវិញ បាន៧ករណីហើយ។

អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក លោក ស៊ឹង សែនករុណា មានប្រសាសន៍ថារូបភាពនៃអំពើជួញដូរមនុស្សទៅកាន់ប្រទេសចិនភាគច្រើន គឺចាញ់បោកមេខ្យល់តាមរយៈមិត្តភក្តិ ឬក៏សាច់ញាតិបញ្ចុះបញ្ចូល ឱ្យយល់ព្រមទៅធ្វើការ ដោយសារតែឃើញមនុស្សខ្លះ ដែលគេទៅធ្វើការនៅចិន មានលុយច្រើនជីវិតបែបហ៊ឺហាជាដើម។ រូបភាពខ្លះទៀតគឺរបៀបជារៀបការជាមួយបុរសចិនក៏មាន ប៉ុន្តែពេលដែលចេញពីកម្ពុជាទៅដល់ប្រទេសចិនទើបដឹងខ្លួនថាចាញ់បោកគេ។ លោក ស៊ឹង សែនករុណា៖ «ពេលខ្លះយើងជួយត្រឡប់មកវិញបាន និងពេលខ្លះក៏ពិបាកជួយត្រឡប់មកវិញដែរ ដោយសារតែជនខិលខូចមានល្បិច ក្នុងការលាក់បាំង ក្នុងការទប់ស្កាត់មិនឱ្យពួកគាត់

មានឱកាសវិលត្រឡប់មកវិញអីជាដើម។ យើងមានការព្រួយបារម្ភណាស់ដូច្នេះហើយបានជាខិតខំផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋមានការយល់ដឹង គិតពិចារណាឱ្យបានខ្ពស់មុននឹងធ្វើចំណាកស្រុកចេញទៅក្រៅប្រទេសទៅអីជាដើម»។

បើទោះបីជាយ៉ាងណាវិទ្យុអាស៊ីសេរី មិនអាចសុំការពន្យល់ពីអ្នកនាំពាក្យក្រសួងការបរទេស លោក អាន សុខខឿន និងរដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកប្រឆាំងការជួញដូរស្ត្រី និងការពារអនីតិជន អ្នកស្រី ជូ ប៊ុនអេង បានថាយ៉ាងណានៅឡើយនៅថ្ងៃទី៤ ខែវិច្ឆិកា។

នាយកប្រតិបត្តិអង្គការសង់ត្រាល់លោក មឿន តុលា ឱ្យដឹងថា ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះអំពើបោកបញ្ឆោតនាំមនុស្សទៅជួញដូរកម្លាំងពលកម្ម និងផ្លូវភេទពីកម្ពុជាទៅប្រទេសចិនមិនថយចុះទេ បើទោះបីជាក្រសួងការបរទេសកម្ពុជា និងស្ថានទូតចិនប្រចាំកម្ពុជាធ្លាប់បានពង្រឹងកិច្ចសហប្រតិបត្តិការដោយរឹតត្បិតក្នុងការចេញទិដ្ឋាការឱ្យស្ត្រីខ្មែរទៅលេងនៅចិនមានកំរិតមែន ក៏ប៉ុន្តែការនាំស្ត្រីខ្មែរដោយធ្វើដំណើរតាមយន្តហោះបានថយចុះ ហើយការធ្វើដំណើរតាមផ្លូវគោក នៃច្រករបៀងព្រំដែនកម្ពុជា-វៀតណាមបានកើនឡើង។

បើទោះបីជាអង្គការក្រៅរដ្ឋាភិបាលទទួលស្គាល់ថា សកម្មភាពនាំយកមនុស្សទៅជួញដូរនៅប្រទេសចិន កំពុងកើនឡើងក៏ដោយក៏គេមិនដឹងពីតួលេខច្បាស់លាស់ថា ចំនួនប៉ុន្មាននាក់ ក្នុង ១ឆ្នាំៗនោះទេ។ ប៉ុន្តែផ្អែកតាមរបាយការណ៍របស់អង្គការសហប្រជាជាតិបានប៉ាន់ប្រមាណថាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានពលរដ្ឋកម្ពុជាប្រមាណ ១០ម៉ឺន បានរងគ្រោះដោយសារអំពើជួញដូរមនុស្ស។ ជនរងគ្រោះទាំងនោះ ត្រូវគេនាំយកទៅជួញដូរកម្លាំងពលកម្មនិងផ្លូវភេទនៅប្រទេសចិន និងប្រទេសមួយចំនួនទៀតក្នុងតំបន់ដូចជានៅម៉ាឡេស៊ី និងប្រទេសថៃជាដើម។

គេហទំព័រឈ្មោះម៉ូឌើន ឌីប្លូម៉ាស៊ី (Modern Diplomacy) បានដកស្រង់របាយការណ៍អង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្មមកផ្សាយកាលពីថ្ងៃទី៣ ខែវិច្ឆិកា ថាការជួញដូរមនុស្ស និងពេស្យាចារនៅកម្ពុជា បានកើតមាននៅខេត្តព្រះសីហនុតាំងពីឆ្នាំ២០១៩ នៅតាមកន្លែងលេងល្បែងស៊ីសងស្របច្បាប់ជាច្រើន។ ប្រទេសកម្ពុជាមិនត្រឹមតែជាប្រភពដែលផ្គត់ផ្គង់ពេស្យាចារទៅឱ្យប្រទេសដទៃទៀតក្នុងការជួញដូរផ្លូវភេទប៉ុណ្ណោះទេ កម្ពុជាក៏ជាចំណុចឆ្លងកាត់ របស់ក្រុមជួញដូរមនុស្សមកពីប្រទេសចិន វៀតណាមនិងថៃផងដែរ។

អង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម បានរកឃើញទៀតថា បច្ចុប្បន្ននេះក្រៅពីការនាំស្ត្រីទៅជួញដូរនៅក្រៅប្រទេសគឺស្ត្រីជាច្រើនទៀតត្រូវគេជួញដូរពីតំបន់មួយទៅតំបន់មួយនៅក្នុងប្រទេសកម្ពុជា ដូចជាខេត្តសៀមរាប ក្រុងព្រះសីហនុ និងរាជធានីភ្នំពេញ ក្នុងតម្លៃខ្លួនដែលបុរសបរទេសហ៊ានចំណាយប្រាក់ពី៨០០ ទៅ ៤.០០០ដុល្លារដើម្បីរួមភេទ។

ក្រុមអង្គការក្រៅរដ្ឋាភិបាលយល់ថា បច្ចុប្បន្ននេះ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សចេះតែកើនឡើងគឺដោយសារតែការបង្ក្រាបមិនមានប្រសិទ្ធភាព ពីព្រោះតែមន្ត្រី និងកងកម្លាំងសន្តិសុខរបស់រដ្ឋាភិបាលខ្លះ មានជាប់ពាក់ព័ន្ធនិងឃុបឃិតជាមួយបណ្តាញឧក្រិដ្ឋជន ហើយប្រព័ន្ធតុលាការទៀតសោត ក៏មានអំពើពុករលួយទទួលសំណូកជាថ្នូរនឹងការមិនចោទប្រកាន់ និងផ្តន្ទាទោសទៅលើក្រុមឧក្រិដ្ឋជនទាំងនោះជាដើម។

# ថ្ងៃទី០៨ ខែ វិច្ឆិកា ឆ្នាំ២០២៣

## សម្តេចធិបតី ហ៊ុន ម៉ាណែត ថ្លែងអំណរគុណ វិនិយោគិនចិន ដែលបានជួយពន្យល់និងបំភ្លឺ លុបបំបាត់ការព្រួយបារម្ភ ដែលកើតឡើងដោយសាររឿង «No More Bet»

https://freshnewsasia.com/index.php/en/localnews/316945-2023-11-07-05-17-00.html 2023-11-07 12:17pm

**(ព្រះសីហនុ)៖** សម្តេចមហាបបរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃកម្ពុជា បានថ្លែងអំណរគុណដល់វិនិយោគិនចិន តំបន់សេដ្ឋកិច្ចពិសេសចេដាង ស្ថិតនៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលបានជួយពន្យល់ និងបំភ្លឺ ដើម្បីលុបបំបាត់ការព្រួយបារម្ភ ដែលកើតឡើងដោយសារភាពយន្តចិនមួយនោះរឿង «No More Bet»។

«No More Bet» ភាពយន្តមួយដែលបាន ផ្សព្វផ្សាយ កាលពីប៉ុន្មានខែមុន ដោយមានលក្ខណៈវាយប្រហារដល់សន្តិសុខសុវត្ថិភាព និងការជួញដូរកម្លាំងពលកម្ម នៅប្រទេសមួយចំនួនដូចជាថៃ ភូមា និងកម្ពុជាជាដើម។ ក្រោយភាពយន្តនេះ ត្រូវបានផ្សព្វផ្សាយ តាមបណ្តាញអ៊ីនធឺណិត មានជនបរទេសជាច្រើន បានលើកឡើងពីការព្រួយបារម្ភពីសុវត្ថិភាព បើពួកគេធ្វើដំណើរមកកាន់ប្រទេសទាំងនេះ។

ថ្ងៃក្នុងពិធីជួបសំណេះសំណាល ជាមួយកម្មករជាង ១ម៉ឺន ៥ពាន់នាក់ នៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ សម្តេចធិបតីនាយករដ្ឋមន្ត្រី បានរំលឹកថា អំឡុងទស្សនកិច្ចផ្លូវការលើកទី២ របស់សម្តេចទៅកាន់ទីក្រុងប៉េកាំង កាលពីខែតុលាកន្លងទៅនេះ សម្តេចបានជួបជាមួយនឹង វិនិយោគិនមកពីតំបន់សេដ្ឋកិច្ចពិសេសចេដាង ដែលពួកគាត់បានជួយបកស្រាយពន្យល់ និងបំភ្លឺដល់មតិមហាជនមួយចំនួន នៅប្រទេសចិន ដែលគាត់ព្រួយបារម្ភពីសុវត្ថិភាព ព្រោះមានរឿងចិន «No More Bet» និយាយពី អសុវត្ថិភាពនៅក្រុងព្រះសីហនុ។

សម្តេចធិបតី ហ៊ុន ម៉ាណែត បានដកស្រង់សម្តីរបស់វិនិយោគិនទាំងនោះ ពន្យល់ទៅកាន់មតិសាធារណៈ នៅក្រៅប្រទេសថា «**គាត់ឡើងនិយាយ គាត់ថា ទេ ! គាត់ធ្វើការនៅហ្នឹងរាល់ថ្ងៃ**

បុគ្គលិករបស់គាត់មកពីចិនក៏មាន មាននរណាភ័យផងហ្នឹង ហើយគាត់បានទៅប្រាប់គេទៀត»។ សម្តេចធិបតីបានថ្លែងអំណរគុណជាថ្មីចំពោះវិនិយោគិនជនជាតិចិនទាំងនោះ ដែលមានជំនឿទុកចិត្តលើប្រទេសកម្ពុជា ហើយបានបន្តជួយយកអាសារការពារកម្ពុជា។ សម្តេចស្នើក៏ឱ្យបន្តបង្កើតការងារផ្តល់ការយកចិត្តទុកដាក់ទៅលើជីវភាព សុវត្ថិភាព និងបរិស្ថានការងារដល់បងប្អូនកម្មករបន្តទៀត។ សម្តេចបានបញ្ជាក់ថា **«សូមបន្តជឿទុកចិត្ត និងពង្រីកការវិនិយោគជាបន្ថែមទៀត រដ្ឋាភិបាលនឹងខិតខំជួយ ហើយក៏នឹងខិតខំបន្តទាក់ទាញមកវិនិយោគថែមទៀត»**។

## លោកជំទាវ ជូ ប៊ុនអេង
## អញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំ សិក្ខាសាលាទិវាជាតិអន្តរសាសនា

https://www.hotnews-asia.com/detail/225098 ចេញផ្សាយ ថ្ងៃទី 7 ខែ វិច្ឆិកា ឆ្នាំ 2023

**ភ្នំពេញ៖** នាព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមរៀបចំ សិក្ខាសាលាទិវាជាតិអន្តរសាសនា ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងអង្គការជាដៃគូរ និងមន្ត្រីជំនាញពាក់ព័ន្ធជាច្រើនរូបផងដែរ។

លោកជំទាវ ជូ ប៊ុនអេង បានថ្លែងនូវមតិស្វាគមន៍ ព្រមទាំងថ្លែងនូវអំណរគុណចំពោះ ការអញ្ជើញចូលរួមរបស់តំណាងមកពីក្រសួងពាក់ព័ន្ធ និងតំណាងអង្គការជាដៃគូរដែលចូលរួមកិច្ចប្រជុំនាពេលនេះ។

ជាមួយគ្នានោះលោកជំទាវក៏បានលើកឡើងនៅមូលហេតុនៃការលើកពេលចំពោះការរៀបចំសិក្ខាសាលាទិវាជាតិអន្តរសាសនា ដែលគ្រោងរៀបចំនៅថ្ងៃទី២០ ខែសីហាកន្លងទៅ តែដោយរាជរដ្ឋាភិបាលរៀបចំសមាសភាពគណៈរដ្ឋមន្ត្រី និងរាជរដ្ឋាភិបាលថ្មីដែលធ្វើឱ្យការរៀបចំ សិក្ខាសាលាទិវាជាតិអន្តរសាសនា ហួសថ្ងៃកំណត់ ។

លោកជំទាវមានប្រសាស៍ លើកឡើងថាកិច្ចប្រជុំនាពេលនេះ ដើម្បីត្រៀមរៀបចំសិក្ខាសាលាទិវាជាតិអន្តរសាសនានេះ នៅវេលាសមស្របណាមួយ ព្រមទាំងត្រូវត្រៀមលក្ខណៈឱ្យល្អប្រសើរស្របតាមបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ស្វែងរកជាតុចូល ការកំណត់រកទិសដៅជាប្រធានបទមួយសម្រាប់ជាប្រយោជន៍រួមដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហា ការរងគ្រោះនៃអំពើរជួញដូរមនុស្ស។

សូមជម្រាបជូនថា ជារៀងរាល់ឆ្នាំព្រះរាជាណាចក្រកម្ពុជាកំណត់យកថ្ងៃទី២០ ខែសីហា ជាថ្ងៃប្រារព្ធទិវាជាតិអន្តរសាសនា ការរៀបចំទិវានេះឡើង ដើម្បីបញ្ជាក់ពីភាពសុខដុមរមនាសាសនាទាំងឡាយនៅកម្ពុជា និងបានបង្ហាញពីឆន្ទៈមោះមុតពីថ្នាក់ដឹកនាំ និងបព្វជិតនៃនិកាយសាសនា

ទាំងឡាយក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាទម្រង់អមនុស្សធម៌មួយនៃការរំលោភបំពានលើសិទ្ធិ សេរីភាព និងកេងប្រវ័ញ្ចលើរាងកាយ សតិបញ្ញា កម្លាំងពលំរបស់មនុស្សយ៉ាងធ្ងន់ធ្ងរ។ក្នុងនោះ ជំនឿសាសនា គឺជាផ្នែកមួយនៃការអប់រំខ្ពស់ផ្នែកស្មារតី និងឥរិយាបថក្នុងការរស់នៅឱ្យប្រកបដោយគុណធម៌ មនុស្សមានស្មារតីភ្ញាក់រលឹក ស្គាល់ខុស ស្គាល់ត្រូវ និងខិតខំកសាងខ្លួនឲ្យមនុស្សល្អក្នុងសង្គមបានដោយ។

## ឧបនាយករដ្ឋមន្ត្រី នេត សាវឿន ជួបពិភាក្សាការងារជាមួយ ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា ដោយផ្តោតសំខាន់លើការងារសន្តិសុខ និងពង្រឹងទំនាក់ទំនង

https://www.tvk.gov.kh/?p=40664 ចេញផ្សាយ ថ្ងៃទី 7 ខែ វិច្ឆិកា ឆ្នាំ 2023 124

(ភ្នំពេញ)៖ ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅរសៀលថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ បានអនុញ្ញាតឲ្យឯកឧត្តម W.Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ជួបសម្តែងការគួរសម និងពិភាក្សាការងារ។ ជំនួបនេះត្រូវបានធ្វើឡើង នៅវិមានសន្តិភាព។

ជំនួបដ៏មានសារៈសំខាន់នេះ ត្រូវបានធ្វើឡើង ដើម្បីពង្រឹងបន្តកិច្ចសហប្រតិបត្តិការ លើការងារសន្តិសុខ ផ្លាស់ប្តូរព័ត៌មាន ដើម្បីទប់ស្កាត់អំពើភេរវកម្ម បទល្មើសបច្ចេកវិទ្យា និងបទឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ ព្រមទាំងបន្តលើការងារបណ្តុះបណ្តាល ពិសេសជំនាញបទល្មើសបច្ចេកវិទ្យា បទល្មើសប្រឆាំងការសម្អាតប្រាក់ និងប្រឆាំងគ្រឿងញៀនជាដើម។

ក្នុងឱកាសនោះ ឯកឧត្តមឯកអគ្គរដ្ឋទូត W.Patrick Murphy បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែង លើការងារការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនាពេលកន្លងមក ក្រោមការដឹកនាំបញ្ជាផ្ទាល់របស់ឧបនាយករដ្ឋមន្ត្រី នេត សាវឿន កាលនៅជាអគ្គស្នងការនគរបាលជាតិ។ ពិសេសការពារព្រឹត្តិការណ៍សំខាន់នានា ក្នុងនោះ មានទាំងដំណើរចូលរួមកិច្ចប្រជុំរបស់ប្រធានាធិបតីអាមេរិកនៅកម្ពុជា ហើយក៏ទទួលបាននូវការកោតសរសើរ ពីស្ថាប័នការពារផ្ទាល់របស់ប្រធានាធិបតី។

ឯកឧត្តមW.Patrick Murphy បានសំណូមពរដល់ ឧបនាយករដ្ឋមន្ត្រី នេត សាវឿន បន្តជួយគាំទ្រដល់ក្រុមការងារ Task Force ដែលបានបង្កើតឡើងរួមគ្នារវាង អគ្គស្នងការដ្ឋាននគរបាលជាតិ និង FBI របស់សហរដ្ឋអាមេរិក។ ឯកឧត្តមឯកអគ្គរដ្ឋទូតអាមេរិក បានអះអាងថា កន្លងមកក្រុមការងារនេះ បានជួយធ្វើការងារជាច្រើន ក្នុងការបង្ក្រាបបទល្មើសដែលបង្កដោយពលរដ្ឋអាមេរិក ដើម្បីចាប់ជនបង្កទាំងនោះ បញ្ជូនទៅផ្តន្ទាទោសនៅអាមេរិកវិញ ហើយបម្រើដល់ប្រយោជន៍រដ្ឋាភិបាលអាមេរិកជាច្រើនផងដែរ។

ជាការឆ្លើយតប ឧបនាយករដ្ឋមន្ត្រី នេត សាវឿន បានឯកភាពទាំងស្រុងចំពោះសំណូមពរ របស់ឯកអគ្គរដ្ឋទូតអាមេរិក និងបានសំណូមពរទៅកាន់ភាគីអាមេរិកវិញ ឲ្យបន្តជួយលើការងារ បណ្តុះបណ្តាលមន្ត្រីជំនាញ មន្ត្រីបច្ចេកទេស ក៏ដូចជាសម្ភារៈនានា ដែលបម្រើដល់ការងារប្រយុទ្ធ ប្រឆាំងបទល្មើស បទឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ បទល្មើសប្រឆាំងភេរវកម្ម និងបទល្មើសគ្រឿង ញៀនជាដើម។

បន្ថែមពីនេះ ភាគីទាំងពីរក៏បានពិភាក្សាគ្នា អំពីកិច្ចសហប្រតិបត្តិការ លើការងារប្រឆាំងការ ជួញដូរមនុស្ស លុបបំបាត់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក៏ដូចជាចូលរួមចំណែក ក្នុងការដាក់ ទោសឲ្យបានធ្ងន់ធ្ងរលើជនដែលប្រព្រឹត្តបទល្មើសនេះផងដែរ៕

## ជនជាតិឥណ្ឌាដែលគេបង្ខាំងនៅកម្ពុជាត្រូវបានជួយសង្គ្រោះ

https://www.khmertimeskh.com/501388402//?p=1388402 November 7, 2023

បុរសអាយុ២៧ ឆ្នាំម្នាក់មកពី NR Pura ស្រុក Chikkamagaluru ត្រូវបានគេបង្ខាំងខ្លួននៅ កម្ពុជាត្រូវបានគេជួយសង្គ្រោះ និងកំពុងធ្វើដំណើរត្រឡប់ទៅផ្ទះវិញ។

Arathi Krishna អនុប្រធាននៃ NRI Forum រដ្ឋាភិបាលនៃរដ្ឋ Karnataka បាននិយាយថា កិច្ច ខិតខំប្រឹងប្រែងកំពុងបន្តជួយសង្គ្រោះឪពុកកូនពីរនាក់ពីក្រុង Kolar ដែលគេដឹងត្រូវបានបង្ខាំងខ្លួន នៅក្នុងប្រទេសនោះផងដែរ។ នៅក្នុងខែសីហា ឆ្នាំ២០២៣ ដែល Ashok កូនប្រុសរបស់ប្តីប្រពន្ធកម្ម ករនៅ NR Pura បានមកប្រទេសកម្ពុជា បន្ទាប់ពីគាត់ត្រូវបានសន្យាថានឹងទទួលបានការងារនៅក្នុង ក្រុមហ៊ុនចិនមួយ។ ពេលមកដល់ គាត់ត្រូវបានគេឲ្យទៅធ្វើការនៅក្រុមហ៊ុនផ្សេងនៅព្រំដែនកម្ពុជា- វៀតណាម។ នៅក្នុងខែតុលា ឪពុកម្តាយរបស់គាត់ បានទទួលដំណឹងពីស្ថានភាពរបស់ Ashok ។

Krishna បាននិយាយថា ឪពុកម្តាយរបស់ Ashok និងអាជ្ញាធរមូលដ្ឋានបានទាក់ទងគាត់កាល ពីថ្ងៃទី ២៥ ខែតុលា។ យោងតាម Krishna ក្រុមហ៊ុនដែលផ្តល់ការងារឱ្យ Ashok គឺពាក់ព័ន្ធនឹងការ លួចយកទិន្នន័យ (hacking) និងសកម្មភាពខុសច្បាប់នានា។ គាត់បាននិយាយថា៖ «គាត់ចង់លា ឈប់ ខណៈគាត់បដិសេធមិនព្រមធ្វើការ ហើយលិខិតឆ្លងដែនរបស់គាត់ត្រូវបានប្រគល់ទៅអាជ្ញាធរ មូលដ្ឋាន»។ គាត់បាននិយាយថា Ashok មានការព្រួយបារម្ភណ៍ ហើយសុំជំនួយ ដើម្បីឱ្យគេបញ្ជូន ខ្លួនត្រឡប់ទៅផ្ទះវិញ។ គាត់បានប្រាប់ឪពុកម្តាយគាត់ថា គាត់ត្រូវបានគេបង្ខាំងខ្លួន ហើយត្រូវបាន គេធ្វើបាបផ្លូវកាយ។ "គាត់ត្រូវបានគេធ្វើទារុណកម្ម ពេលគាត់មិនព្រមធ្វើការងារឱ្យគេ។ គេវាយគាត់ ហើយធ្វើបាបគាត់។ គាត់មិនអាចចេញពីកន្លែងនោះបានទេ ព្រោះវាមានការឃាមកាមយ៉ាងល្អ ហើយចាប់តាំងពីគាត់ចូលធ្វើការ លិខិតឆ្លងដែនគាត់ត្រូវបានក្រុមហ៊ុនយកទុក»។

"ខ្ញុំបានដឹងថា ភ្នាក់ងារការងារបានជូនដំណឹងដល់គ្រួសារថាពួកគេត្រូវតែបង់ប្រាក់ចំនួន១៣ លានរូពី ទៅឱ្យក្រុមហ៊ុនដើម្បីដោះលែង Ashok ។ គេប្រមូលលុយដើម្បីលោះកូនប្រុសគាត់មកវិញ។ ខ្ញុំបានសុំឱ្យពួកគេកុំទាន់ផ្ញើប្រាក់ឱ្យសោះ យើងបានស្នើទៅក្រសួងកិច្ចការបរទេស ដែលសម្របសម្រួលជាមួយផ្នែកកុងស៊ុល ផ្នែកលិខិតឆ្លងដែន និងផ្នែកទិដ្ឋាការ ហើយបានជួបឯកអគ្គរាជទូតកម្ពុជា និងវៀតណាមនៅទីក្រុងដេលី។ Krishna បានរៀបរាប់ថា ពួកគេបានទាក់ទងជាមួយក្រសួងមហាផ្ទៃកម្ពុជា។ ការសង្គ្រោះនឹងធ្វើឡើងនាពេលខាងមុខ"។ នាងបានប្រាប់សារព័ត៌មាន TOI កាលពីថ្ងៃអាទិត្យថា "កាលពីថ្ងៃសុក្រ លិខិតឆ្លងដែនរបស់ Ashok ត្រូវបានប្រគល់ទៅឱ្យគាត់ ហើយគាត់ត្រូវបានគេនាំទៅទីតាំងដែលមានសុវត្ថិភាព។ គាត់ត្រូវបានគ្រោងនឹងបញ្ជូនតាមជើងយន្តហោះត្រឡប់ទៅកាន់ Bengaluru នៅថ្ងៃអាទិត្យ"។

Krishna បាននិយាយថា ក្នុងរយៈពេលបីខែកន្លងទៅនេះ មានករណីក្លែងបន្លំការងារជាច្រើននៅអាស៊ីបូព៌ា ដោយក្រុមហ៊ុនចិន ដោយពួកគេមិនអាចដឹងថាតើភ្នាក់ងារការងារដែលទាក់ទងនោះពិតឬអត់។ "យើងនឹងសរសេរលិខិតទៅក្រសួងការបរទេស ស្នើសុំការត្រួតពិនិត្យ មុនពេលពួកគេចាកចេញទៅធ្វើការក្រៅប្រទេស ដើម្បីកុំឱ្យពួកគេជាប់ពាក់ព័ន្ធជាមួយភ្នាក់ងារ និងក្រុមហ៊ុនក្លែងបន្លំ។ ពីមុន យើងឃើញករណីបែបនេះកើតឡើងពីបណ្ដាប្រទេសឈូងសមុទ្រ ប៉ុន្តែឥឡូវនេះវាកើតមានឡើងក្នុងបណ្ដាប្រទេសអាស៊ីបូព៌ាផងដែរ»។

# ថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ២០២៣

## កម្ពុជា-អាមេរិក ជួបពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការ លើការងារប្រឆាំងការជួញដូរមនុស្ស និងលុបបំបាត់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

https://www.hotnews-asia.com/detail/225274 ចេញផ្សាយ ថ្ងៃទី 8 ខែ វិច្ឆិកា ឆ្នាំ 2023

**ភ្នំពេញ៖** នៅរសៀលថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអនុញ្ញាតឲ្យលោក W.Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ជួបសម្តែងការគួរសម និងពិភាក្សាការងារ។ ជំនួបនេះ ត្រូវបានធ្វើឡើង ដើម្បីពង្រឹងបន្តកិច្ចសហប្រតិបត្តិការលើការងារសន្តិសុខ ផ្លាស់ប្តូរព័ត៌មាន ដើម្បីទប់ស្កាត់អំពើភេរវកម្ម បទល្មើសបច្ចេកវិទ្យា និងបទឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ ព្រមទាំងបន្តលើការងារបណ្តុះបណ្តាល ពិសេសជំនាញបទល្មើសបច្ចេកវិទ្យា បទល្មើសប្រឆាំងការសម្អាតប្រាក់ និងប្រឆាំងគ្រឿងញៀនជាដើម។

ភាគីទាំងពីរក៏បានពិភាក្សាគ្នា អំពីកិច្ចសហប្រតិបត្តិការ លើការងារប្រឆាំងការជួញដូរមនុស្ស លុបបំបាត់អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក៏ដូចជាចូលរួមចំណែក ក្នុងការដាក់ទោសឲ្យបានធ្ងន់ធ្ងរលើជនដែលប្រព្រឹត្តបទល្មើសនេះផងដែរ។

ក្នុងឱកាសនោះ ឯកអគ្គរដ្ឋទូត W.Patrick Murphy បានសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែង លើការងារការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពនាពេលកន្លងមក ក្រោមការដឹកនាំបញ្ជាផ្ទាល់របស់ឧបនាយករដ្ឋមន្ត្រី នេត សាវឿន កាលនៅជាអគ្គស្នងការនគរបាលជាតិ។ ពិសេសការពារព្រឹត្តិការណ៍សំខាន់នានា ក្នុងនោះ មានទាំងដំណើរចូលរួមកិច្ចប្រជុំរបស់ប្រធានាធិបតីអាមេរិកនៅកម្ពុជា ហើយក៏ទទួលបាននូវការកោតសរសើរ ពីស្ថាប័នការពារផ្ទាល់របស់ប្រធានាធិបតី។

លោក W.Patrick Murphy បានសំណូមពរដល់ ឧបនាយករដ្ឋមន្ត្រី នេត សាវឿន បន្តជួយគាំទ្រដល់ក្រុមការងារ Task Force ដែលបានបង្កើតឡើងរួមគ្នារវាង អគ្គស្នង ការដ្ឋាននគរបាលជាតិ និង FBI របស់សហរដ្ឋអាមេរិក។ លោកឯកអគ្គរដ្ឋទូតអាមេរិក បានអះអាងថា កន្លងមកក្រុមការងារនេះ បានជួយធ្វើការងារជាច្រើន ក្នុងការបង្ក្រាបបទល្មើសដែលបង្កដោយពលរដ្ឋអាមេរិក ដើម្បីចាប់ជនបង្កទាំងនោះ បញ្ជូនទៅផ្តន្ទាទោសនៅអាមេរិកវិញ ហើយបម្រើដល់ប្រយោជន៍រដ្ឋាភិបាលអាមេរិកជាច្រើនផងដែរ។

ជាការឆ្លើយតប ឯកឧត្តមឧបនាយករដ្ឋមន្ត្រី នេត សាវឿន បានឯកភាពទាំងស្រុងចំពោះសំណូមពររបស់ឯកអគ្គរដ្ឋទូតអាមេរិក និងបានសំណូមពរទៅកាន់ភាគីអាមេរិកវិញ ឲ្យបន្តជួយលើការងារបណ្តុះបណ្តាលមន្ត្រីជំនាញ មន្ត្រីបច្ចេកទេស ក៏ដូចជាសម្ភារៈនានា ដែលបម្រើដល់ការងារប្រយុទ្ធប្រឆាំងបទល្មើស បទឧក្រិដ្ឋឆ្លងដែនគ្រប់ប្រភេទ បទល្មើសប្រឆាំងភេរវកម្ម និងបទល្មើសគ្រឿងញៀនជាដើម៕

## លោកជំទាវរដ្ឋលេខាធិការ ប្រាក់ ច័ន្ទណាយ បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាស្តីពី " ការលើកកម្ពស់សមភាពយេនឌ័រ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារតាមប្រព័ន្ធអនឡាញ " នៅខេត្តតាកែវ

***[https://l.facebook.com/l.php?u=https%3A%2F%2Fwww.mptc.gov.kh](https://l.facebook.com/l.php?u=https%3A%2F%2Fwww.mptc.gov.kh) Ministry of Post and Telecommunications***

ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣

ខេត្តតាកែវ: នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគារ Alice Villa ខេត្តតាកែវ លោកជំទាវ ប្រាក់ ច័ន្ទណាយ រដ្ឋលេខាធិការនិងជាប្រធានក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានអញ្ជើញជាអធិបតីក្នុងសិក្ខាសាលាស្តីពី " ការលើកកម្ពស់សមភាពយេនឌ័រ

ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការទប់ស្កាត់អំពើហឹង្សាលើស្ត្រីនិងកុមារតាមប្រព័ន្ធអនឡាញ ” ដែលមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង លោក មាស អ៊ុយ នាយករដ្ឋបាលសាលាខេត្តតាកែវ លោកស្រី ម៉ម រតនា ប្រធានមន្ទីរកិច្ចការនារីខេត្តតាកែវ លោក លោកស្រី មន្ត្រីរាជការនៃមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្តចំនួន៤ រួមមាន ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តព្រះសីហនុ ព្រមទាំងសាខាប្រតិបត្តិករផ្តល់សេវាប្រៃសណីយ៍ និងសាខាប្រតិបត្តិករផ្តល់សេវាអុីនធឺណិត សរុបប្រមាណ ១០០រូប។

សិក្ខាសាលានេះមានគោលបំណងចែករំលែកចំណេះដឹងជូនសិក្ខាកាម ជាមន្ត្រីរាជការមកពីមន្ទីរ ប.ទ.ខេត្ត អង្គភាពពាក់ព័ន្ធក្នុងការចូលរួមលើកកម្ពស់សមភាពយេនឌ័រ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការទប់ស្កាត់អំពើហឹង្សាលើស្ត្រី និងកុមារតាមប្រព័ន្ធអនឡាញ ដោយផ្តោតលើប្រធានបទៈ ការផ្សព្វផ្សាយអនុសាសន៍១២ ចំណុច របស់ សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន និងអនុសាសន៍ ៦ចំណុចរបស់ សម្តេចគតិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងការងារលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ, ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស, ស្ត្រីក្នុងភាពជាអ្នកដឹកនាំ, ការទប់ស្កាត់អំពើហឹង្សាលើស្ត្រី និងកុមារតាមប្រព័ន្ធអនឡាញ, និងការជំរុញសកម្មភាពស្ត្រីក្នុងការចាប់យកជំនាញឌីជីថល។

នៅក្នុងឱកាសនោះ លោកជំទាវរដ្ឋលេខាធិការ ប្រាក់ ច័ន្ទណាយ បានមានប្រសាសន៍ថា ការផ្តល់ឱកាសនិងការជំរុញភាពអង់អាចដល់ស្ត្រី គឺជាយន្តការសំខាន់ក្នុងការកាត់បន្ថយវិសមភាពយេនឌ័រ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់គុណភាពជីវិត និងឈានទៅសម្រេចឱ្យបានចំណាត់ថ្នាក់ ជាប្រទេសមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ស្របជាមួយគ្នានេះ លោកជំទាវរដ្ឋលេខាធិការ បានសំណូមពរដល់ថ្នាក់ដឹកនាំទាំងអស់បន្តយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីធ្វើឱ្យប្រសើរឡើង នូវ សិទ្ធិ ឋានៈ តួនាទី និងជីវភាពរស់នៅរបស់មន្ត្រីរាជការនារី នៅក្នុងអង្គភាពរបស់ខ្លួនតាមរយៈ៖

១).បន្តលើកកម្ពស់សមធម៌យេនឌ័រ ជំរុញភាពអង់អាចរបស់ស្ត្រីក្នុងសេដ្ឋកិច្ច ក្នុងការបណ្តុះបណ្តាលបំពាក់បំប៉នជំនាញបច្ចេកទេស ដើម្បីបង្កើនសមត្ថភាពរបស់ស្ត្រីក្នុងការផ្តល់ឱកាសដល់ស្ត្រីឱ្យទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេសថ្មីៗបន្ថែមទៀត និង

២).បន្តបង្កើនសមាមាត្រការចូលរួមរបស់ស្ត្រីឱ្យបានកាន់តែច្រើនឡើង តាមរយៈការលើកកម្ពស់សិទ្ធិ និងឋានៈ របស់ស្ត្រី ក្នុងគ្រប់ថ្នាក់ ដើម្បីឱ្យស្ត្រីបានចូលរួមកាន់តែសកម្មក្នុងការធ្វើសេចក្តីសម្រេចនានា។

ឆ្លៀតឱកាសនេះ លោកជំទាវរដ្ឋលេខាធិការ បានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំក្រសួង ដែលតែងតែឧបត្ថម្ភគាំទ្រក្នុងការលើកកម្ពស់សមភាពយេនឌ័រ ហើយលោកជំទាវក៏បានថ្លែងអំណរគុណដល់វាគ្មិន ដែលបានចំណាយពេលក្នុងការចែករំលែកនូវចំណេះដឹងនិងបទពិសោធន៍ថ្មីៗជូនសិក្ខាកាម និងមានសង្ឃឹមថា សិក្ខាកាមទាំងអស់ នឹងបានយល់ដឹងបន្ថែមនូវចំណុចសំខាន់ៗក្នុងការលើកកម្ពស់សមភាពយេនឌ័រ ព្រមទាំងបន្តផ្សព្វផ្សាយនៅតាមអង្គភាពរៀងៗខ្លួន ដើម្បីចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមជាតិយើងអោយកាន់តែរីកចម្រើនថែមទៀត។

## រដ្ឋមន្ត្រីកិច្ចការនារី៖ ក្នុងស្ថានភាពបែបណា ក៏កម្ពុជាមិនបោះបង់ឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្ត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://freshnewsasia.com/index.php/en/localnews/317133-2023-11-08-14-02-57.html 2023-11-08 09:02pm

**(ភ្នំពេញ)៖** លោកស្រី អ៊ីង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រាប់ទៅគណៈប្រតិភូស្ថានទូតអាមេរិកប្រចាំកម្ពុជា ថា ទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក្តី ក៏រាជរដ្ឋាភិបាលកម្ពុជា មិនបោះបង់ឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឡើយ។ លោកស្រីថ្លែងបែបនេះ ពេលជួបពិភាក្សាការងារជាមួយ លោក ផាកទ្រីក មឺរហ្វី ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា និងគណៈប្រតិភូ នៅរសៀលថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងមហាផ្ទៃ។ លោកស្រី អ៊ីង កន្ថាផាវី បានថ្លែងថា កម្ពុជា នៅមិនទាន់អាចជម្នះបានទាំងស្រុងនៅឡើយទេលើឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលមាននៅក្នុងបណ្តាញសង្គមងងឹតយ៉ាងទូលំទូលាយ ដែលព្យាយាម ប្រើប្រាស់គ្រប់ឧបាយកល និងមធ្យោបាយបច្ចេកវិទ្យាទំនើបដ៏សម្បូរបែប ដែលបាន និងកំពុងពង្រីកខ្លួននៅទូទាំងតំបន់ និងក្នុងពិភពលោក ហើយក៏មិនទាន់មានប្រទេសណាមួយ ដែលបានបោសសម្អាតឧក្រិដ្ឋកម្មនេះ បានជោគជ័យទាំងស្រុងនៅឡើយដែរ។

លោកស្រី អ៊ីង កន្ថាផាវី បានបន្តថា ជនល្មើសបានប្រើល្បិចកលទាក់ទាញមនុស្សនៅគ្រប់ទីកន្លែង ដែលកំពុងតែប្រឈមនឹងវិបត្តិសេដ្ឋកិច្ច និងសង្គមជាសាកល បណ្តាលមកពីកូវីដ១៩ គ្រោះធម្មជាតិ និងសង្គ្រាម វិនាសកម្ម ដែលកាន់តែស្មុគ្រស្មាញទៅ ឲ្យចូលក្នុងអន្ទាក់នៃការឆបោកគ្រប់រូបភាព។ បញ្ហានេះបានជះឥទ្ធិពលដល់ បណ្តាប្រទេស តូចធំទាំងឡាយ ហើយកម្ពុជាក៏ជាប្រទេសរងគ្រោះយ៉ាងធ្ងន់ធ្ងរផងដែរ។ បញ្ហាជួញដូរជាបញ្ហាដែលប្រទេសទាំងអស់ត្រូវរួមគ្នាទទួលខុសត្រូវដោះស្រាយ ទោះបីជាបទល្មើសមួយចំនួន ជាមធ្យោបាយថ្មី បង្កឡើងដោយឧក្រិដ្ឋជនក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងរិះរកវិធានការ ដើម្បីបើកប្រតិបត្តិការស៊ើបអង្កេត ស្រាវជ្រាវ និងប

ផ្ទ្រាបបទល្មើសនេះយ៉ាងសកម្ម ដោយបើកទូលាយឲ្យមានបណ្តាញរាយការណ៍ទាន់ហេតុការណ៍ និងបើកប្រតិបត្តិការបានរហូតដល់ទៅជាង ១០៦៧ករណី ក្នុងរយៈពេលតែមួយឆ្នាំ ដើម្បីរុករក និងបំផ្លាញបណ្តាញឧក្រិដ្ឋជន និងសង្គ្រោះជនរងគ្រោះឲ្យបានទាន់ពេលវេលា បើទោះបីជាករណីទាំងនោះ មិនមែនជាករណីជួញដូរមនុស្ស ឬមានការផ្តល់ព័ត៌មានមិនពិតក៏ដោយ។

លោកស្រីបន្តថា រាជរដ្ឋាភិបាលកម្ពុជា តែងបានអំពាវនាវដល់បណ្តា ប្រទេសដែលមានជាប់ពាក់ព័ន្ធ ទាំងជនល្មើស ទាំងជនរងគ្រោះ ឲ្យរួមសហការជាមួយកម្ពុជា ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស និងដោះស្រាយបញ្ហារួមគ្នា ឲ្យបានល្អប្រសើរ ព្រោះនេះជាបញ្ហារួម មិនមែនជាបញ្ហាដោយឡែក តែកម្ពុជានោះទេ។ កន្លងមក រហូតដល់បច្ចុប្បន្ន ប្រជាជនកម្ពុជា ត្រូវបានទទួលរងនឹងការកេងប្រវ័ញ្ច ក្នុងអំឡុងពេលនៃទេសន្តរប្រវេសន៍ ដូចជា ការងារដោយបង្ខំនិងកេងប្រវ័ញ្ចតាមទូកនេសាទ ការងារ តាមផ្ទះ ការកេងប្រវ័ញ្ចតាមរូបភាពអាពាហ៍ពិពាហ៍នៅក្រៅប្រទេស ជាដើម តែកម្ពុជាបានខិតខំរួមសហការ ដើម្បីដោះស្រាយបញ្ហា បើទោះបីជាការដោះស្រាយនោះនៅមិនទាន់បានលទ្ធផលល្អប្រសើរក៏ដោយ។

«ទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក្តីក៏រាជរដ្ឋាភិបាលកម្ពុជាមិនបោះបង់ឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឡើយហើយថែមទាំងចាត់ទុកថា ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺជាអាទិភាពមួយក្នុងចំណោម អាទិភាពទាំងឡាយ ក្នុងរបៀបវារៈនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលដឹកនាំដ៏ខ្ពង់ខ្ពស់ដោយ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រី នៃព្រះរាជរដ្ឋាភិបាលកម្ពុជា»។ នេះបើតាមលោកស្រី អ៊ឹង កន្ថាផាវី។

លោកស្រីបន្ថែមថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) គឺជាយន្តការជាតិ អន្តរក្រសួង-អន្តរស្ថាប័ន ដែលមានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ សម្របសម្រួល និងស្វែងរកការចូលរួមសហការ ការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ នៅថ្នាក់ជាតិ និងអន្តរជាតិ ក៏ដូចជាអង្គការសហប្រជាជាតិ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព និងពង្រីកទំនាក់ទំនងសហការជាមួយតំបន់ និងពិភពលោក ក្នុងគោលបំណងពិនិត្យតាមដានភាពប្រែប្រួលនៃបទល្មើសជួញដូរមនុស្ស និងចូលរួមសហការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងឲ្យបានជោគជ័យ៕

## ក្រសួងសង្គមកិច្ច និង JICA
## កំពុងអនុវត្តគម្រោងរួមគ្នាជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស

https://www.postkhmer.com/national/2023-11-08-0724-255840.html *ជា សុខនី* ׀ Publication date 08 November 2023 ׀ 07:24 ICT

*ភ្នំពេញៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) កំពុងអនុវត្តគម្រោងរួមគ្នា ដើម្បីជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យទទួលបានសេវាពេញលេញលើការប្រឹក្សាយោបល់ សុខភាព សេដ្ឋកិច្ច និងប្រព័ន្ធយុត្តិធម៌ ដោយគម្រោងនេះផ្តល់សេវាគាំពារទាំងជនជាតិខ្មែរ និងបរទេស។*

*លោក ញឹម វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ថ្លែងនៅថ្ងៃទី ៧ ខែវិច្ឆិកាថា ក្រសួងបានប្រជុំជាមួយ JICA នាពេលថ្មីៗនេះ ដោយបានពិភាក្សាគ្នាលើការអនុវត្តគម្រោងរួមគ្នាមួយ ដើម្បីធ្វើយ៉ាងណាជួយទៅដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យទទួលបានសេវាពេញលេញលើការប្រឹក្សាយោបល់ សុខភាព សេដ្ឋកិច្ច និងប្រព័ន្ធយុត្តិធម៌ជាដើម។ ក្រសួង និង JICA បានប្រជុំពិភាក្សាគ្នា ដើម្បីធ្វើការកសាង និងអភិវឌ្ឍសមត្ថភាពទៅដល់ក្រុមគោលដៅ ក្នុងពេលដែលឱ្យពួកគាត់ជួយទៅដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សឱ្យទទួលបានសេវាកាន់តែមានប្រសិទ្ធភាព។*

*លោកថា៖«គម្រោងហ្នឹងបានជួយដល់កម្ពុជាយើងបានច្រើនជាពិសេសវាជាឧត្តមប្រយោជន៍សម្រាប់ជនរងគ្រោះដោយអំពើជួញដូរ ហើយវាក៏មិនមែនតែសម្រាប់ជនជាតិកម្ពុជានោះទេ ជនជាតិអីក៏ដោយឱ្យតែត្រូវបានជួញដូរនៅលើទឹកដីកម្ពុជា ត្រូវបានយើងយកចិត្តទុកដាក់ និងផ្តល់សេវាគាំពារ»។ គម្រោងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សនេះ បានចាប់ផ្តើមអនុវត្តតាំងពីខែមីនា ឆ្នាំ ២០២៣ រហូតដល់ខែកញ្ញា ឆ្នាំ ២០២៦ ដែលមានរយៈពេល ៣ឆ្នាំកន្លះ ក្នុងនោះមានខេត្តគោលដៅចំនួន៣រួមមាន៖ខេត្តសៀមរាប ត្បូងឃ្មុំ និងខេត្តបន្ទាយមានជ័យ ដែលកំពុងអនុវត្តគម្រោងនេះ។ នេះបើតាមលោក ញឹក វណ្ណារ៉ា។ លោកបានបន្ថែមថា ខណៈដែលគម្រោងនេះកំពុងអនុវត្តក្នុងខេត្តគោលដៅទាំងនោះ ក្នុងពេលឆាប់ៗខាងមុខនេះ ទាំងក្រសួង និង JICA នឹងឈានដល់ការចុះហត្ថលេខាជាផ្លូវការ ក្នុងការអនុវត្តគម្រោងជួយជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស (២០២៣ -២០២៦)។*

*លោក នី សុខា ប្រធានសមាគមការពារសិទ្ធិមនុស្ស អាដហុក បានថ្លែងថា កន្លងមកអ្នកដែលទទួលរងគ្រោះដោយអំពើជួញដូរមនុស្សតាមរយៈមេខ្យល់ក្តី តាមរយៈកម្រិតចំណេះដឹងព័ត៌មាននិងបញ្ហាជីវភាពក្តីគឺសុទ្ធតែជាបញ្ហាដែលធ្វើឱ្យប្រជាពលរដ្ឋងាយរងគ្រោះក្នុងអំពើជួញដូរនេះ។ លោកថា នៅពេលដែលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវបានរំដោះត្រឡប់មកវិញ អ្វីដែលជនរងគ្រោះត្រូវការបំផុតនោះគឺសេវាសង្គម និងសេវាយុត្តិធម៌ ខណៈដែលកន្លងមកនេះ ជនរងគ្រោះ*

ហាក់បីដូចជាទទួលបានសេវាទាំងនេះនៅខ្វះខាតនិងនៅមិនទាន់ដោះស្រាយឱ្យមានប្រសិទ្ធភាពនៅឡើយៗ

## អាជ្ញាធរខ្មែរបញ្ជូនឧក្រិដ្ឋជនជនជាតិជប៉ុន ២៥នាក់ ទៅអនុវត្តទោសនៅជប៉ុន

ឧក្រិដ្ឋជនជនជាតិជប៉ុនចំនួន ២៥នាក់ ត្រូវបានប៉ូលីសអន្តោប្រវេសន៍កម្ពុជាចាប់បញ្ជូនទៅប្រទេសរបស់ពួកគេវិញកាលពីថ្ងៃទី០៨ ខែវិច្ឆិកាម្សិលមិញ បន្ទាប់ពីពួកគេបានធ្វើសកម្មភាពឆបោកតាមប្រព័ន្ធទូរស័ព្ទ។ ការបញ្ជូនជនល្មើសជាតិជប៉ុនឡើងយន្តហោះនេះ ធ្វើឡើងដោយមានវត្តមានតំណាងស្ថានទូតជប៉ុនប្រចាំកម្ពុជា និងមានការទទួលពីប៉ូលីសជប៉ុន ដើម្បីនាំពួកគេទៅអនុវត្តទោសនៅប្រទេសជប៉ុន។

https://www.rfi.fr/km//20231109-?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 09/11/2023 - 05:55

យោងតាមអគ្គនាយកដ្ឋានអន្តោប្រវេសន៍កម្ពុជា ជនជាតិជប៉ុនទាំង២៥នាក់នេះ ត្រូវបានសមត្ថកិច្ចខ្មែរបង្ក្រាប និងចាប់ខ្លួនកាលពីខែកញ្ញា ឆ្នាំ២០២៣ នៅក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញបន្ទាប់ពីពួកគេបានធ្វើសកម្មភាពឆបោកតាមប្រព័ន្ធទូរស័ព្ទលើជនរងគ្រោះនៅប្រទេសជប៉ុន។ ជនជាតិជប៉ុនទាំងអស់នេះ ត្រូវបានចងដៃទាំងពីរទៅក្រោយ ជាមួយនឹងសម្លៀកបំពាក់ឃុំជិតដងខ្លួន និងមុខ និងកាន់ក្រៀកដោយកម្លាំងប៉ូលីសខ្មែរម្នាក់មួយ បណ្តើរឡើងយន្តហោះពិសេសជប៉ុននៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ក្រោមវត្តមានមេដឹកនាំប៉ូលីសខ្មែរ និងតំណាងស្ថានទូតជប៉ុននៅកម្ពុជា។

អាជ្ញាធរខ្មែរផ្នែកអន្តោប្រវេសន៍ បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកថាការបង្ក្រាបលើជនឧក្រិដ្ឋជប៉ុនទាំងអស់នេះ ក៏ដោយសារតែមានកិច្ចសហការផ្តល់ព័ត៌មានពីស្ថានទូតជប៉ុនទាន់ពេលវេលាដែរ ដោយសមត្ថកិច្ចខ្មែរធ្វើការអំពាវនាវដល់បណ្តាស្ថានទូតបរទេស និងជនបរទេសនានាបន្តផ្តល់ព័ត៌មានដល់សមត្ថកិច្ចប្រសិនបើមានព័ត៌មានពាក់ព័ន្ធនឹងបទល្មើសផ្សេងៗ។

សូមរំលឹកថា កន្លងមកអាជ្ញាធរខ្មែរតែងសហការជាមួយអាជ្ញាធរចិន ចាប់បញ្ជូនឧក្រិដ្ឋជនចិនជាច្រើនរយនាក់ជាបន្តបន្ទាប់ឲ្យទៅទទួលទោសនៅប្រទេសចិន បន្ទាប់ពីពួកគេធ្វើសកម្មភាពឆបោកចាប់ជំរិតតាមប្រព័ន្ធអនឡាញ និងសកម្មភាពឧក្រិដ្ឋផ្សេងៗទៀត។ តាមរយៈសកម្មភាពឧក្រិដ្ឋទាំងចិន ទាំងជប៉ុន បែបនេះ ត្រូវគេមើលឃើញថាបញ្ហាសុវត្ថិភាពបានក្លាយទៅជាសំណួរ ដែលភ្ញៀវទេសចរបរទេសចោទសួរបន្ថែមទៀត បន្ទាប់ពីមានសំណួរ និងការព្រួយបារម្ភជាច្រើនរួចទៅហើយពី

ជនបរទេស ក្រោយភាពយន្តចិនរឿង«No More Bet» បានបង្ហាញជាសកលពីឧក្រិដ្ឋកម្មចាប់ជំរិត និងឆបោកតាមប្រព័ន្ធអនឡាញ នៅកម្ពុជា ថៃ និងភូមា។

ក៏ប៉ុន្តែសម្តេចកិច្ចកម្ពុជា តែងលើកឡើងថាកម្ពុជាបានក្លាយជាប្រទេសរងគ្រោះ ដោយសារជនបរទេសតែងតែយកកម្ពុជា ជាទីតាំងប្រព្រឹត្តបទល្មើសដោយលួចលាក់ ធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់កម្ពុជាលើឆាកអន្តរជាតិ ខណៈរដ្ឋាភិបាលក៏បានដាក់បទបញ្ជាម៉ឺងម៉ាត់ដែរ ដល់សមត្ថកិច្ចពាក់ព័ន្ធក្នុងការសហការស្រាវជ្រាវបង្រ្កាបបទល្មើសឆ្លងដែនគ្រប់ប្រភេទឲ្យមានប្រសិទ្ធភាព។ តែអ្នកតាមដានសង្គមនានាមើលឃើញថាការអនុវត្តន៍ច្បាប់នៅកម្ពុជាហាក់មិនមានភាពម៉ឺងម៉ាត់ ជាហេតុធ្វើឲ្យជនបរទេសជាពិសេសជនជាតិចិន តែងយកកម្ពុជាធ្វើសកម្មភាពឧក្រិដ្ឋ ដែលរូបភាពនេះ បានបង្ហាញឡើងបន្ទាប់ពីកម្ពុជាបានអនុញ្ញាតឲ្យមានការវិនិយោគ និងអភិវឌ្ឍន៍ខេត្តព្រះសីហនុចាប់តាំងពីឆ្នាំ ២០១៨មក។

## កម្ពុជា និងសហរដ្ឋអាមេរិក
## នឹងពង្រឹងកិច្ចសហការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://www.postkhmer.com/national/2023-11-09-1503-255885.html ជា សុខនី | Publication date 09 November 2023 | 15:03 ICT

ភ្នំពេញៈ ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា និងសហរដ្ឋអាមេរិក នឹងពង្រឹងកិច្ចសហការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ដើម្បីធានាការពារសន្តិសុខ សុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងអាយុជីវិតមនុស្សពីឧក្រិដ្ឋកម្មនានា។ ផែនការពង្រឹងកិច្ចសហការគ្នានេះ ត្រូវបានលើកឡើងនៅក្នុងជំនួបពិភាក្សាគ្នា រវាងឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា លោក W. Patrick Murphy ជាមួយស្ថាប័នរាជរដ្ឋាភិបាលពាក់ព័ន្ធរួមមាន ក្រសួងកិច្ចការនារី និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធនាគារជាតិនៃកម្ពុជា អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣។

តាមរយៈហ្វេសប៊ុកក្រសួងកិច្ចការនារី លោកស្រី អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ត្រូវបានស្រង់សម្តីនៅលើហ្វេសប៊ុករបស់ក្រសួងបានឱ្យដឹងថា ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពទាំងឡាយ ក្នុងរបៀបវារៈនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ស្ថិតក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រីកម្ពុជា។

លោកស្រី បញ្ជាក់ថា៖ «រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តខ្ពស់ តស៊ូពុះពារការលំបាក និង ឧបសគ្គទាំងឡាយ ដើម្បីការពារសន្តិសុខ សុវត្ថិភាព សេចក្តីថ្លៃថ្នូរ និងអាយុជីវិតមនុស្ស ពីឧក្រិដ្ឋកម្ម នានា ជាពិសេសអំពើជួញដូរមនុស្សតាមរយៈការបើកប្រតិបត្តិការស៊ើបអង្កេតស្រាវជ្រាវ និងបង្រ្កាប បទល្មើសនេះយ៉ាងសកម្ម ដោយបើកទូលាយឱ្យមានបណ្តាញរាយការណ៍ទាន់ហេតុការណ៍ ដើម្បីប ង្ក្រាប និងសង្គ្រោះជនរងគ្រោះឱ្យបានទាន់ពេលវេលាផងដែរ»។

បើតាមក្រសួងកិច្ចការនារី បានឱ្យដឹងទៀតថា លោក W. Patrick Murphy បានសម្តែងនូវការ កោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញ ដូរមនុស្ស ដោយបានបញ្ជាក់ពីជំហររបស់សហរដ្ឋអាមេរិកក្នុងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងគាំទ្រជំនួយបច្ចេកទេសនានាដល់រាជរដ្ឋាភិបាលកម្ពុជា។លោកបញ្ជាក់ថា៖ «សហរដ្ឋអាមេរិក នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងគាំទ្រជំនួយបច្ចេកទេសនានាដល់រាជរដ្ឋាភិបាលកម្ពុជាក្នុង កិច្ចការនេះ ដើម្បីការពារឧត្តមប្រយោជន៍របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស»។

នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការការពារសិទ្ធិមនុស្សលីកាដូ លោក អំ សំអាត ថ្លែង ថា សហរដ្ឋអាមេរិក គឺជាដៃគូល្អក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា ខ ណៈដែលប្រទេសនេះ បានដាក់ចំណាត់ថ្នាក់កម្ពុជាដល់លំដាប់ថ្នាក់លេខ៣ ដែលជាចំណាត់ថ្នាក់ មិនល្អក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ លោកបញ្ជាក់ថា៖ «មានកត្តាមួយចំនួនដែលនាំឱ្យ កើតមានបទល្មើសនៃការជួញដូរមនុស្សនេះ គឺដោយសារការអនុវត្តច្បាប់នៅមានកម្រិតខ្វះកិច្ចសហ ការរវាងអាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងមានអំពើពុក រលួយជាដើម»។ លោកបានបន្ថែមថា ការជួញដូរមនុស្ស វាក៏ជះឥទ្ធិពលមិនល្អដល់សង្គមជាតិ និង ជនរងគ្រោះរួមមានអាចបង្កឱ្យមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបង្កភាពភ័យខ្លាច និងអសន្តិសុខ ដល់សង្គម ប៉ះពាល់ដល់សេដ្ឋកិច្ច និងការវិនិយោគទុន ហើយក៏បង្កឱ្យមានវិបត្តិធនធានមនុស្សទៅ ថ្ងៃអនាគតផងដែរ។

ពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះដែរ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានបើកសិក្ខាសាលាស្តីពី «ការលើកកម្ពស់សមភាពយេនឌ័រ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារតាមប្រព័ន្ធអនឡាញ» ទៅដល់មន្ត្រីថ្នាក់ក្រោមជាតិមក ពីខេត្តតាកែវ កំពង់ស្ពឺ កំពត និងខេត្តព្រះសីហនុ នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣។

លោកស្រី ប្រាក់ ច័ន្ទណាយ រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានថ្លែង ក្នុងសិក្ខាសាលាថា គោលបំណងនៃការរៀបចំសិក្ខាសាលានេះ គឺដើម្បីចែករំលែកចំណេះដឹងជូន ដល់អង្គភាពពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ក្នុងការចូលរួមលើកកម្ពស់សមភាពយេនឌ័រ ការប្រយុទ្ធ

ប្រឆាំងអំពើជួញដូរមនុស្ស និងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារតាមប្រព័ន្ធអនឡាញ។ ទន្ទឹមនេះ លោកស្រីសំណូមពរដល់ថ្នាក់ដឹកនាំទាំងអស់បន្តយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់មន្ត្រីរាជការនារី នៅក្នុងអង្គភាពរបស់ខ្លួនតាមរយៈការបន្តលើកកម្ពស់សមធម៌យេនឌ័រ និងលើកកម្ពស់សិទ្ធិ និងឋានៈ របស់ស្ត្រី ក្នុងគ្រប់ថ្នាក់ ដើម្បីឱ្យស្ត្រីបានចូលរួមកាន់តែសកម្មក្នុងការធ្វើសេចក្តីសម្រេចនានា។

លោកស្រីបញ្ជាក់ថា៖ «ការផ្តល់ឱកាស និងការជំរុញភាពអង់អាចដល់ស្ត្រី គឺជាយន្តការសំខាន់ក្នុងការកាត់បន្ថយវិសមភាពយេនឌ័រ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់គុណភាពជីវិត និងឈានទៅសម្រេចឱ្យបានចំណាត់ថ្នាក់ជាប្រទេសមានប្រាក់ចំណូលមធ្យម នៅឆ្នាំ ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០»។

# ថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ២០២៣

## អង្គការក្រៅរដ្ឋាភិបាល នឹងរៀបចំព្រឹត្តិការណ៍មួយលើកកម្ពស់ការយល់ដឹងលើពលករទេសន្តរប្រវេសន៍ជាស្ត្រី

https://www.postkhmer.com/national/2023-11-10-0904-255925.html ១០ វិច្ឆិកា ២០២៣ ។ ១៦: ០៤ អ្នកយកព័ត៌មាន: សុខ វក្សា

អង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការពាក់ព័ន្ធសិទ្ធិការងារ និងលើកកម្ពស់ស្ត្រី នឹងរៀបចំព្រឹត្តិការណ៍ពិសេស ក្រោមប្រធានបទ «ពាក្យពេចន៍មានសារៈសំខាន់» នៅចុងខែវិច្ឆិកានេះ ដើម្បីលើកកម្ពស់ការរាយការណ៍ប្រកប ដោយទទួលខុសត្រូវ ជុំវិញពលករទេសន្តរប្រវេសន៍ជាស្ត្រី។ ព្រឹត្តិការណ៍នេះ នឹងត្រូវរៀបចំឡើង នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០២៣ ចាប់ពីវេលាម៉ោង ២ដល់ម៉ោង ៥ ល្ងាច នៅទីតាំង Raintree Phnom Penh នៅក្នុងកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ (SAF)។

កម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ត្រូវបានអនុវត្ត ដោយអង្គការអន្តរជាតិខាងការងារ (ILO) និងទីភ្នាក់ងារសហប្រជាជាតិ ដើម្បីសមភាពយេនឌ័រ និងការលើកស្ទួយភាពអង់អាចរបស់ស្ត្រី (UN Women) ដែលដឹកនាំដោយការិយាល័យ ILO ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ នេះបើតាមសេចក្តីប្រកាសរួមនៃអង្គការខាងលើ។ សេចក្តីប្រកាសបន្តថា៖«កម្មវិធីសុវត្ថិភាពនិងយុត្តិធម៌ សូមគោរពអញ្ជើញលោកអ្នក ចូលរួមក្នុងកម្មវិធី ពាក្យពេចន៍មានសារៈសំខាន់៖ ការសម្ពោធ កម្រងសទ្ទានុក្រមវាក្យសព្ទ ស្តីអំពីទេសន្តរប្រវេសន៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ផ្តោតលើពលករទេសន្តរប្រវេសន៍ជាស្ត្រី និងការបញ្ឈប់អំពើហិង្សាលើស្ត្រី»។

ស្របពេលជាមួយនឹងយុទ្ធនាការ ១៦ ថ្ងៃ ប្រឆាំងអំពើហិង្សាលើស្ត្រី និងក្មេងស្រី កម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ប្រចាំនៅកម្ពុជា នឹងរៀបចំកម្មវិធីមួយសម្រាប់អ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងស្ថាប័នពាក់ព័ន្ធនានា។ ប្រភពដដែលបញ្ជាក់ថា៖«កម្មវិធីនេះ គឺជាការសម្ពោធ សទ្ទានុក្រមសម្រាប់ប្រព័ន្ធផ្សព្វផ្សាយជាភាសាខ្មែរ ដែលលើកកម្ពស់ការរាយការណ៍ប្រកបដោយការទទួលខុសត្រូវ ទៅលើការធ្វើទេសន្តរប្រវេសន៍ និងអំពើហិង្សាប្រឆាំងនឹងពលករទេសន្តរប្រវេសន៍ជាស្ត្រី ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃភាសាដែលមានការគិតគូរអំពីយេនឌ័រ»។ កម្មវិធីនេះ ត្រូវបានបង្កើតឡើងជាពិសេសសម្រាប់អ្នកមានវិជ្ជាជីវៈនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ រួមមានអ្នកសារព័ត៌មាន អ្នកនិពន្ធ អ្នករាយការណ៍ព័ត៌មាន អ្នកផលិតព័ត៌មាន អ្នកបង្កើតប្លុក អ្នកស្រាវជ្រាវ និងស្ថាប័ន សង្គមស៊ីវិល នានា។ កម្មវិធីនេះនឹងមានកិច្ចពិភាក្សាស្តីពីការរាយការណ៍លើប្រធានបទដែលនិយាយអំពីទេសន្តរប្រវេសន៍ការងារការជម្នះបទដ្ឋានសង្គមនិងផ្នត់គំនិតរើសអើង នឹងពង្រឹងភាពអង់អាចដល់ពលករជាស្ត្រី។

គួរជម្រាបថា កម្មវិធីសុវត្ថិភាពនិងយុត្តិធម៌ បានសម្រេចសិទ្ធិ និងឱកាសរបស់ពលករទេសន្តរប្រវេសន៍ជាស្ត្រី នៅក្នុងតំបន់អាស៊ាន (២០១៨-២០២៣)។ កម្មវិធីនេះគឺជាផ្នែកមួយនៃគំនិតផ្តួចផ្តើមប្រទីបបំភ្លឺផ្លូវ ដែលជាគំនិតផ្តួចផ្តើមសកលរួមគ្នារបស់អង្គការសហប្រជាជាតិ ដែលទទួលបានការគាំទ្រពីសហភាពអឺរ៉ុប (EU) ក្នុងគោលបំណងលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី៕

**កម្លាំងចម្រុះ ចុះបង្ក្រាបហាងម៉ាស្សា ភោសជប់ បន្ទប់សេវាផ្លូវភេទ ៤ទីតាំង ខណ្ឌច្បារអំពៅ រកឃើញជនរងគ្រោះ ១៩នាក់**

https://dap-news.com/national/2023/11/11/371646/?fbclid=IwAR2kpuL_sTRdEGilqYRejJFexP8NEE3jQLYCcNQnv8nMdscyZCIXzTBD5_Q ByPH104Posted on November 11, 2023 11:59 am

ភ្នំពេញ៖ ដោយមានការសម្របសម្រួលពីព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ កម្លាំងអធិការដ្ឋាននគរបាលខណ្ឌច្បារអំពៅ សហការជាមួយកម្លាំងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ បានចុះបង្ក្រាបករណីសញ្ចារកម្មចំនួន ៤ទីតាំង នៅខណ្ឌច្បារអំពៅ រកឃើញជនរងគ្រោះ ១៩នាក់ និងឃាត់ខ្លួនជនសង្ស័យ ៣នាក់ ។

ទីតាំងទាំង៤កន្លែង ដែលសមត្ថកិច្ចចុះបង្ក្រាបនោះរួមមាន៖

១-ហាងម៉ាស្សាកោសជប់ (៩៩៩) ផ្ទះគ្មានលេខ ផ្លូវ ១១៤ ភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ធែកឆេររកឃើញជនរងគ្រោះ ៥នាក់ (ស្រី ៤នាក់) និងជនសង្ស័យ ម្នាក់ (ស្រី)។

២-ហាងម៉ាស្សា (៧៧៧) ផ្ទះគ្មានលេខ ផ្លូវ ១១៤ ភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌ ច្បារអំពៅ ធែកឆេររកឃើញជនរងគ្រោះ ៤នាក់ (ស្រី)។

៣-ហាងម៉ាស្សា (៩៩៩៩) ផ្ទះលេខ១១០០ ផ្លូវ ១១៤ ភូមិចំពុះក្អែក សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ ធែកឆេររកឃើញជនរងគ្រោះ ៣នាក់ (ស្រី) និងជនសង្ស័យ ម្នាក់ (ស្រី)។

៤-ហាងម៉ាស្សាកោសជប់ (៩៩៩៩) ផ្ទះលេខ០១ ផ្លូវ ១១៤ ភូមិចំពុះក្អែក សង្កាត់ ព្រែកថ្មី ខណ្ឌច្បារអំពៅ ធែកឆេររកឃើញជនរងគ្រោះ ៣នាក់ (ស្រី) និងជនសង្ស័យ ម្នាក់ (ស្រី)។

បច្ចុប្បន្ន ជនរងគ្រោះ និងជនសង្ស័យ រួមទាំងវត្ថុតាងប្រគល់ឲ្យនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីចាត់ការបន្ត៕

## ជនចំណាកស្រុក១២៣នាក់ ត្រូវបានគេរកឃើញជាប់ក្នុងកុងតឺន័រកណ្តាលប្រទេសម៉ិកស៊ិក

https://www.postkhmer.com/international/2023-11-10-0535-255918.html ១០ វិច្ឆិកា ២០២៣ | ១២: ៣៥ អ្នកយកព័ត៌មាន:ស្រ៊ុន សិរី វឌ្ឍនៈ

ទីភ្នាក់ងារអន្តោប្រវេសន៍របស់ប្រទេសម៉ិកស៊ិក កាលពីថ្ងៃព្រហស្បតិ៍ ទី៩ ខែវិច្ឆិកា ឆ្នាំ២០២៣ បាននិយាយថា អាជ្ញាធរបានរកឃើញជនចំណាកស្រុកអាមេរិកឡាទីនកណ្តាល និងអាមេរិកឡាទីន ខាងត្បូង ចំនួន ១២៣ នាក់ ជាប់នៅក្នុងកុងតឺន័រមួយនៅកណ្តាលរដ្ឋ San Luis Potosi។ ជនចំណាកស្រុកទាំងអស់ ត្រូវបានរកឃើញដោយមន្ត្រីពីការិយាល័យមេធាវីរបស់រដ្ឋ San Luis Potosi នៅក្នុងទីក្រុង Matehuala បន្ទាប់ពីបានឮសំឡេងស្រែកឱ្យជួយចេញពីក្នុងកុងតឺន័រមួយដែលបានចាក់សោចោល។

បើយោងតាមវិទ្យាស្ថានអន្តោប្រវេសន៍ជាតិរបស់ប្រទេសម៉ិកស៊ិកបានឱ្យដឹងថា ភាគច្រើននៃជនចំណាកស្រុកដែលត្រូវបានជួយសង្គ្រោះគឺមកពីប្រទេសអាមេរិកឡាទីនកណ្តាលរួមមានប្រទេសហ្គាតេម៉ាឡា នីការ៉ាហ្គា ហុងឌូរ៉ាស អែលសាល់វ៉ាឌ័រ ព្រមទាំងបួននាក់មកពីប្រទេសអេក្វាឌ័រ និងម្នាក់មកពីប្រទេសគុយបា។ ហើយក្នុងចំណោមជនចំណាកស្រុករងគ្រោះទាំងនេះ មានកុមារចំនួន ៣៤ នាក់។ ទីភ្នាក់ងារអន្តោប្រវេសន៍មិនបានពន្យល់ពីរបៀបដែលជនចំណាកស្រុកមកជាប់គាំងនៅកណ្តាលទីក្រុង ឬបង្ហាញពីកន្លែងដែលពួកគេធ្វើដំណើរនោះទេ។ ចំណែកក្រុមជនចំណាកស្រុកវិញ ដឹងត្រឹមថាខ្លួនអាចនឹងទៅដល់ទឹកដីសហរដ្ឋអាមេរិកប៉ុណ្ណោះ។

នៅថ្ងៃដដែលនេះ ប៉ូលិសនៅទីក្រុង Ciudad Juarez ក្បែរបន្ទាត់ព្រំដែន El Paso រដ្ឋតិចសាស់ បានចាប់ខ្លួនអ្នករត់ពន្ធមនុស្ស ៣ នាក់ បន្ទាប់ពីបានរកឃើញជនចំណាកស្រុកមកពីប្រទេស Guatemalan ចំនួន ១១ នាក់ ជាប់នៅក្នុងផ្ទះមួយ ស្រដៀងនឹងករណីជាប់ក្នុងកុងតឺន័រខាងលើដែរ។

គួរជម្រាបថា គ្រោះថ្នាក់សម្រាប់ជនចំណាកស្រុកដែលរួមមាន ការចាប់ជំរិត ការឆបោក និងការទារប្រាក់ពីក្រុមក្មេងទំនើង ក្នុងតំបន់សម្រាប់ការធ្វើដំណើរឆ្លងកាត់ព្រំដែន បានក្លាយជាបញ្ហាធំមួយសម្រាប់អាជ្ញាធរនៅតំបន់អាមេរិកឡាទីន។ លើសពីនេះ ទាំងព្រំដែនភាគខាងត្បូងរបស់សហរដ្ឋអាមេរិក និងម៉ិកស៊ិក បានប្រឈមមុខនឹងកំណើនជនចំណាកស្រុកធ្វើដំណើរទៅកាន់តែច្រើនឡើងៗក្នុងឆ្នាំនេះ រួមទាំងប្រទេសប៉ាណាម៉ា នៅអាមេរិកឡាទីនកណ្តាលក៏ដូចគ្នា។ បើយោងតាមទិន្នន័យរបស់រដ្ឋាភិបាលប៉ាណាម៉ាបានឱ្យដឹងថា មនុស្សជាង ៤០ ម៉ឺននាក់បានឆ្លងកាត់តំបន់ Darien Gap ពីប្រទេសកូឡុំប៊ី ចូលទៅក្នុងប្រទេសរបស់ខ្លួនក្នុងឆ្នាំ ២០២៣៕

# ថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ២០២៣

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រៀបចំសិក្ខាសាលាថ្នាក់ជាតិការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ៥ឆ្នាំ (២០១៩-២០២៣) និងការបង្កើតផែនការយុទ្ធសាស្រ្តជាតិ៥ឆ្នាំ (២០២៤-២០២៨)

https://www.hotnews-asia.com/detail/226977 ចេញផ្សាយ ថ្ងៃទី 13 ខែ វិច្ឆិកា ឆ្នាំ 2023

**ភ្នំពេញ៖** នាព្រឹកថ្ងៃចន្ទ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានរៀបចំសិក្ខាសាលាថ្នាក់ជាតិការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ៥ឆ្នាំ (២០១៩-២០២៣) និងការបង្កើតផែនការយុទ្ធសាស្រ្តជាតិ៥ឆ្នាំ (២០២៤-២០២៨) ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងអង្គការដៃគូរ និងមន្រ្តីជំនាញពាក់ព័ន្ធជាច្រើនរូបផងដែរ។

ជាកិច្ចចាប់ផ្តើម លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា សិក្ខាសាលានៅក្នុងថ្ងៃនេះ គឺជាកិច្ចប្រជុំក្បាលម៉ាស៊ីនថ្នាក់ជាតិ ដើម្បីវាយតម្លៃចំណុចខ្វះខាតចន្លោះប្រហោង នៃការអនុវត្តផែនការយុទ្ធសាស្រ្តជាតិ៥ឆ្នាំ (២០១៩-២០២៣) ក៏ដូចជាពិភាក្សាប្រមូលធាតុចូល និងទិន្នន័យពីអ្នកពាក់ព័ន្ធទាំងអស់ដែលជាសមាជិកនៃគណៈកម្មាធិការជាតិគ.ជ.ប.ជ សម្រាប់រៀបចំផែនការយុទ្ធសាស្រ្តជាតិ៥ឆ្នាំបន្ត (២០២៤-២០២៨)។ លោកជំទាវបានបញ្ជាក់ថា

ការរៀបចំផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០២៤-២០២៨) នេះគឺផ្អែកលើការវាយតម្លៃយុទ្ធសាស្ត្រចាស់ដែលជាមូលដ្ឋានគ្រឹះ ពោលគឺការអនុវត្តយុទ្ធសាស្ត្រ៥ឆ្នាំកន្លងទៅ (២០១៩-២០២៣) និងផែនការយុទ្ធសាស្ត្រឆ្នាំមុនៗ រួមមាន ផែនការសកម្មភាព ឆ្នាំ២០១១-២០១៣, ផែនការសកម្មភាព ២០១៤-២០១៨, និងឯកសារគោលសម្រាប់អនុវត្ត ឆ្នាំ២០១៦-២០១៨ ជាដើម។ លោកជំទាវបានបន្តថា ការប្រមូលព័ត៌មាន និងធាតុចូលពីអ្នកអនុវត្តផ្ទាល់ និងអ្នកអនុវត្តសកម្មលើការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនេះ គឺពិតជាមានសារៈសំខាន់សម្រាប់ជាព័ត៌មានមូលដ្ឋាន ដោយពួកគាត់ជាអ្នកចុះផ្ទាល់ជាមួយស្ថាប័នពាក់ព័ន្ធ ចុះតាមសហគមន៍ដើម្បីប្រមូលមតិ សម្លេងពីជនរងគ្រោះ។

លោកជំទាវសង្ឃឹម និងជឿជាក់ថា តាមរយៈការបែងចែងជាក្រុមពិភាក្សា នៃកិច្ចប្រជុំថ្ងៃនេះ នឹងផ្តល់ជាទិន្នន័យ ជាតុចូល និងព័ត៌មានខុសៗគ្នា ដើម្បីយកមកបញ្ចូលគ្នាសម្រាប់កំណត់នូវចំណុចជាអាទិភាពក្នុងផែនការ៥ឆ្នាំទៅមុខ ក៏ដូចជារួមគ្នាប៉ាន់ប្រមាណនូវការវិវត្តនៃបទល្មើសនានាបន្តទៀត។ លោកជំទាវក៏បានសង្កត់ធ្ងន់ផងដែរថា ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រហូតមកដល់ពេលនេះ ប្រទេសកម្ពុជាមានស្ថានភាពនឹងនរ ហើយការងារនេះគឺជាការងាររួម រវាងអន្តរក្រសួងស្ថាប័ន និងអង្គការជាដៃគូទាំងថ្នាក់ជាតិ និងអន្តរជាតិ រួមទាំងកិច្ចសហការជាមួយបណ្តាប្រទេសនានា ដើម្បីកាត់បន្ថយនូវការរងគ្រោះរបស់ជនរងគ្រោះ និងដើម្បីឆ្ពោះទៅរកទស្សនវិស័យលុបបំបាត់នូវបទល្មើសតែម្តង។

គួរជម្រាបថា ផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ សម្រាប់ឆ្នាំ២០២៤-២០២៨ មានយុទ្ធសាស្ត្រចំនួនបួន រួមមាន៖ ១. ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា, ២. លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់ នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ, ៣. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និង ៤. បង្កើនកិច្ចការពារជនរងគ្រោះ ៕

## សហរដ្ឋអាមេរិកជំរុញឱ្យកម្ពុជាប្រយុទ្ធប្រឆាំងការជួញដូរមនុស្សឱ្យមានប្រសិទ្ធភាព

https://www.rfa.org/khmer/news/human-rights/us-urges-cambodian-authorities-to-step-up-fight-against-human-traffickers-11092023015214.html *ដោយ សេក បណ្ឌិត*2023.11.09

*មន្ត្រីសហរដ្ឋអាមេរិកជំរុញអាជ្ញាធរកម្ពុជា អនុវត្តវិធានការប្រយុទ្ធប្រឆាំងលើក្រុមឧក្រិដ្ឋជនជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព ស្របពេលអាមេរិកដាក់កម្ពុជាក្នុងចំណាត់ថ្នាក់អាក្រក់បំផុតនៃអំពើជួញដូរមនុស្ស។ មន្ត្រីសង្គមស៊ីវិលថា ការជំរុញជាថ្មីនេះ ដោយសារសហរដ្ឋអាមេរិកមើលឃើញថា កម្ពុជាមិនទាន់ឆ្លើយតបគ្រប់គ្រាន់ទៅនឹងបញ្ហាជួញដូរមនុស្ស។*

*ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជាលោក បាទ្រីក ម័រហ្វី* (Patrick Murphy) *សរសេរសារបង្ហោះនៅលើបណ្ដាញសង្គមអិច* (X) *អតីតបណ្ដាញសង្គមទ្វីតធឺ* (Twitter) *កាលពីថ្ងៃទី០៧ វិច្ឆិកា ថា លោកបានជួបពិភាក្សាជាមួយឧបនាយករដ្ឋមន្ត្រីលោក នេត សាវឿន។ នៅក្នុងជំនួបនោះ ភាគីទាំងពីរបានពិភាក្សាពីបញ្ហាឧក្រិដ្ឋកម្មឆ្លងដែន និងទទួលស្គាល់កិច្ចសហការរបស់ប្រទេសទាំងពីរក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការពារកុមារ។ លោកបន្តថា ក្នុងជំនួបនោះ លោកក៏ទទូចឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត នៃវិធានការប្រយុទ្ធប្រឆាំងក្រុមជួញដូរមនុស្ស ប្រតិបត្តិការឆបោកតាមអ៊ីនធឺណិត និងការការពារសិទ្ធិមនុស្ស។*

*វិទ្យុអាស៊ីសេរីមិនទាន់ទទួលបានការបកស្រាយបន្ថែមពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជាបាននៅថ្ងៃទី៨ វិច្ឆិកា។ ទោះជាយ៉ាងណាក៏ដោយ ការទទូចរបស់សហរដ្ឋអាមេរិកនេះ ធ្វើឡើងស្របពេលរដ្ឋាភិបាលកម្ពុជា តែងមិនទទួលស្គាល់របាយការណ៍របស់សហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិ ដែលលើកឡើងនាពេលកន្លងមកថា កម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលសម្បូរករណីជួញដូរមនុស្ស ដែលជាទង្វើរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដោយសារតែអាជ្ញាធរកម្ពុជាពុករលួយ។ មន្ត្រីរដ្ឋាភិបាលឆ្លើយតបទៅនឹងរបាយការណ៍ទាំងនោះ ថា ជាចេតនាធ្វើឱ្យកម្ពុជាបាក់មុខមាត់នៅលើឆាកអន្តរជាតិ ជាហេតុនាំឱ្យអ្នកវិនិយោគ និងអ្នកទេសចរបរទេស មិនហ៊ានធ្វើដំណើរមកកាន់កម្ពុជា។*

*អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង លើកឡើងនៅថ្ងៃទី៧ វិច្ឆិកាថា ការអះអាងថា អាជ្ញាធរកម្ពុជាពុំបានប្រឹងប្រែងឱ្យបានគ្រប់គ្រាន់ ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាការលើកឡើងខ្វះចន្លោះ និងសំអាងតែទៅតាមរបាយការណ៍ម្ខាងពីក្រុមអង្គការដៃគូរបស់អាមេរិក។ លោកស្រី ជូ ប៊ុនអេង៖ «ព័ត៌មាន ឬក៏លទ្ធផលដែលទទួលបានហ្នឹង គឺតាមរយៈអង្គការដៃគូ ដែលយើងដឹងហើយថា ធម្មតា អង្គការដៃគូ មិនបាន*

ធ្វើការគ្រប់គ្រងជ្រោយ ដូចរដ្ឋាភិបាលទេ។ ហើយប្រសិនបើគាត់រាយការណ៍ ប្រហែលនៅក្នុងចន្លោះណា ដែលគាត់បានមើលឃើញនៅក្នុង Project (គម្រោង)គាត់មួយៗហ្នឹង»។

ជាមួយគ្នានេះ កាលពីថ្ងៃទី០៧ វិច្ឆិកា លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត លើកឡើងនៅពេលចុះជួបក្រុមកម្មករថា អំឡុងពេលទៅទស្សនកិច្ចនៅរដ្ឋធានីប៉េកាំង កាលពីខែតុលា លោកបានខិតខំពន្យល់ទៅដល់អ្នកវិនិយោគចិន ឱ្យឈប់ភ័យខ្លាច ចំពោះបញ្ហាសន្តិសុខនៅកម្ពុជា បន្ទាប់ពីមានភាពយន្តចិនរឿង នូ ម៉រ បិត (No more bets) ដែលបានលាតត្រដាងពីការជួញដូរមនុស្សប្រមាណ១សែននាក់នៅកម្ពុជា។ លោក ហ៊ុន ម៉ាណែត បញ្ជាក់ថា លោកក៏បានពឹងក្រុមវិនិយោគិនចិនកំពុងរកស៊ីនៅស្រុកខ្មែរ ជួយពន្យល់បន្ថែមទៅដល់អ្នកវិនិយោគចិនផ្សេងទៀត ដែលមិនទាន់ចេញមករកស៊ីនៅស្រុកខ្មែរ។

លោក ហ៊ុន ម៉ាណែត៖ «បើគ្នាគេ(អ្នកវិនិយោគចិន)ដែលបានរស់នៅហ្នឹង គេមកប្រាប់ថាសុវត្ថិភាព អារឿងនោះ(ករណីជួញដូរមនុស្ស) វាមាន ប៉ុន្តែវាតូចតាច។ អារឿងនេះ! សុវត្ថិភាពទូទៅគាត់ទៅណាអីបាន គេមកច្រើនៗ បើថា ហេ! អំណោយផលរដ្ឋាភិបាលស្រុកខ្មែរ មានគោលការណ៍អនុគ្រោះច្រើន រឿងសេដ្ឋកិច្ចពិសេសអី យើងធ្វើតទៅទៀត គាត់ជឿទុកចិត្ត»។

ជុំវិញបញ្ហានេះ អ្នកនាំពាក្យសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) លោក ស៊ឹង សែនករុណា យល់ឃើញថា ការជំរុញជាថ្មីរបស់មន្ត្រីសហរដ្ឋអាមេរិកនេះ ដោយសារសហរដ្ឋអាមេរិកបន្តមើលឃើញថា អាជ្ញាធរកម្ពុជា មិនទាន់ឆ្លើយតបឱ្យបានគ្រប់គ្រាន់នៅឡើយ ជុំវិញការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា។ លោក ស៊ឹង សែនករុណា៖ «គេមើលឃើញពីការអនុវត្តហ្នឹង ហាក់ដូចជា មិនទាន់មានភាពឆ្លើយតបទៅនឹងអំពើបទល្មើស ឬក៏ឧក្រិដ្ឋហ្នឹងឱ្យបានគ្រប់គ្រាន់ ដែលគេអាចជឿទុកចិត្ត ឬគេអាចទទួលយកបានទេ។ អ៊ីចឹងហើយ បានមានការលើកឡើង ដើម្បីឱ្យមានការជំរុញ ក្នុងការទប់ស្កាត់ និងការពារកុំឱ្យករណីហ្នឹង ចេះតែបន្តកើតមានឡើងទៀត»។ មន្ត្រីសិទ្ធិមនុស្សរូបនេះ បន្តថា ប្រសិនរដ្ឋាភិបាលកម្ពុជា នៅតែមិនទទួលស្គាល់ការរកឃើញរបស់អង្គការសហប្រជាជាតិ និងសហរដ្ឋអាមេរិក ដូច្នេះ មិនអាចដោះស្រាយបញ្ហាជួញដូរមនុស្សឱ្យមានប្រសិទ្ធភាពឡើយ ហើយបញ្ហានេះ នឹងបន្តធ្វើឱ្យកម្ពុជាបាក់មុខនៅលើឆាកអន្តរជាតិថែមទៀត រួមទាំងត្រូវខាតបង់ពីវិស័យទេសចរណ៍ និងការវិនិយោគពីបរទេស៕

# សង្គមស៊ីវិល
# ចង់ឃើញតុលាការផ្តន្ទាទោសជនជាតិចិនចំនួន១០នាក់ករណីថតវីដេអូអាសអាភាស

https://www.rfa.org/khmer/news/social-economy/civil-society-wants-to-see-court-convict-10-chinese-for-producing-pornographic-videos-11102023074416.html ដោយ សេក បណ្ឌិត 2023.11.10

ក្រុមអង្គការសង្គមស៊ីវិល និងអ្នកច្បាប់គាំទ្រចំណាត់ការរបស់តុលាការក្រុងភ្នំពេញ ដែលសំរេចឃុំខ្លួនជនជាតិចិនចំនួន ១០នាក់ក្នុងរឿងលួចថត និងផលិតវីដេអូអាសអាសពាក់ព័ន្ធជាមួយស្ត្រីខ្មែរមួយចំនួននោះ។ ក៏ប៉ុន្តែអ្វីដែលក្រុមសង្គមស៊ីវិលព្រួយបារម្ភ គឺខ្លាចក្រែងតែតុលាការដោះលែង ឬក៏បន្ធូរបន្ថយទោសជនជាតិចិនទាំងនោះ បន្ទាប់ពីតុលាការចេញសាលក្រមកាត់ទោសរួចហើយ។ សង្គមស៊ីវិលថា នឹងតាមឃ្លាំមើលចំណាត់ការផ្លូវច្បាប់របស់តុលាការក្រុងភ្នំពេញទៅលើជនជាតិចិនចំនួន១០នាក់ ដែលពាក់ព័ន្ធនិងករណីថតរូបស្ត្រីខ្មែរនិងផលិតជាវីដេអូ អាសអាភាស។

ប្រធានសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) លោក នី សុខា មានប្រសាសន៍ថា អង្គការរបស់លោកនឹងតាមឃ្លាំមើលចំណាត់ការផ្លូវច្បាប់របស់តុលាការក្រុងភ្នំពេញទៅលើជនជាតិចិនទាំង១០នាក់នោះ ខ្លាចក្រែងបន្ទាប់ពីមានការដាក់ទោសរួចហើយ ប៉ុន្តែការអនុវត្តទោសធ្វើពុំបានត្រឹមត្រូវតាមច្បាប់។ លោក នី សុខា៖ «ពាក់ព័ន្ធទៅនឹងការថតរូបអាសអាភាសអីផ្សេងៗហ្នឹងគឺវាពាក់ព័ន្ធទៅដល់អំពើពេស្យាចារ ឬអនាចារ ពីព្រោះអានេះវាប្រើប្រាស់រូបភាពមួយចំនួនទាក់ទងផ្លូវភេទដល់ស្ត្រីអីចឹងវាអាចជាបទល្មើសឧក្រិដ្ឋ។ នៅពេលណាដែលសាលក្រមតុលាការសំរេចហើយគឺស្នើឱ្យមានការអនុវត្តន៍ទោសឱ្យបានត្រឹមត្រូវ មានន័យថាត្រូវគោរពច្បាប់ បើទោះបីជាចង់លើកលែងទោសអីក៏សូមអនុវត្តន៍ឱ្យស្របទៅតាមគោលការណ៍របស់ច្បាប់យើង»។

កាលពីថ្ងៃទី៣១ ខែតុលាចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញលោក លិ សុខា បានចេញដីកាឱ្យឃុំខ្លួនជនជាតិចិនចំនួន១០នាក់នៅពន្ធនាគារព្រៃសជាបណ្តោះអាសន្ន។ ជនជាតិចិនទាំង១០នាក់នោះត្រូវបានតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចោទប្រកាន់ពីបទមានស្ថានទម្ងន់ទោសនៃសញ្ចារកម្ម ការដឹកនាំពេស្យាចារ រូបភាពនិងសម្ភារអាសអាភាសតាមមាត្រា២៧ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ប្រធានមជ្ឈមណ្ឌលពលរដ្ឋ ដើម្បីអភិវឌ្ឍន៍ និងសន្តិភាព លោក យង់ គិមអេង ចង់ឃើញតុលាការក្រុងភ្នំពេញចាត់ការផ្លូវច្បាប់ ទៅលើជនជាតិចិនទាំង១០នាក់នោះ ដោយគ្មានការលើកលែងឬបន្ធូរបន្ថយទោស។ លោក យង់ គិមអេង៖ «ខ្ញុំយល់ថា រឿងដែលតុលាការសំរេចឃុំខ្លួនជន

ជាតិចិនគឺជារឿងល្អ ប៉ុន្តែសំខាន់បំផុតការដាក់ទោសទណ្ឌ គឺកុំឱ្យមានការបន្ធូរបន្ថយទោស ត្រូវផ្តន្ទាទោសឱ្យបានធ្ងន់ធ្ងរទៅតាមទង្វើដែលពួកគេបានប្រព្រឹត្ត។ បើសិនជាសាលក្រមដាក់ទោសគាត់រយៈពេល២០ឆ្នាំគឺត្រូវឱ្យគាត់នៅក្នុងគុក២០ឆ្នាំហ្នឹងទៅ កុំឱ្យមានការបន្ធូរបន្ថយទោសឬក៏លើកលែងទោស»។

សមត្ថកិច្ចកម្ពុជាកាលពីថ្ងៃទី២៤ តុលា បានចុះបង្ក្រាបករណីលួចផលិតវីដេអូអាសអាភាសក្នុងអគារខុនដូមួយកន្លែងឈ្មោះ វ៉ាវ ណាវ (Wow Now) ស្ថិតនៅក្នុងខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនជាតិចិន និងខ្មែរចំនួន៤៥នាក់។ ប៉ុន្តែក្រោយមកសមត្ថកិច្ចបានដោះលែងមនុស្សចំនួន៣៥នាក់វិញ ដោយអះអាងថា ពួកគេមិនមានជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសនោះទេ រីឯជនជាតិចំនួន១០នាក់ ក្នុងចំណោមនោះត្រូវបានតុលាការសម្រេចឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារ។

អ្នកជំនាញផ្នែកច្បាប់ និងជាមេធាវី លោក សុក សំអឿន ឱ្យដឹងថា យោងតាមការចោទប្រកាន់ពីបទស្ថានទម្ងន់ទោសនៃសញ្ញារកម្មការដឹកនាំពេស្យាចារ រូបភាពនិងសម្ភារអាសអាភាសតាមមាត្រា២៧មាត្រា២៩និងមាត្រា៣០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនោះជនល្មើសអាចជាប់ពន្ធនាគារពី ១៥ឆ្នាំឡើងទៅ ក៏ប៉ុន្តែស្ថានទម្ងន់ទោសអាចស្រាល ឬធ្ងន់ គឺវាអាស្រ័យលើការប្រព្រឹត្តបទល្មើសរបស់ពួកគេរៀងៗខ្លួន។ លោក សុក សំអឿន លើកឡើងថា កម្ពុជាមានច្បាប់សម្រាប់អនុវត្ត និងដាក់ទោសទណ្ឌទៅលើជនល្មើសស្រេចទៅហើយក៏ប៉ុន្តែអ្វីដែលលោកព្រួយបារម្ភគឺនៅត្រង់ថា តើការអនុវត្តច្បាប់ អាចធ្វើបានត្រឹមត្រូវ ឬក៏យ៉ាងណា? លោក សុក សំអឿន៖ «ខ្ញុំយល់ថាច្បាប់យើងមានស្រេចទៅហើយ មិនមែនសំខាន់ទៅលើការដាក់ទោសធ្ងន់ឬក៏មិនធ្ងន់នោះទេ សំខាន់នៅលើថា តើការអនុវត្តច្បាប់នោះរឹងមាំដែរឬក៏អត់? បើចង់ឱ្យរឹងមាំគឺពេលចិនចូលមកត្រូវឱ្យប៉ូលិសតាមដានបន្ថែម ក៏ប៉ុន្តែកន្លងមកយើងឃើញចិនៗឱ្យតែចូលមកស្រុកខ្មែរ អាងអ្នកធំ អាងអី ដល់អីចឹងវាមានបញ្ហាសម្រាប់អ្នកអនុវត្តន៍ច្បាប់ដែរ»។

ចំណែកអ្នកវិភាគឯករាជ្យ លោកបណ្ឌិត ឡៅ ម៉ុងហៃ មានប្រសាសន៍ថា លោកសូមលើកទឹកចិត្តដល់តុលាការកម្ពុជាក្នុងការអនុវត្តច្បាប់ប្រឆាំងនឹងជនបរទេស ដែលបានប្រព្រឹត្តខុសច្បាប់នៅកម្ពុជាក៏ប៉ុន្តែលោកចង់ឃើញការអនុវត្តច្បាប់នោះ ធ្វើឡើងឱ្យមានប្រសិទ្ធភាព និងត្រឹមត្រូវ។ បណ្ឌិត ឡៅ ម៉ុងហៃ៖ «ជាការល្អហើយដែលតុលាការសំរេចដាក់ទណ្ឌកម្មអីចឹង យើងអនុវត្តន៍ច្បាប់របស់ប្រទេសយើង ទៅលើជនជាតិបរទេសណាក៏ដោយឱ្យតែបានប្រព្រឹត្តបទល្មើសនៅលើទឹកដីខ្មែរ។ ប៉ុន្តែសុំកុំឱ្យតែបន្ធូរបន្ថយទោសតែប៉ុណ្ណឹង ពីព្រោះពាក់ព័ន្ធនិងស្ត្រីភេទគឺជាទោសធ្ងន់»។

ជុំវិញរឿងនេះ វិទ្យុអាស៊ីសេរីមិនអាចសុំការឆ្លើយតបពីអ្នកនាំពាក្យសាលាដំបូងរាជធានីភ្នំពេញ លោក អ៊ី រិទ្ធ បានទេ នៅថ្ងៃទី៨ វិច្ឆិកា។

ករណីសមត្ថកិច្ចឈានដល់ការចុះបង្ក្រាបឃាត់ខ្លួនមនុស្សចំនួន ៤៥នាក់ កាលពីថ្ងៃទី២៤ ខែតុលា គឺបន្ទាប់ពីស្ត្រីខ្មែរពីរនាក់ ដែលអះអាងថា ជាជនរងគ្រោះក្នុងសកម្មភាពថតរឿងអាសអាភាស បានដាក់ពាក្យបណ្ដឹង ក្រោយពីពួកគេបានឃើញវីដេអូរឿងអាសអាភាសរបស់ខ្លួន ដែលថតជាមួយជនបរទេសទាំងនោះត្រូវបែកធ្លាយនៅលើបណ្ដាញសង្គម (Facebook) និងប្រព័ន្ធតេឡេក្រាម (Telegram) ព្រមទាំងមានការចែកចាយតៗគ្នាជាច្រើនផង។

ស្របពេល ដែលរដ្ឋាភិបាលកម្ពុជាកំពុង មានទំនាក់ទំនងជិតស្និទ្ធជាមួយប្រទេសចិន លំហូរនៃជនបរទេសជាពិសេសជនជាតិចិនមកកម្ពុជា ក៏មានកាន់តែច្រើនឡើង ក្នុងនោះរួមមានទាំងអ្នកវិនិយោគ និងជនជាតិចិនដែលបង្កបទល្មើស ដែលនាំមកនូវបញ្ហាអសន្តិសុខដល់កម្ពុជាផងដែរ។ បទល្មើសដែលជនជាតិចិនប្រព្រឹត្តនៅកម្ពុជាមានដូចជាការចាប់ជំរិតមនុស្សទារប្រាក់តាមប្រព័ន្ធអនឡាញ ការឆបោក ការប្លន់ប្រដាប់អាវុធ ការបាញ់ប្រហារតាមទីសាធារណៈ ការជួញដូរគ្រឿងញៀន ឃាតកម្ម អំពើពេស្យាចារ អំពើហិង្សា និងចុងក្រោយនេះការថតវីដេអូអាសអាភាសជាដើម។

ទង្វើរបស់ជនជាតិចិនមួយចំនួននេះ កំពុងធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះនិងតំលៃវប្បធម៌របស់កម្ពុជា ថែមទាំងជាឧបសគ្គរាំងស្ទះសម្រាប់កម្ពុជាក្នុងការអូសទាញវិនិយោគិនបរទេសល្អៗ និងភ្ញៀវទេសចរណ៍ មិនចង់ចូលមកវិនិយោគនិងទស្សនាប្រទេសកម្ពុជា ដោយសារតែពួកគេខ្លាចរអានឹងបញ្ហាអសន្តិសុខនៅកម្ពុជា៕

## ពលករខ្មែរមួយចំនួន
## បង្ហាញការឈឺចាប់ក្រោយធ្វើការនៅថៃជាង២០ឆ្នាំ តែជីវភាពនៅតែខ្វះខាត

https://www.rfa.org/khmer/news/social-economy/some-cambodian-workers-worry-after-working-in-thailand-for-more-than-20-years-life-is-still-poor-11102023104222.html ដោយ ឡេង ម៉ាលី 2023.11.10

ពលករខ្មែរមួយចំនួន បង្ហាញការឈឺចាប់ ក្រោយពេលពួកគេទៅធ្វើការនៅប្រទេសថៃអស់រយៈពេលជាង២០ហើយ នៅតែមានជីវភាពខ្វះខាត ខណៈមានពលករខ្លះមិនបានទៅលេងស្រុកកំណើតជាច្រើនឆ្នាំមកហើយដោយសារតែគ្មានប្រាក់។ តើពលករទាំងនោះធ្វើការងារលំបាកនិងជួបបញ្ហាអ្វីខ្លះបានជាមានជីវភាពខ្វះខាតបែបនេះ? ក្រុមពលករខ្មែរទាំងនោះ ជាកម្មករធ្វើការងារស្របច្បាប់នៅប្រទេសថៃ។ ពួកគេលើកឡើងថា មិនចង់មកធ្វើការនៅប្រទេសមួយនេះនោះទេ ក៏ប៉ុន្តែ

ដោយសារគ្មានជម្រើស ព្រោះមានជីវភាពក្រីក្រ ហើយនៅក្នុងស្រុកគ្មានការងារធ្វើ និងពុំមានទីផ្សារលក់កសិផលក្នុងតម្លៃសមរម្យ។

បុរសសម្បុរស្រអែមមាឌក្រអាញអាយុ ៤៣ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ស្ពឺ លោក សុខ បាន ប្រាប់វិទ្យុអាស៊ីសេរីថា លោកមកធ្វើការងារនៅប្រទេសថៃអស់រយៈពេលជាង២០ឆ្នាំមកហើយ ដោយសារតែជីវភាពក្រីក្រ និងអត់ការងារធ្វើនៅកម្ពុជា។ ពលកររូបនេះធ្វើការងារផ្នែកបម្រើភ្ញៀវទេសចរនៅឆ្នេរសមុទ្រលើកោះមួយក្នុងខេត្តឈុនបូរី (Chunbori) ដែលមានចម្ងាយប្រមាណ ១០០គីឡូម៉ែត្រពីទីក្រុងបាងកក (Bangkok)។

លោក សុខ បាន រៀបរាប់ថា ទម្រាំតែលោកបានមកធ្វើការងារលើកោះមួយនេះ លោកត្រូវបានជនជាតិថៃនាំយកទៅលក់ឱ្យធ្វើការនៅលើទូកនេសាទថៃ នៅកណ្ដាលសមុទ្រ អស់រយៈពេលជាង១ខែរួចមកហើយ។ លោកថា ក្នុងពេលដែលលោកធ្វើការនៅទីនោះថៅកែជនជាតិថៃ ប្រើលោកនិងពលករខ្មែរប្រមាណ ១០នាក់ផ្សេងទៀតឱ្យធ្វើការងារលើទូកនេសាទស្ទើរតែពុំមានពេលសម្រាកហើយមិនផ្ដល់ប្រាក់ឈ្នួលឱ្យពួកលោកនោះទេ។ បន្ថែមពីនេះលោកថា លោកអាចនឹងត្រូវក្រុមជនជាតិថៃនៅលើទូកនោះសម្លាប់ចោលនៅកណ្ដាលសមុទ្រ ប្រសិនបើធ្លាក់ខ្លួនឈឺធ្វើការមិនកើត ព្រោះនៅលើទូកនោះមានក្រុមដើងកាងយាមការពារប្រដាប់ដោយកាំភ្លើងគ្រប់ដៃ។ លោកបន្តថា ដោយសារព្រួយបារម្ភពីសុវត្ថិភាព ថ្ងៃមួយលោកក៏ប្រថុយជីវិតលោតពីលើទូកនេសាទចូលទៅក្នុងកប៉ាល់របស់ឈ្មួញទិញត្រីជនជាតិថៃ ដែលមកទិញត្រីនៅតំបន់នោះ ដោយចូលទៅសំងំក្នុងទូទឹកកកដាក់ត្រីដើម្បីគេចខ្លួនត្រឡប់មកដីគោកវិញ។

លោក សុខ បាន៖ «ទាំងយប់ខ្ញុំលួចរត់ទាំងយប់តើ ខ្ញុំលោតពីគែមទូកខាងក្រោយចូលទៅកប៉ាល់ ទៅចូលក្នុងធុងត្រី ព្រោះកប៉ាល់វាមានធុងច្រើន ហើយមេការគេអត់ដឹងទេ ដឹងតែអ្នកធ្វើការជាមួយគ្នាទេ តែគេអត់ប្រាប់ទេ។អីចឹងដល់គេកប៉ាល់គេឡើងត្រីអស់អីចឹងក៏ចាប់ផ្ដើមចេញដំណើរមកថៃ ចេញមកថៃបានប្រហែលកន្លះម៉ោងឬមួយម៉ោងបានមេការដឹង។ ហើយវាដឹងអីចឹងវាឆ្ងាយដែរហើយវាតាមចង់ទៅយកខ្ញុំតើ បើតាមទៅយកវាបាញ់ខ្ញុំងាប់ហើយ។ ដល់អីចឹងវាឃើញឆ្ងាយដែរហើយប្រហែលមួយជាងហើយវាខ្ជិលតាម ខ្ញុំមកដល់ថៃគេចាប់ខ្ញុំយកលុយម្ដងទៀត គំរាមយកលុយទៀតវេទនាណាស់កាលមកថៃដំបូង»។

លោក សុខ បាន បន្តទៀតថា ក្រោយពីរត់គេចខ្លួនចេញពីទូកនេសាទរបស់ថៃបានហើយ លោកក៏បានធ្លាក់ខ្លួនឈឺ និងបានត្រឡប់ទៅព្យាបាលជំងឺនៅកម្ពុជាវិញអស់រយៈពេលប្រមាណ២ខែ។ លោកប្រាប់ថា ក្រោយមកលោកក៏សម្រេចចិត្តត្រឡប់ទៅធ្វើការនៅប្រទេសថៃជាលើកទី២ទៀតកាលពីឆ្នាំ២០០១ ហើយបានមកធ្វើការនៅលើកោះមួយក្នុងខេត្តឈុនបូរី រហូតមកទល់សព្វថ្ងៃ។

លោកថា អំឡុងពេលធ្វើការនៅលើកោះរយៈពេលប្រមាណ ៣ឆ្នាំដំបូងថៅកែជនជាតិថៃឱ្យប្រាក់ឈ្នួលប្រមាណ ៣ពាន់បាត ឬស្មើប្រមាណ១០០ដុល្លារក្នុងមួយខែ។ សព្វថ្ងៃនេះលោកធ្វើការងារបានប្រាក់ឈ្នួល និងលុយធីបដែលភ្ញៀវឱ្យផងបានចន្លោះពី ១ម៉ឺន ៥ពាន់ ទៅ២ម៉ឺនបាត(២០,០០០) ឬស្មើប្រមាណពី៤៦០ ទៅ ៦០០ដុល្លារក្នុងមួយខែ។ ប៉ុន្តែលោកថា ប្រាក់ឈ្នួលទាំងនេះមិនអាចធ្វើឱ្យជីវភាពរបស់លោកប្រសើរឡើងបាននោះទេ ព្រោះប្រាក់មួយចំនួនត្រូវបែងចែកទៅឱ្យឪពុកម្ដាយនៅកម្ពុជា និងមួយផ្នែកទៀតសម្រាប់ចាយវាយនៅប្រទេសថៃផង និងសន្សំដើម្បីទុកធ្វើឯកសារធ្វើការងារស្របច្បាប់ផង។

លោក សុខ បាន៖ «មិនមែនតែខ្ញុំមួយទេបង ខ្ញុំចង់ឱ្យរដ្ឋាភិបាលគាត់ជួយមើលបញ្ហាលិខិតឆ្លងដែន (Passport) ក៏ថ្លៃអ្នកខ្លះបង្ខំឱ្យគ្នាធ្វើ ដូចខ្ញុំអីចឹងជួនកាលធ្វើការពីរបីខែគ្រាន់តែបង់ថ្លៃលិខិតឆ្លងដែន នឹងថៅកែកាត់អស់ដដែលហ្នឹងវាថ្លៃពេក។ ថ្នាក់ដឹកនាំយើងមើលខ្មែរយើងដូចថាប្រទេសមួយនឹងគេដែរគឺថាអត់មានសិទ្ធិសេរីភាពអត់អីចឹង គេអត់គោរពសិទ្ធិ គេរំលោភសិទ្ធិមកលើយើងអីចឹង ខ្ញុំវាតូចចិតដែរ យើងជាខ្មែរម្នាក់ដែរ ជាមនុស្សម្នាក់ ហើយគេមើលមកដូចសត្វដូចជាតុ។ គេរំលោភសិទ្ធិដូចថាគេអត់ឱ្យសិទ្ធិសេរីភាពយើងគេចង់វាយយើងគេចង់ធ្វើបាប ទោះបីជាយើងត្រូវក៏ដូចខុសស្រេចតែគេចោទប្រកាន់យើងអីចឹងអត់មានអ្នកការពារសិទ្ធិសេរីភាពយើងខ្មែរយើង»។

ស្រដៀងគ្នានេះដែរ ពលករវ័យ ៤៥ឆ្នាំ មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ លោក ចង ឈុន ថ្លែងថា លោកមកធ្វើការនៅប្រទេសថៃអស់រយៈពេលជាង៣០ឆ្នាំហើយ ក៏ប៉ុន្តែជីវភាពគ្រួសាររបស់លោកនៅតែក្រីក្រ និងមានជីវភាពកាន់តែដុនដាប។ លោកប្រាប់ថា សព្វថ្ងៃនេះលោកធ្វើការសំណង់នៅខេត្តរ៉ាក់យ៉ង (Rayong) ជាមួយប្រពន្ធនិងមានកូន៤នាក់ ប៉ុន្តែកូន៣នាក់រស់នៅជាមួយលោកក្នុងប្រទេសថៃ ចំណែកកូនប្រុសម្នាក់ទៀតអាយុ ១១ឆ្នាំរស់នៅជាមួយយាយនៅខេត្តបន្ទាយមានជ័យ។ លោកបន្តថា សព្វថ្ងៃនេះការងាររបស់លោកមិនទៀងទាត់នោះទេ ដោយក្នុងមួយខែលោកធ្វើការពីរនាក់ប្រពន្ធបានប្រាក់ឈ្នួលប្រមាណ ២ម៉ឺនបាត ឬស្មើប្រមាណ៦០០ដុល្លារប៉ុណ្ណោះ។ លោកបញ្ជាក់ថា ប្រាក់ឈ្នួលទាំងនោះស្ទើរតែមិនគ្រប់សម្រាប់ដោះស្រាយជីវភាពនោះទេ ព្រោះលោកមានសមាជិកគ្រួសារដល់ទៅ៦នាក់ ខណៈដែលកូនរបស់លោកនៅតូចមិនទាន់ធ្វើការងារអ្វីបាននៅឡើយទេ។ លោកថា ជីវភាពលំបាកខ្លាំងនៅពេលធ្វើលិខិតឆ្លងដែននិងបន្តសុពលភាពទិដ្ឋាការ ដែលត្រូវចំណាយប្រាក់អស់ច្រើនដើម្បីធ្វើឯកសារស្របច្បាប់។ លោកបន្ថែមថា ដោយសារតែធ្វើការបានប្រាក់ឈ្នួលតិចតួចនេះហើយ ទើបលោកសម្រេចចិត្តមិនទៅលេងកម្ពុជាអស់រយៈពេល៤ឆ្នាំមកហើយ ដោយសារគ្មានប្រាក់ធ្វើដំណើរ។

លោក ថង ឈុននៈ «ធ្វើម៉េចបានបង ទី១ ដូចខ្ញុំនិយាយអីចឹងឯង ណាផ្ញើឱ្យកូននៅផ្ទះផង ហូបខ្លួនឯងផង ថ្លៃលិខិតឆ្លងដែនផង ដល់ខែគេៗ គេចេះតែកាត់លុយយកពីយើង តែលិខិតឆ្លងដែនក៏មិនបាន។ យើងធ្វើដំណើរក៏លំបាក យើងធ្វើដំណើរអ្នកអត់លិខិតឆ្លងដែនម្នាក់ជាង៥ពាន់បាតទៅខ្មែរ ឡើងមក អ្នកអត់លិខិតឆ្លងដែនសុទ្ធតែ ៦ ទៅ ៧ពាន់បាត ដល់អ៊ីចឹងយើងស៊ូអត់ទៅវាមិនល្អជាង បើទៅមានតែជំពាក់គេទៀតពេលឡើងមក។ និយាយតាមត្រង់តែម្ដងគ្មានសល់ទេ បានតែម៉ារស់ ហើយមានតែជំពាក់គេថែម ខ្លះណាក៏ជំពាក់ស្ថាប័នមីក្រូហិរញ្ញវត្ថុទៅ បើអ្នកធ្វើការជាមួយខ្ញុំភាគច្រើនជំពាក់ស្ថាប័នមីក្រូហិរញ្ញវត្ថុ សឹងតែគ្រប់គ្នាបណ្ដោយ»។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការងារ លោក កត្តា អន ដើម្បីសាកសួរជុំវិញពីទុក្ខលំបាករបស់ពលករខ្មែរទាំងនេះបានទេនៅថ្ងៃទី៩ វិច្ឆិកា។

ប៉ុន្តែកាលពីថ្ងៃទី១ ខែកញ្ញា លោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត មានប្រសាសន៍ថា កន្លងទៅមន្ត្រីរបស់លោកដែលប្រចាំការនៅក្រៅប្រទេស ជាពិសេសនៅប្រទេសថៃ (Thailand) កូរ៉េខាងត្បូង (South Korea) ជប៉ុន (Japan) និងម៉ាឡេស៊ី (Malaysia) បានយកចិត្តទុកដាក់ចំពោះសុខទុក្ខពលករខ្មែរចំណាកស្រុកតាមរយៈការអន្តរាគមន៍ផ្តល់ជំនួយផ្លូវច្បាប់ ម្ហូបអាហារ និងផ្តល់សេវាផ្សេងទៀត។

លោក ហ៊ុន ម៉ាណែត៖ «កន្លងទៅយើងចរចានៅទីផ្សារការងារជាមួយជប៉ុន កូរ៉េ ជាមួយកាណាដា និងប្រទេសផ្សេងទៀត ដើម្បីឱ្យបងប្អូនមានឱកាស គឺមិនមែនជាការបង្ខិតបង្ខំនោះទេ បងប្អូនរបស់យើងដែលចេញទៅធ្វើការនៅក្រៅប្រទេស គឺយើងមានទូត ទីប្រឹក្សាពលករ ទីប្រឹក្សាការងារនៅតាមស្ថានទូត ហើយប្រទេសមួយចំនួនដែលមានប្រជាពលករច្រើន យើងគិតដើម្បីបង្កើនចំនួនបន្ថែមទៀតនៃទីប្រឹក្សាការងារដើម្បីឱ្យពួកគាត់អាចចុះជួប»។

កាលពីថ្ងៃទី១៣ កញ្ញា កន្លងទៅរដ្ឋាភិបាលលោក ហ៊ុន ម៉ាណែត ក៏បានបង្កើតគណៈកម្មការត្រួតពិនិត្យនិងដោះស្រាយបញ្ហាចេញចូលរបស់ពលករខ្មែរនៅតាមព្រំដែន ដើម្បីសម្រួលដល់ការធ្វើដំណើរចេញចូលកម្ពុជា និងថៃរបស់ពលករខ្មែរ ដោយពុំមានការយកប្រាក់ក្រៅផ្លូវការ។ ទោះជាយ៉ាងណាក្រុមពលករខ្មែរលើកឡើងថា គណៈកម្មការនេះមិនបានជួយអ្វីដល់ពួកគេដែលកំពុងមានបញ្ហាជីវភាពនៅប្រទេសថៃបានឡើយ។

ជុំវិញរឿងនេះ ប្រធានផ្នែកប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ នៃអង្គការសង់ត្រាល់ (Central) លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា ពលករខ្មែរនៅប្រទេសថៃដែលប្រឈមនឹងការបោកប្រាស់កម្លាំងពលកម្មនិងពិបាករកប្រាក់ចំណូលមាន៣ផ្នែកគឺ អ្នកធ្វើការងារផ្នែកសំណង់ ធ្វើការងារនៅលើទូកនេសាទ និងធ្វើការផ្នែកកសិកម្មនៅតាមស្រែចម្ការ។ លោកបញ្ជាក់ថា បញ្ហាទាំងនេះកើតឡើង ដោយសារតែរដ្ឋាភិបាលខ្មែរមិនសូវយកចិត្តទុកដាក់ជួយអន្តរាគមន៍ផ្នែក

ច្បាប់ និងមិនបានជួយអន្តរាគមន៍ទៅអាជ្ញាធរថៃឱ្យបានទាន់ពេលវេលា។ លោក ឌី ថេហ្វូយ៉ា៖ «ដូចខ្ញុំបានលើកអ៊ីចឹង វិស័យបីបួននឹងដែលរងគ្រោះជាងគេ ហើយក៏មិនទាន់ទទួលបានការដោះស្រាយពីរដ្ឋនៅឡើយ។ ហើយក៏យើងមើលឃើញការខិតខំប្រឹងប្រែងរបស់រដ្ឋនឹងជាទូទៅមិនបានប្រឹងប្រែងដោះស្រាយបញ្ហាទាំងអស់នោះទេ ។ ប្រឹងប្រែងរឿងអីផ្សេងដែលមិនតម្រូវការរបស់ពលករដែលធ្វើការនៅក្នុងប្រទេសថៃក្នុងវិស័យបីបួននឹង»។

របាយការណ៍អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការស្របច្បាប់និងមិនស្របច្បាប់ជាង២លាននាក់នៅប្រទេសថៃ។ ក្នុងចំណោមពលករទាំងនោះមានអ្នកខ្លះត្រូវបានថៅកែបោកប្រាស់កម្លាំងពលកម្ម ដោយធ្វើការមិនបើកប្រាក់ឈ្នួលឱ្យ និងខ្លះទៀតត្រូវបានថៅកែវាយធ្វើបាបនិងប្ដឹងទៅសមត្ថកិច្ចថៃឱ្យចាប់ដាក់ពន្ធនាគារក៏មានដែរ។

មន្ត្រីសង្គមស៊ីវិលលើកឡើងថា ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលកម្ពុជាគួរតែអន្តរាគមន៍ទៅរដ្ឋាភិបាលថៃឱ្យសម្រួលធ្វើឯកសារស្របច្បាប់ដល់ពលករទាំងនោះឱ្យបានឆាប់ និងក្នុងតម្លៃថោក។ទី២រដ្ឋាភិបាលត្រូវតាមដានការអនុវត្តច្បាប់របស់ថៅកែថៃមកលើពលករខ្មែរដើម្បីកុំឱ្យពួកគេកេងប្រវ័ញ្ចកម្លាំងលើពលករ និងទី៣រដ្ឋាភិបាលក៏គួរផ្សព្វផ្សាយអប់រំណែនាំដល់ពលករឱ្យចេះសន្សំសំចៃដើម្បីមានប្រាក់សល់ខ្លះផ្ញើទៅឱ្យគ្រួសារនៅកម្ពុជា៕

# ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ២០២៣

## ការផ្សព្វផ្សាយព័ត៌មាន
## ជួញដូរមនុស្សមិនច្បាស់លាស់ ប៉ះពាល់កំណើនទេសចរ វិនិយោគិនបរទេស

https://www.kampucheathmey.com/local-news/611327 ថ្ងៃចន្ទ ១៣ វិច្ឆិកា ២០២៣ KC Virak

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ ដែលបានស្រាវជ្រាវ ឬរកឃើញករណីអ្វីមួយពាក់ព័ន្ធបញ្ហាអំពើជួញដូរមនុស្ស ហើយបានចងក្រងជាឯកសារ ឬធ្វើជារបាយការណ៍ សូមផ្ញើទៅកាន់ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងដោះស្រាយរួមគ្នា ចៀសជាងយកទៅផ្សព្វផ្សាយ ធ្វើឱ្យប៉ះពាល់ដល់កំណើន នៃភ្ញៀវទេសចរបរទេស ក៏ដូចជាអ្នកវិនិយោគពីក្រៅប្រទេសជាដើម។

ថ្ងៃបើកសិក្ខាសាលាស្តីពី ការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០១៩-២០២៣) និងបង្កើតផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ (២០២៤-២០២៨) ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាថ្ងៃទី១៣ វិច្ឆិកានេះ នៅទីស្តីការក្រសួងមហាផ្ទៃ លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា បច្ចុប្បន្ននេះទម្រង់ នៃអំពើជួញដូរមនុស្ស ដែលកើតឡើងថ្មីមានភាពខុសប្លែកពីមុន ខណៈពីមុនការ

ទំនាក់ទំនងទាក់ទាញជនរងគ្រោះ ទៅក្នុងអំពើជួញដូរមនុស្ស ពីសំណាក់មេខ្យល់ គឺបានជួបផ្ទាល់ ប៉ុន្តែបច្ចុប្បន្ននេះគឺទាក់ទងតាមប្រព័ន្ធអនឡាញដែលអាចធ្វើឡើងឆ្លងប្រទេសបានថែមទៀតក៏មាន។

លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍បន្តថា ទម្រង់ នៃការទាក់ទាញជនរងគ្រោះ គឺមានភាព ជឿនលឿន មានការពិបាកគ្រប់គ្រង ហើយការបង្ក្រាបនេះទៀតសោត ក៏មានផលលំបាកផងដែរ ពាក់ព័ន្ធនឹងភាសា នៃជនល្មើសប្រើប្រាស់ ហើយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏គ្រោងដាក់នូវសំណើ នៃការបណ្តុះបណ្តាលផ្នែកភាសាមួយចំនួន ទៅក្នុងផែនការយុទ្ធសាស្ត្រ នេះ។ បន្ថែមពីលើនេះ លោកស្រី ជូ ប៊ុនអេង រំពឹងថា ធាតុចូលថ្មីៗ ដែលនឹងដាក់ចូលក្នុងផែនការ យុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ ទៅមុខទៀតនោះ នឹងជួយបង្កើនប្រសិទ្ធភាព នៃការទប់ស្កាត់ និង បង្ក្រាបអំពើជួញដូរមនុស្សនៅកម្ពុជា ជាពិសេសបទល្មើសកើតឡើងក្នុងទម្រង់ថ្មីៗ។

គួរបញ្ជាក់ថា ផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ សម្រាប់ឆ្នាំ២០២៤-២០២៨ មានយុទ្ធសាស្ត្រចំនួន បួន រួមមាន៖ ១. ពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និង បទដ្ឋានគតិយុត្តិនានា, ២. លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់ នៃអំពើជួញដូរមនុស្ស និងការ រំលោភបំពានផ្លូវភេទលើកុមារ, ៣. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរ មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និង ៤. បង្កើនកិច្ចការពារជនរងគ្រោះ៕ **អត្ថបទ៖ សំអឿន**

## មន្ត្រីក្រសួងមហាផ្ទៃ៖
## ការប្រឆាំងការជួញដូរមនុស្ស ទាមទារការរួមគ្នារវាងអន្តរស្ថាប័ន និងសហការប្រទេសនានា

https://www.kampucheathmey.com/local-news/611330 ថ្ងៃចន្ទ ១៣ វិច្ឆិកា ២០២៣ដោយ Thoeun Vansong

ការប្រឆាំងការជួញដូរមនុស្ស ទាមទារការរួមសហការគ្នារវាងអន្តរក្រសួង-ស្ថាប័ន និងអង្គការ ជាដៃគូ ព្រមទាំងកិច្ចសហប្រតិបត្តិជាមួយបណ្តាប្រទេសនានា ដើម្បីឈានឆ្ពោះទៅរកទស្សនវិស័យ លុបបំបាត់បទល្មើសជួញដូរមនុស្ស។ នេះជាការអះអាងរបស់លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ថ្ងៃក្នុងសិក្ខាសាលាថ្នាក់ជាតិ វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០១៩-២០២៣) នាថ្ងៃទី១៣ ខែវិច្ឆិកានេះ លោកស្រី ជូ ប៊ុនអេង បានសង្កត់ធ្ងន់ថា ពាក់ព័ន្ធនឹងការងារ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រហូតមកដល់ពេលនេះ ប្រទេសកម្ពុជាមានស្ថានភាពនឹងនរ ហើយការងារនេះ គឺជាការងាររួមរវាងអន្តរក្រសួង-ស្ថាប័ន និងអង្គការជាដៃគូ ទាំងជាតិ និងអន្តរ

ជាតិ រួមទាំងកិច្ចសហការជាមួយបណ្តាប្រទេសនានា ដើម្បីកាត់បន្ថយការរងគ្រោះរបស់ជនរងគ្រោះ និងឈានឆ្ពោះទៅរកទស្សនវិស័យលុបបំបាត់នូវបទល្មើសតែម្តង។

ចំពោះសិក្ខាសាលានាពេលនេះ ត្រូវបានលោកស្រីរដ្ឋលេខាធិការ ជូ ប៊ុនអេង បញ្ជាក់ថា គឺជាកិច្ចប្រជុំក្បាលម៉ាស៊ីនថ្នាក់ជាតិ ដើម្បីវាយតម្លៃលើចំណុចខ្វះខាត ចន្លោះប្រហោងនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ (២០១៩-២០២៣) ក៏ដូចជាពិភាក្សាប្រមូលធាតុចូល និងទិន្នន័យពីអ្នកពាក់ព័ន្ធទាំងអស់ ដែលជាសមាជិកនៃគណៈកម្មាធិការជាតិ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំបន្ត (២០២៤-២០២៨)។ លោកស្រី បន្តថា ការប្រមូលព័ត៌មាន និងធាតុចូលពីអ្នកអនុវត្តផ្ទាល់ និងអ្នកអនុវត្តសកម្មលើការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រនេះ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ជាព័ត៌មានមូលដ្ឋាន ដោយពួកគាត់ជាអ្នកចុះផ្ទាល់ជាមួយស្ថាប័នពាក់ព័ន្ធ ចុះតាមសហគមន៍ ដើម្បីប្រមូលមតិពីជនរងគ្រោះ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស សង្ឃឹម និងជឿជាក់ថា តាមរយៈកិច្ចប្រជុំនាថ្ងៃនេះ នឹងផ្តល់ជាទិន្នន័យ ធាតុចូល និងព័ត៌មានខុសៗគ្នា ដើម្បីយកមកបញ្ចូលគ្នាសម្រាប់កំណត់នូវចំណុចជាអាទិភាពក្នុងផែនការ៥ឆ្នាំទៅមុខ ក៏ដូចជារួមគ្នាប៉ាន់ប្រមាណការវិវត្តនៃបទល្មើសនានាបន្តទៀត។

គួរជម្រាបថា ផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ សម្រាប់ឆ្នាំ២០២៤-២០២៨ មានយុទ្ធសាស្ត្រចំនួន ៤ រួមមាន៖ ១.ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការកសាង និងអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា, ២.លើកកម្ពស់ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ, ៣.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និង ៤.បង្កើនកិច្ចការពារជនរងគ្រោះ៕

# ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ២០២៣

## ឯកអគ្គរដ្ឋទូតគោចរអាមេរិកនឹងពិភាក្សា<br>ជាមួយរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធការជួញដូរមនុស្សនិងអំពើឆបោកតាមអ៊ីនធឺណិត

https://khmer.voanews.com/a/us-ambassador-at-large-to-discuss-with-cambodian-government-on-human-trafficking-and-cyber-scams/7357712.html ១៦ វិច្ឆិកា ២០២៣ស៊ឹម ចាន់សំណាង

ភ្នំពេញ៖ ឯកអគ្គរដ្ឋទូតគោចរសហរដ្ឋអាមេរិកទទួលបន្ទុកតាមដាន និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស អ្នកស្រី Cindy Dyer កំពុងធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសកម្ពុជា ដើម្បីពិភាក្សាអំពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងក្នុងតំបន់។ នេះបើតាមសេចក្តីប្រកាស

ព័ត៌មានរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក។ ការមកបំពេញទស្សកិច្ចរបស់មន្ត្រីការទូតអាមេរិកជាន់ខ្ពស់រូបនេះ កើតមានឡើង បន្ទាប់ពីមានសេចក្តីរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ និងរបាយការណ៍នានា បង្ហាញអំពីអំពើឆបោកតាមអនឡាញ និងការបង្ខាំងមនុស្សដែលបានកើតឡើងនៅកម្ពុជា។

យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ក្រសួងការបរទេសអាមេរិក ចេញផ្សាយកាលពីថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ អ្នកស្រី Cindy Dyer នឹងស្នាក់នៅប្រទេសកម្ពុជាចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី ១៧ ខែវិច្ឆិកា។ ក្នុងសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសអាមេរិកចេញផ្សាយកាលពីថ្ងៃពុធ មន្ត្រីការទូតជាន់ខ្ពស់របស់សហរដ្ឋអាមេរិករូបនោះ គ្រោងជួបពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាលកម្ពុជាជាច្រើនរូប រួមមានក្រសួងយុត្តិធម៌ ក្រសួងការងារ ក្រសួងសង្គមកិច្ច នគរបាលជាតិ និងគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស (NCCT) និងភាគីពាក់ព័ន្ធផ្សេងទៀត ក្នុងគោលបំណងកសាងទំនាក់ទំនងជាមួយរដ្ឋាភិបាលថ្មីសម្រាប់ការសម្របសម្រួលនាពេលអនាគត និងការតស៊ូមតិសម្រាប់វឌ្ឍនភាពក្នុងវិស័យសំខាន់ៗ រួមទាំងការបង្កើនការស៊ើបអង្កេត និងការផ្តន្ទាទោសលើប្រតិបត្តិការបោកប្រាស់តាមបណ្តាញអ៊ីនធឺណិតជាដើម។ អ្នកស្រី Cindy Dyer ក៏នឹងចូលរួមកិច្ចពិភាក្សាជាមួយអង្គការសង្គមស៊ីវិល ដែលធ្វើការលើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សផងដែរ។

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសអាមេរិកបានលើកឡើងថា៖ «កិច្ចពិភាក្សានឹងផ្តោតលើកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការការពារជនរងគ្រោះពីការជួញដូរ រួមទាំងការផ្តល់សេវាជំនួយការពារដល់ជនរងគ្រោះនៃការជួញដូរ និងជនចំណាកស្រុក ដែលងាយរងគ្រោះ ការកសាងសមត្ថភាពសម្រាប់អ្នកផ្តល់សេវា និងមន្ត្រីរដ្ឋាភិបាល ដើម្បីកែលម្អអត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូនបន្ត និងការដោះស្រាយនិន្នាការដែលកំពុងលេចឡើងនៃឧក្រិដ្ឋកម្មដោយបង្ខំ»។

នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការការពារសិទ្ធិមនុស្សលីកាដូ លោក អំ សំអាត ប្រាប់វីអូអេថា ទស្សនកិច្ចរបស់អ្នកស្រី Cindy Dyer នៅប្រទេសកម្ពុជា នឹងរួមចំណែកដល់ការដោះស្រាយបញ្ហានៃការជួញដូរមនុស្ស និងការឆបោកតាមប្រព័ន្ធអនឡាញ ក្រោយសហរដ្ឋអាមេរិកបានដាក់កម្ពុជានៅចំណាត់ថ្នាក់លេខ៣ក្នុងបញ្ជីខ្មៅ ស្តីពីការជួញដូរមនុស្សដ៏សម្បើមមួយ។ ការណ៍នេះបានជះឥទ្ធិពលជាអវិជ្ជមានមកលើមុខមាត់ប្រទេសកម្ពុជាលើឆាកអន្តរជាតិ។ លោកថ្លែងថា៖ «យើងឃើញហើយថា សហរដ្ឋអាមេរិកដែលដាក់ចំណាត់ថ្នាក់កម្ពុជាក្នុងចំណាត់ថ្នាក់លេខ ៣ ដែលក្នុងបញ្ជីខ្មៅ នៃការជួញដូរមនុស្សហ្នឹង វាធ្វើឲ្យមានការប៉ះពាល់ច្រើនដែរសម្រាប់កម្ពុជាយើង ហើយប្រសិនជាកម្ពុជាយើងមិនបានខិតខំបន្ថែមទៀត នៅក្នុងការទប់ស្កាត់ការជួញដូរមនុស្ស ឬការឆបោកតាមប្រព័ន្ធអនឡាញទេ ហ្នឹងវាមិនអាចឡើងចំណាត់ថ្នាក់បាន»។

បើតាមលោក អំ សំអាត ស្ថានភាពនៃការជួញដូរមនុស្ស និងករណីឆបោកតាមប្រព័ន្ធអនឡាញនៅតែបន្តកើតមានក្នុងប្រទេសកម្ពុជា ដោយមានរបាយការណ៍ជាច្រើនរួមមានរបាយការណ៍របស់អង្គការសហប្រជាជាតិផងដែរ។ លោកស្នើឲ្យរដ្ឋាភិបាលពង្រឹងសមត្ថភាពរបស់មន្ត្រី និងអាជ្ញាធរទទួលបន្ទុកបង្ក្រាបបទល្មើសតាមប្រព័ន្ធអនឡាញ ដោយសារតែករណីនៃការឆបោកផ្សេងៗបានកំពុងលេចឡើងជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ។ លោកថ្លែងថា៖ «បញ្ហាបទល្មើសនេះវាទំនើបកម្មតាមប្រព័ន្ធបច្ចេកវិទ្យា អ៊ីចឹងអាជ្ញាធរដែលពាក់ព័ន្ធនៅក្នុងរឿងហ្នឹងគឺត្រូវតែទទួលបានការបណ្ដុះបណ្ដាលបន្ថែម ដើម្បីឲ្យវត់តាមសភាពការណ៍ ក៏ដូចជាការកំណត់នៃបទល្មើសឲ្យទាន់ពេលវេលា»។

អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិលោក ឆាយ គឹមខឿន និងអ្នកនាំពាក្យក្រសួងយុត្តិធម៌លោក ជិន ម៉ាលីន បដិសេធផ្ដល់ការអត្ថាធិប្បាយ ដោយបានបង្វែរសំណួរទៅអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង។ វីអូអេមិនអាចទាក់ទងសុំការធ្វើអត្ថាធិប្បាយពីអ្នកស្រី ជូ ប៊ុនអេង បានទេ នៅថ្ងៃព្រហស្បតិ៍នេះ។

អ្នកនាំពាក្យស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា អ្នកស្រី Katherine M. Diop ប្រាប់វីអូអេតាមសារអ៊ីមែលថា ការមកបំពេញការងារការទូតរបស់អ្នកស្រី Cindy Dyer ក្នុងប្រទេសកម្ពុជា បានបង្ហាញពីផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងបន្តរបស់អាមេរិកក្នុងភាពជា ដៃគូជាមួយអ្នកពាក់ព័ន្ធនានាក្នុងប្រទេសកម្ពុជា និងជុំវិញពិភពលោក ដើម្បីលើកទឹកចិត្តរដ្ឋាភិបាលឲ្យទទួលខុសត្រូវលើការទប់ស្កាត់អំពើអ្នកជួញដូរមនុស្ស និងការពារជនរងគ្រោះ។ អ្នកស្រីបន្តថា អ្នកស្រីឯកអគ្គរដ្ឋទូតគោចរ Dyer កំពុងតែជួបពិភាក្សាផ្ទាល់ជាមួយមន្ត្រីជាន់ខ្ពស់មកពីក្រសួង ស្ថាប័ននានា រួមទាំងគណៈកម្មាធិការជាតិប្រឆាំងការជួញដូរមនុស្ស (NCCT) ផងដែរ។ អ្នកស្រី Katherine M.Diop លើកឡើងតាមសារអ៊ីមែលជាភាសាអង់គ្លេស និងត្រូវបានប្រែសម្រួលជាខេមរភាសាថា៖ «សហរដ្ឋអាមេរិកនៅជាមួយប្រជាជនកម្ពុជាក្នុងការកំណត់អត្តសញ្ញាណ គាំទ្រ និងស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះដោយការជួញដូរមនុស្ស»។

របាយការណ៍របស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ដែលចេញផ្សាយកាលពីចុងខែសីហា ឆ្នាំ២០២៣ បានឲ្យដឹងថា នៅក្នុងប្រទេសកម្ពុជាមនុស្សប្រមាណជា ១០ម៉ឺននាក់ ត្រូវបានបង្ខំឲ្យធ្វើការងារឆបោកតាមប្រព័ន្ធអនឡាញនៅក្នុងប្រទេសកម្ពុជា។ ហើយករណីឆបោកតាមប្រព័ន្ធអនឡាញនេះ ក៏បានកើតឡើងនៅក្នុងប្រទេសចំនួន៥ ក្នុងតំបន់អាស៊ីអាគ្នេយ៍រួមមានកម្ពុជា ថៃ ឡាវ មីយ៉ាន់ម៉ា និងហ្វីលីពីន ដោយករណីជនរងគ្រោះនៃការឆបោកតាមប្រព័ន្ធអនឡាញទាំងនោះ បានប្រឈមនឹងការគំរាមកំហែង និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដោយពួកគេ

ទទួលរងការធ្វើទារុណកម្មយ៉ាងឃោរឃៅ អំពើអមនុស្សធម៌ ថោកទាប ការឃុំខ្លួនដោយបំពាន អំពើហិង្សាផ្លូវភេទ ពលកម្មដោយបង្ខំ និងការរំលោភសិទ្ធិមនុស្សផ្សេងៗទៀត។

ដោយឡែក របាយការណ៍ប្រចាំឆ្នាំ ពីការជួញដូរមនុស្សនៅទូទាំងពិភពលោក របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកគិតត្រឹមខែមិថុនា ឆ្នាំ២០២៣ បានបង្ហាញថា កម្ពុជាកំពុងស្ថិតនៅក្នុងកម្រិតបី (Tier 3) ដែលជាចំណាត់ថ្នាក់ទាបបំផុតមួយ និងមានន័យថា រដ្ឋាភិបាលកម្ពុជាមិនបានខិតខំធ្វើការកែលម្អលើបញ្ហាការជួញដូរមនុស្ស ហើយមិនបានបំពេញតាមបទដ្ឋានអប្បបរមាដូចដែលបានកំណត់។

## រដ្ឋមន្ត្រីក្រសួងការងារ ស្នើឱ្យរាជរដ្ឋាភិបាលអារ៉ាប៊ីសាអូឌីត ពង្រីកទីផ្សារការងារ

https://freshnewsasia.com/index.php/en/localnews/317995-2023-11-16-11-55-01.html 2023-11-16 06:55pm

**(ភ្នំពេញ)៖** លោក ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃព្រហស្បតិ៍ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ បានស្នើឱ្យព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ពង្រីកវិសាលភាពទីផ្សារការងារជាមួយកម្ពុជា។ នេះ គឺជាការលើកឡើងរបស់ លោករដ្ឋមន្ត្រីក្នុងជំនួបផ្លូវការជាមួយនឹង លោក Mohammed Ismaeil A. Dahlwy ឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីតនៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងជំនួបប្រកបដោយភាពរីករាយ លោករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា ការពង្រីកទីផ្សារការងារពីវិស័យអតិពលកម្មទៅវិស័យដែលប្រើប្រាស់កម្លាំងជំនាញនឹងមានភាពទាក់ទាញសម្រាប់ពលរដ្ឋកម្ពុជាផង។

ជាការឆ្លើយតប ឯកអគ្គរាជទូតអារ៉ាប៊ីសាអូឌីត បានទទួលយកសំណើររបស់ឯកឧត្តមរដ្ឋមន្ត្រី ហើយថានឹងបញ្ជូនសំណើរនេះទៅកាន់រដ្ឋាភិបាលរបស់ខ្លួនដើម្បីពិចារណា និងសម្រេច។

សូមបញ្ជាក់ថា ក្រៅពីបញ្ហាសំខាន់ខាងលើ ភាគីទាំងពីរ ក៏បានពិភាក្សាពីទំនាក់ទំនងរវាងប្រទេសទាំងពីរ ដែលកាន់តែស្អិតរមួត និងរីកចម្រើនជំជាត់ជាបន្តទៀត បន្ទាប់ពីព្រះរាជាណាចក្រទាំងពីរ បានចុះអនុស្សរណៈយោគយល់គ្នា លើការបញ្ជូនពលករបម្រើការងារតាមផ្ទះកាលពីឆ្នាំ២០១៦។ ក្នុងជំនួបពិភាក្សាប្រកបដោយភាពរីករាយ លោករដ្ឋមន្ត្រី បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលអារ៉ាប៊ីសាអូឌីត ដែលបានមើលថែរក្សាពលរដ្ឋកម្ពុជាដែលកំពុងបម្រើការងារនៅទឹកដីអារ៉ាប៊ីសាអូឌីតផងដែរ។

យ៉ាងណាក៏ដោយមុននឹងបញ្ចប់ភាគីទាំងពីរ បានប្តេជ្ញាជំរុញទំនាក់ទំនងប្រទេសទាំងពីរលើវិស័យការងារឱ្យកាន់តែស្អិតរមួតបន្ថែមទៀតតាមរយៈទំនាក់ទំនងរវាងប្រជាជននិងប្រជាជន។

# ដំណើរការប្រព័ន្ធទំនាក់ទំនង
# ទាន់ហេតុការណ៍ ដើម្បីដោះស្រាយបញ្ហាពលករខ្មែរចេញចូលតាមព្រំដែន

https://kohsantepheapdaily.com.kh/article/1835500.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ១៧ ខែ វិច្ឆិកា ឆ្នាំ ២០២៣ ម៉ោង ០៩:៣៩

រាជធានីភ្នំពេញ ៖ គណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរតាមព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា (គ.ច.ព.ក) បានដាក់ឱ្យដំណើរការប្រព័ន្ធទំនាក់ទំនងទាន់ហេតុការណ៍ ដើម្បីដោះស្រាយបញ្ហាពលករខ្មែរចេញ-ចូលតាមព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា។

យោងតាមសេចក្តីជូនដំណឹង ស្តីពីការដាក់ឱ្យដំណើរការប្រព័ន្ធទំនាក់ទំនងទាន់ហេតុការណ៍ ដើម្បីដោះស្រាយបញ្ហាពលករខ្មែរចេញ-ចូលតាមព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា របស់គណៈកម្មការចំពោះកិច្ចត្រួតពិនិត្យ និងដោះស្រាយបញ្ហាដំណើរចេញ-ចូលរបស់ពលករខ្មែរ តាមព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា (គ.ច.ព.ក) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់សាធារណជន ឬពលករខ្មែរ ដែលធ្វើដំណើរចេញចូលតាមច្រកព្រំដែនទាំងអស់ មេត្តាជ្រាបថា គណៈកម្មការ គ.ច.ព.ក បានរៀបចំប្រព័ន្ធទំនាក់ទំនងទាន់ហេតុការណ៍ ដែលមានមធ្យោបាយសម្រាប់ទំនាក់ទំនងដូចជា ៖ លេខទូរស័ព្ទ Hotline ៖ ១២៤៤ (ដោយឥតគិតថ្លៃ) ។ តេលេក្រាម (Telegram) ៖ ០៩៧ ៥៥៥ ១២៤៤ ។

ប្រភពខាងលើបានលើកឡើងថា អាស្រ័យហេតុដូចនេះ ចំពោះសាធារណជន ឬបងប្អូនពលករខ្មែរទាំងឡាយ ដែលមានបំណងចង់ផ្តល់ព័ត៌មាន ឬសំណូមពរផ្សេងៗ ពាក់ព័ន្ធនឹងភាពមិនប្រក្រតីក្នុងពេលធ្វើដំណើរចេញ ចូល និងឆ្លងកាត់ព្រំដែនកម្ពុជា សូមទាក់ទងមកគណៈកម្ម ការ គ.ច.ព.ក តាមប្រព័ន្ធទំនាក់ទំនងទាន់ហេតុការណ៍ខាងលើនេះ។

# ថ្ងៃទី២១ ខែ វិច្ឆិកា ឆ្នាំ២០២៣

## លោកជំទាវ ជូ ប៊ុនអេង
## អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំការិយាល័យត្រួតពិនិត្យ និងប្រយុទ្ធប្រឆាំង ការជួញដូរមនុស្សនៅក្រសួងការបរទេសសហរដ្ឋអាមេរិក ចូលជួបពិភាក្សាការងារ

https://www.hotnews-asia.com/detail/228920 *ចេញផ្សាយ ថ្ងៃទី 17 ខែ វិច្ឆិកា ឆ្នាំ 2023*

***ភ្នំពេញ៖*** *នាព្រឹកថ្ងៃសុក្រ ទី១៧ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានអនុញ្ញាតឱ្យលោកស្រី ស៊ិនឌី ដាយ័រ* (Ms. Cindy Dyer, Ambassador at Large) *ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំការិយាល័យត្រួតពិនិត្យ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្រសួងការបរទេសសហរដ្ឋអាមេរិក និងជាអ្នកទទួលបន្ទុកសរសេររបាយការណ៍វាយតម្លៃប្រចាំឆ្នាំ ព្រមទាំងសហការី ចូលជួបពិភាក្សាការងារ នាទីស្តីការក្រសួងមហាផ្ទៃ។*

*ក្នុងជំនួបរវាង គណៈប្រតិភូសហរដ្ឋអាមេរិក ដឹកនាំដោយលោកស្រី ស៊ិនឌី ដាយ័រ* (Ms. Cindy Dyer, Ambassador at Large) *ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំការិយាល័យត្រួតពិនិត្យ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្រសួងការបរទេសសហរដ្ឋអាមេរិក និងជាអ្នកទទួលបន្ទុកសរសេររបាយការណ៍វាយតម្លៃប្រចាំឆ្នាំ និងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលដឹកនាំដោយ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ គឺជាជំហាននៃការរីកចម្រើនក្នុងកិច្ចសហប្រតិបត្តិការរវាងសហរដ្ឋអាមេរិក និងកម្ពុជា ក្នុងបរិបទការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។*

*ផ្អែកលើរបាយការណ៍ លោកជំទាវ ជូ ប៊ុនអេង បានធ្វើសេចក្តីរាយការណ៍ អំពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាសេនាធិការ និងជាយន្តការអន្តរក្រសួង ស្ថាប័ន និងបើកទូលាយ ក្នុងកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន និងបានទទួលលទ្ធផលគួរឱ្យកត់សម្គាល់។*

*លោកស្រី ស៊ិនឌី ដាយ័រ បានវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ឱកាសឱ្យលោកស្រីបានមកជួបពិភាក្សាដោយផ្ទាល់ ជាមួយក្រសួង ស្ថាប័នជំនាញសំខាន់ៗ និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលធ្វើឱ្យលោកស្រីយល់កាន់តែច្បាស់ អំពីស្ថានភាពពិតនៅកម្ពុជា។ មុននឹងមកដល់កម្ពុជា លោកស្រីបានជួបពិភាក្សា និងសិក្សាស្វែងយល់ពីប្រទេសមួយចំនួន ដែលលោកស្រីកត់សម្គាល់ឃើញថា ភាពប្រឈមនឹងបទល្មើសជួញដូរមនុស្សតាមប្រព័ន្ធអនឡាញនេះមានភាពស្មុគ្រស្មាញ ប្រហាក់ប្រហែលគ្នា។ ហើយលោកស្រីក៏ទទួលស្គាល់ថា នេះជាបទល្មើសបែបថ្មី ដែលប៉ះពាល់ទៅគ្រប់ប្រទេស មិនមែនតែកម្ពុជានោះទេ។ បន្ទាប់មកលោកស្រី ប្រធានគណៈ*

ប្រតិភូអាមេរិក បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការបើកទូលាយឱ្យមានកិច្ចសហការ ដើម្បីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ លោកស្រីបានសន្យាថានឹងពិនិត្យឡើងវិញនូវការវាយតម្លៃដែលធ្វើឡើងកន្លងមកនេះ និងខិតខំបន្តប្រមូលទិន្នន័យឱ្យបានពេញលេញ។

ចុងបញ្ចប់នៃកិច្ចពិភាក្សា រវាងគណៈប្រតិភូទាំងពីរបានឯកភាពគ្នា ថាកិច្ចសហការរវាងប្រទេសពាក់ព័ន្ធគឺជាកត្តាចាំបាច់ ដើម្បីឆ្លើយតបបញ្ហារួមនេះ ហើយក៏ត្រូវមានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្នុងការអនុវត្តទៅដល់សមត្ថកិច្ចគ្រប់ផ្នែកដែលពាក់ព័ន្ធ ដើម្បីយល់ដឹង និងសហការគ្នាកាន់តែល្អប្រសើរ លើការកំណត់អត្តសញ្ញាណ ការបង្ក្រាប សង្គ្រោះ ការផ្តន្ទាទោស ការផ្តល់សេវា និងសមាហរណកម្មជនរងគ្រោះ ឱ្យបានកាន់តែល្អប្រសើរ ៕

## មន្ត្រីអាមេរិក វាយតម្លៃខ្ពស់ ចំពោះកម្ពុជា ដែល បើកទូលាយនូវកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://www.kampucheathmey.com/local-news/614382 ថ្ងៃសៅរ៍ ១៨ វិច្ឆិកា ២០២៣ដោយ Thoeun Vansong

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំការិយាល័យត្រួតពិនិត្យ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្រសួងការបរទេសអាមេរិក បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកម្ពុជា ដែលបានបើកទូលាយឱ្យមានកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ការលើកឡើងរបស់មន្ត្រីជាន់ខ្ពស់អាមេរិកនេះ ក្នុងជំនួបការងារជាមួយលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នាថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣។

ក្នុងជំនួបរវាងគណៈប្រតិភូសហរដ្ឋអាមេរិក ដឹកនាំដោយលោកស្រី ស៊ិនឌី ដាយ័រ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំការិយាល័យត្រួតពិនិត្យ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្រសួងការបរទេសសហរដ្ឋអាមេរិក និងជាអ្នកទទួលបន្ទុកសរសេររបាយការណ៍វាយតម្លៃប្រចាំឆ្នាំ និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដឹកនាំដោយលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺជាជំហាននៃការរីកចម្រើនក្នុងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-អាមេរិក ក្នុងបរិបទការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

នៅចំពោះគណៈប្រតិភូអាមេរិក, លោកស្រី ជូ ប៊ុនអេង បានបង្ហាញការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាសេនាធិ

ការ និងជាយន្តការអន្តរក្រសួង-ស្ថាប័ន បានបើកទូលាយសម្រាប់កិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន រហូតទទួលបានលទ្ធផលគួរឱ្យកត់ សម្គាល់។

ជាកិច្ចឆ្លើយតប លោកស្រី ស៊ិនឌី ដាយ៉ែរ បានវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ឱកាសឱ្យលោកស្រីបានមកជួបពិភាក្សាដោយផ្ទាល់ ជាមួយក្រសួង-ស្ថាប័នជំនាញសំខាន់ៗ និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដែលធ្វើឱ្យលោកស្រីបានយល់កាន់តែច្បាស់អំពីស្ថានភាពពិតនៅកម្ពុជា។

លោកស្រី បានបញ្ជាក់ថា មុននឹងមកដល់កម្ពុជា លោកស្រីបានជួបពិភាក្សា និងសិក្សាស្វែងយល់ពីប្រទេសមួយចំនួន ដោយលោកស្រី បានកត់សម្គាល់ឃើញថា ភាពប្រឈមនឹងបទល្មើសជួញដូរមនុស្សតាមប្រព័ន្ធអនឡាញនេះ មានភាពស្មុគ្រស្មាញ និងប្រហាក់ប្រហែលគ្នា ហើយលោកស្រី ក៏ទទួលស្គាល់ថា នេះជាបទល្មើសបែបថ្មី ដែលប៉ះពាល់ទៅគ្រប់ប្រទេស មិនមែនតែកម្ពុជានោះទេ។ លោកស្រីប្រធានគណៈប្រតិភូអាមេរិក ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការបើកទូលាយឱ្យមានកិច្ចសហការ ដើម្បីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយលោកស្រី បានសន្យាថា នឹងពិនិត្យឡើងវិញនូវការវាយតម្លៃដែលធ្វើឡើងកន្លងមក និងខិតខំបន្តប្រមូលទិន្នន័យឱ្យបានពេញលេញថែមទៀត។

ជារួម ភាគីទាំងពីរ បានឯកភាពគ្នាថា កិច្ចសហការរវាងប្រទេសពាក់ព័ន្ធ គឺជាកត្តាចាំបាច់ដើម្បីឆ្លើយតបបញ្ហារួមនេះ ហើយក៏ត្រូវមានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពក្នុងការអនុវត្តទៅដល់សមត្ថកិច្ចគ្រប់ផ្នែកដែលពាក់ព័ន្ធឱ្យបានយល់ដឹង និងសហការគ្នាកាន់តែល្អប្រសើរលើការកំណត់អត្តសញ្ញាណ ការបង្ក្រាប សង្គ្រោះ ការផ្តន្ទាទោស ការផ្តល់សេវា និងសមាហរណកម្មជនរងគ្រោះឱ្យបានកាន់តែល្អប្រសើរ៕

## ១០ខែនេះ កម្ពុជាបានផ្តល់ការងារជូនពលរដ្ឋទៅធ្វើការនៅក្រៅប្រទេសជាង៥ម៉ឺននាក់

https://www.kampucheathmey.com/local-news/614576 ថ្ងៃសៅរ៍ ១៨ វិច្ឆិកា ២០២៣

ដោយ Sokhom Khon

នៅក្នុងរយៈពេល១០ខែ ឆ្នាំ២០២៣នេះ កម្ពុជាបានផ្តល់ឱកាសការងារជូនប្រជាពលរដ្ឋទៅធ្វើការនៅក្រៅប្រទេសប្រមាណជាង៥ម៉ឺននាក់ ដែលបានជួយលើកស្ទួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក៏ដូចជាសេដ្ឋកិច្ចជាតិកាន់តែប្រសើរឡើងថែមទៀត។

លោក កត្តា អ៊ន អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍នៅព្រឹកថ្ងៃទី១៨វិច្ឆិកានេះថា ចាប់ពីខែមករារហូតមកដល់ខែតុលា ឆ្នាំ២០២៣ កម្ពុជាបានផ្តល់ឱ

*កាសការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋចំនួន៥០៧៩៨នាក់ ស្រី២១២៣៣នាក់ ក្នុងនោះរួមមានប្រទេសថៃ មានចំនួន ៣៦ ២៨៤នាក់ ស្រី ១៦ ១៤៧នាក់សាធារណរដ្ឋកូរ៉េ មានចំនួន ៨ ២២៤ នាក់ ស្រី ២ ៣០៣នាក់ ប្រទេសជប៉ុន មានចំនួន ៦ ២១៩នាក់ ស្រី ២ ៧១២នាក់ ប្រទេសម៉ាឡេស៊ី មានចំនួន ០០នាក់ ស្រី ០០នាក់ ប្រទេសសិង្ហបុរី មានចំនួន ៣០នាក់ ស្រី ៣០នាក់ តំបន់រដ្ឋបាលពិសេសហុងកុង មានចំនួន ៣នាក់ ស្រី ៣នាក់ និង ព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត មានចំនួន ៣៨នាក់ ស្រី ៣៨នាក់។*

*លោក កត្តា អ៊ិន បានបញ្ជាក់ថា គិតត្រឹមខែតុលា ឆ្នាំ២០២៣ កម្ពុជាបានផ្ដល់ឱកាសការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋបានចំនួន ១ ៣៥២៤៧៨នាក់ ស្រីចំនួន ៥៥១ ១៧០នាក់ ក្នុងនោះរួមមាន៖ ប្រទេសថៃ មានចំនួន ១ ២៥៦ ២៩៤នាក់ ស្រី ៥០៦ ០២១នាក់ សាធារណរដ្ឋកូរ៉េ មានចំនួន ៥១ ១៣៦នាក់ ស្រី ១២ ៤៣៣នាក់ ប្រទេសជប៉ុន មានចំនួន ២១ ៣៤៤នាក់ ស្រី ៩ ៩៣០ នាក់ ប្រទេសម៉ាឡេស៊ី មានចំនួន ២២ ៥៧២នាក់ ស្រី ២១ ៦៥៤នាក់ ប្រទេសសិង្ហបុរី មានចំនួន ៨៦៩ នាក់ ស្រី ៨៦៩ នាក់តំបន់រដ្ឋបាលពិសេសហុងកុង មានចំនួន ២១៦ នាក់ ស្រី២១៦នាក់ និង ព្រះរាជាណាចក្រអារ៉ាប់ប៊ីសាអូឌីត មានចំនួន៤៧ នាក់ ស្រី៤៧នាក់។ លោកបានបន្តទៀតថា ពលករទាំងនោះទៅធ្វើការផ្នែកកសិកម្មឧស្សាហកម្ម សំណង់ ការងារផ្ទះ និងការងារផ្សេងៗដោយពួកគេផ្ញើប្រាក់ត្រឡប់មកប្រទេសកម្ពុជាវិញជិត៣ពាន់លានដុល្លារ។*

*បើតាមលោក កត្តា អ៊ិន ពលករទៅធ្វើការនៅប្រទេសថៃជាមធ្យមទទួលបានប្រាក់ខែ ៤០០ ដុល្លារ ក្នុង១ខែ ប្រទេសម៉ាឡេស៊ីទទួលបានប្រាក់ខែ ៣៤០ ដុល្លារ ប្រទេសអារ៉ាប៊ីសាអូឌីតទទួលបានប្រាក់ខែ ៤០០ ដុល្លារ ប្រទេសជប៉ុនទទួលបានប្រាក់ខែ ១៤០០ ដុល្លារ ប្រទេសសិង្ហបុរីទទួលបានប្រាក់ខែ ៥០០ ដុល្លារ កូរ៉េខាងត្បូងទទួលបានប្រាក់ខែ ១៥០០ ដុល្លារ និងតំបន់សេដ្ឋកិច្ចពិសេសហុងកុងទទួលបានប្រាក់ខែ ៥៩១ដុល្លារក្នុង១ខែ។ អត្ថបទ៖ សំអឿន*

# ថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០២៣

## អង្គការលីកាដូថាការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារឡឥដ្ឋនៅតែបន្តមាន

https://www.rfi.fr/km//20231120?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 20/11/2023 - 12:08

*អង្គការការពារសិទ្ធិមនុស្សលីកាដូ រកឃើញថាការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅតែបន្តរីករាលដាលនៅតាមសិប្បកម្មផលិតឥដ្ឋក្នុងប្រទេសកម្ពុជា ដែលបញ្ហានេះអង្គការសង្គមស៊ីវិលនេះ បានបន្ទោសទៅលើភាពអសកម្មរបស់អាជ្ញាធរ និងវិស័យសំណង់ ដែល*

បណ្ដាយឲ្យមានការរំលោភសិទ្ធិមនុស្សបែបនេះនៅតែបន្ត។ ក៏ប៉ុន្តែរដ្ឋាភិបាលថាខ្លួនបានប្រឹងប្រែងធ្វើការងារនេះ ហើយរកមិនឃើញបញ្ហាបញ្ចាំខ្លួនដោះបំណុល ឬពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរនោះទេ។

នៅក្នុងរបាយការណ៍ ដែលមានឈ្មោះថា «ចំណងក្នុងឡឥដ្ឋ៖ ឱកាសដើម្បីបញ្ចប់ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅសិប្បកម្មឡឥដ្ឋនៅកម្ពុជា» អង្គការលីកាដូបានលើកឡើងពីការចងក្រងព័ត៌មានរបស់ខ្លួនទាក់ទងទៅនឹងសិប្បកម្មផលិតឥដ្ឋចំនួន ២១ទីតាំង នៅខេត្តកណ្ដាល និងរាជធានីភ្នំពេញ។ នៅក្នុងនោះក៏រួមមានកិច្ចសម្ភាសជាមួយកម្មករចំនួន១០នាក់ដែលបង្ហាញថាការបញ្ចាំខ្លួនដោះបំណុលនៅតែកើតមាន ហើយក្មេងអាយុត្រឹម៩ឆ្នាំ ក៏ត្រូវបានរកឃើញថានៅតែបន្តអនុញ្ញាតឲ្យធ្វើការក្នុងឡឥដ្ឋ។ នេះបើតាមអង្គការលីកាដូ។ របាយការណ៍បន្តរំលេចថា មានការផ្ទេរកម្លាំងពលកម្មចេញពីឡឥដ្ឋទៅកាន់ឧស្សាហកម្មផ្សេងទៀត ឬត្រូវបានបង្ខាំងរង់ចាំដោយមិនទទួលបានប្រាក់ឈ្នួល នៅក្នុងសិប្បកម្មដែលគ្មានប្រតិបត្តិការ បន្ទាប់ពីវិស័យអចលនទ្រព្យ និងសំណង់មានការថមថយ។ កម្មករមួយចំនួនតូចត្រូវបានដោះលែងឲ្យរួចពីពលកម្មដើម្បីដោះបំណុល ដោយបំណុលទាំងអស់ត្រូវបានលុបចោល ដែលករណីនេះជាការឆ្លើយតបចាំបាច់ជាបន្ទាន់នៅក្នុងឧស្សាហកម្មនេះ។

លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូបានលើកឡើងថា ការជំពាក់បំណុលរបស់កម្មករសិប្បកម្មឡឥដ្ឋជាមួយម្ចាស់សិប្បកម្ម គឺជាឧទាហរណ៍ទូទៅនៃការបញ្ចាំខ្លួនដោះបំណុល ដែលជាអំពើខុសច្បាប់ ហើយបំណុលទាំងអស់នោះត្រូវតែលុបចោលជាបន្ទាន់។ លោក អំ សំអាត បញ្ជាក់ថាក្មេងអាយុក្រោម១៨ឆ្នាំ មិនគួរធ្វើការផ្លូវការ ឬមិនផ្លូវការនៅសិប្បកម្មផលិតឥដ្ឋដែលប្រកបដោយគ្រោះថ្នាក់នោះទេ។

អ្នកនាំពាក្យក្រសួងការងារលោក កត្តា អ៊ន បានឆ្លើយតបជុំវិញបញ្ហានេះដែរថា រដ្ឋាភិបាល តាមរយៈក្រសួងការងារតែងយកចិត្តទុកដាក់ខ្ពស់ ចំពោះការអនុវត្តន៍ច្បាប់ការងារឲ្យមានប្រសិទ្ធភាពនៅគ្រប់រោងចក្រ សហគ្រាស សិប្បកម្ម និងស្ថាប័នសាធារណៈ និងឯកជនដែលស្ថិតក្រោមច្បាប់ស្ដីពីការងារ។ អ្នកនាំពាក្យរូបនេះរៀបរាប់ថាគិតចាប់តាំងពីឆ្នាំ២០២១ មកទល់នឹង៩ខែឆ្នាំ២០២៣នេះ ក្រសួងការងារបានប្រឹងប្រែងក្នុងការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលក្នុងនោះមាន ការចុះធ្វើអធិការកិច្ចដោយមិនជូនដំណឹងនៅតាមវិស័យអាទិភាពនិងមានហានិភ័យខ្ពស់ ដូចជាវិស័យកាត់ដេរ សិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្មដោយផ្ដោតទៅលើការពង្រឹងការអនុវត្តន៍ច្បាប់ និងទប់ស្កាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ រួមទាំងការងារដោយបង្ខំ ជាពិសេសទាសភាពបំណុល។

លោក កត្តា អ៊ិន បញ្ជាក់ថា ក្រសួងការងារបានធ្វើអធិការកិច្ចសរុប ៣៩៣លើកដោយពិនិត្យឃើញថាគ្មានការប្រើប្រាស់ពលកម្មកុមារ និងទាសភាពបំណុលទេ។ ក្រៅពីនេះ ក្រសួងការងារក៏បានបង្ហាញពីការប្រឹងប្រែងរបស់ខ្លួនជាច្រើនទៀត ក្នុងការទប់ស្កាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដោយមានការបញ្ជាក់ថានឹងធ្វើការស៊ើបអង្កេតក្នុងករណីសង្ស័យម្ចាស់ ឬនាយករោងចក្រ សហគ្រាស សិប្បកម្ម ដែលមានប្រើប្រាស់ពលកម្មកុមារ ឬទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលល្មើសច្បាប់ស្ដីពីការងារនឹងត្រូវទទួលរងការផាកពិន័យ ឬអាចឈានទៅបិទអាជីវកម្ម ឬអាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ។

ក៏ប៉ុន្តែអ្នកនាង ណាលី ពីឡូក នាយិការទទួលបន្ទុកកិច្ចការក្រៅតំបន់នៃអង្គការលីកាដូ បញ្ជាក់ថារដ្ឋាភិបាលអនុញ្ញាតឲ្យមានការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ បន្តមានយ៉ាងជាក់ច្បាស់ ដោយអ្នកនាងចាត់ទុកថាការចុះអធិការកិច្ចរបស់អាជ្ញាធររដ្ឋជាការសម្ដែង និងជាការប្រឹងប្រែងបែបអវិជ្ជមាន។៕

## ស្នងការដ្ឋាននគរបាលខេត្តព្រៃវែង
## បន្តពង្រឹងកិច្ចសហការជាមួយអង្គការ IGM ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

https://www.hotnews-asia.com/detail/229923 ចេញផ្សាយ ថ្ងៃទី 20 ខែ វិច្ឆិកា ឆ្នាំ 2023

***ភ្នំពេញ៖*** នៅថ្ងៃចន្ទ ៨កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០២៣ លោក ឧត្តមសេនីយ៍ទោ ឈឿន ប៊ុនធន ស្នងការនគរបាលខេត្តព្រៃវែង បានដឹកនាំលោកស្រី ស្នងការរង លោកនាយការិយាល័យ លោក-លោកស្រី នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ទទួលជួបសំណេះសំណាល និងពិភាក្សាការងារជាមួយប្រតិភូអង្គការ IGM នៅសាលប្រជុំនគរភ្នំ នៃស្នងការដ្ឋាននគរបាលខេត្ត។

នាឱកាសនោះ ភាគីទាំងពីរ បានសំណេះសំណាល ចែករំលែកបទពិសោធន៍ និងបន្តពង្រឹងកិច្ចសហការលើកិច្ចការងារ បង្ការទប់ស្កាត់ការជួញដូរមនុស្ស, ការជួញដូរកម្លាំងពលកម្មកុមារ, ការកេញប្រវ័ញ្ចកុមារតាមផ្ទះ ឬតាមក្រុមហ៊ុន សហគ្រាស។ បន្តកិច្ចសហការ ស្រាវជ្រាវបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីក្រៅប្រទេស ដែលខាងកម្ពុជាបានបង្ក្រាប ដោយសហការជាមួយខាងជំនាញអន្តោប្រវេសន៍ ឬសន្តិសុខរហូតទទួលបានជោគជ័យ, បន្តកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងប្រទេស និងឆ្លងដែន និងបន្តកិច្ចសហការបណ្តុះបណ្តាលផ្នែកជំនាញ ដល់មន្ត្រីនគរបាលជាតិបន្ថែមទៀតផងដែរ ៕

# កម្លាំងនាយកដ្ឋានប្រឆាំងបទល្មើសការជួញដូរមនុស្ស ចុះបង្ក្រាបហាងម៉ាស្សា លក់កាហ្វេមួយកន្លែង និងឃាត់ខ្លួនស្ត្រីម្នាក់ច្រឡំរួចប្រើប្រាស់ហិង្សាបណ្តាលឲ្យរងរបួស

https://cen.com.kh/archives/713980.html Posted ByPen Srey Neat November 21, 2023

ភ្នំពេញ ៖ ហាងម៉ាស្សា និងលក់ការហ្វេរយីហោ៩៩មួយកន្លែង ត្រូវបានកម្លាំងនាយកដ្ឋានប្រឆាំងបទល្មើសការជួញដូរមនុស្ស និងការពារអនីតិជន បានចុះឆ្មក់បង្ក្រាប និងឃាត់ខ្លួនស្ត្រីជាអ្នកលក់កាហ្វេម្នាក់ច្រឡំ រួចបានប្រើប្រាស់ហិង្សា បណ្តាលឲ្យរងរបួស ផ្អើលពលរដ្ឋក្នុងភូមិប្រមូលគ្នាជួយអន្តរាគមន៍ភ្លាមៗ។ ហេតុការណ៍ខាងលើនេះ ដែរបង្កឲ្យមានការភ្ញាក់ផ្អើលកាលពីវេលាម៉ោង១០និង៣០នាទីយប់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ថិតនៅលើផ្លូវ៨០កែង និងផ្លូវព្រះស៊ីសុវត្ថិសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

បើយោងតាមការបញ្ជាក់ពីស្ត្រីម្នាក់ឃើញហេតុការណ៍ខាងលើ បានប្រាប់ឲ្យដឹងថា នៅវេលាម៉ោងប្រមាណជា១០ និង៣០នាទីយប់ ដោយនារីជាអ្នកបម្រើការងារនៅក្នុងហាងម៉ាស្សា និងលក់កាហ្វេយីហោ៩៩ម្នាក់ បានទិញកាហ្វេពីស្ត្រីរងគ្រោះ ក្រោយមកស្ត្រីរងគ្រោះរូបនោះ ក៏បានកាន់កាហ្វេមួយថង់យកទៅឲ្យ នារីម៉ាស្សាដល់ខាងមុខហាង ពេលនោះដែរក៏មានជនស៊ីវិលមួយក្រុមមានគ្នា៤នាក់ រួមមានម៉ូតូមួយគ្រឿងនិងរថយន្តមួយគ្រឿងទៀត មិនស្គាល់ម៉ាក ក៏ចុះមកឃាត់ស្ត្រីខាងលើរួមទាំងនារីម៉ាស្សារ រុញចូលទៅក្នុងហាងបន្ទាប់មកដោយស្ត្រីជាអ្នកលក់កាហ្វេ គាត់មិនមានពាក់ព័ន្ធនោះទេ ក៏មានការប្រតាយប្រតប់ធ្វើឲ្យកម្លាំងជំនាញម្នាក់ បានវាយទៅលើស្ត្រីរងគ្រោះបណ្តាលឲ្យរងរបួសត្រង់ក្បាល រួចចាក់សោរជាប់នៅក្នុងហាង ហើយឡើងរថយន្តជិះគេចខ្លួនទៅបាត់ស្រមោល ក្រោយមកទៀតក៏ឃើញមានខាងកម្លាំងនាយកដ្ឋានប្រឆាំងបទល្មើសការជួញដូរមនុស្ស ចុះមកទីតាំងកើតហេតុបន្តផងដែរ។

គួរបញ្ជាក់ផងដែរថា នៅក្នុងការចុះបង្ក្រាបទីតាំងហាងម៉ាស្សា និងលក់កាហ្វេយីហោ៩៩ខាងលើនេះ មានការចូលរួម

ទី១ -ស៊ិន មុនី ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ទី២-លោកវរៈសេនីយ៍ឯក សំពិសិដ្ឋ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិង ការពារអនីតិជន

ទី៣-លោក វរៈសេនីយ៍ទោ ហង្សពិសិដ្ឋ ការិយាល័យរង

ទី៣-លោកវរៈសេនីយ៍ទោ ត្រាវ ដារ័ត្ន នាយរងការិយាល័យ(អ្នកកត់ត្រា)

ទី៤-លោក វរៈនីយ៍ទោ ម៉ម សារិទ្ធ រងការិយាល័យ

ទី៥-លោកទេព សុវាត្តិ ជាក្រឡាបញ្ជី

ទី៦- វរៈនីយ៍ទោ គង់សារ៉ាត់ នាយផ្នែក

*ទី៧-អនុសេនីយ៍ឯក អ៊ុយ ច័ន្ទ រីទ្ធី នាយរងផ្នែក*

*ទី៨- លោកសុខស៊ីណេត មន្ត្រីសាលាសង្កាត់ស្រះចក*

*បច្ចុប្បន្នកម្លាំងនាយកដ្ឋានប្រឆាំងបទល្មើសការជួញដូរមនុស្ស និងការពារអនីតិជន បានឃាត់ខ្លួនមនុស្ស៣នាក់ប្រុសម្នាក់ និង ស្រ្តី២នាក់ នាំយកទៅសួរនាំបន្ត នៅនាយកដ្ឋានប្រឆាំងបទល្មើសការជួញដូរមនុស្ស។ ចំណែកឯស្ត្រីដែលត្រូវសមត្ថកិច្ចចាប់ច្រឡំ និងប្រើប្រាស់ហិង្សាបណ្ដាលឲ្យរងរបួស ត្រូវបានដោះលែងវិញ៕ រក្សាសិទ្ធដោយ ៖ សា មេត*

**ក្រសួងការងារ និង ILO**
**ពិគ្រោះយោបល់ពីការរៀបចំកម្មវិធីការងារសមរម្យសម្រាប់ឆ្នាំ ២០២៤-២០២៨**

https://www.postkhmer.com/national/2023-11-20-207-256166 ២១ វិច្ឆិកា ២០២៣ ۱ ១១:០២ *អ្នកយកព័ត៌មាន:គីម យុត្តារ៉ូ*

***ភ្នំពេញ:*** *លោក ហេង សួរ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានផ្តល់អនុសាសន៍ ១០ ចំណុច លើ «ការរៀបចំកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ ២០២៤-២០២៨» ដែលជាមូលដ្ឋានគ្រឹះក៏ដូចជាធាតុចូលសម្រាប់កិច្ចពិភាក្សាដើម្បីជានាឧត្តមប្រយោជន៍របស់កម្ពុជា។ ការផ្តល់នូវអនុសាសន៍នេះធ្វើឡើងក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិ ដែលមានការចូលរួមពីលោក* Oktavianto Pasaribu *នាយករងនៃការិយាល័យអង្គការអន្តរជាតិខាងការងារ* (ILO) *ប្រចាំប្រទេសថៃ កម្ពុជា និងឡាវ រួមនឹងមន្ត្រីសហជីព និងអ្នកពាក់ព័ន្ធមួយចំនួនទៀត។ លោក ហេង សួរ ថ្លែងថា ៖ «អនុសាសន៍ទាំងនេះនឹងធ្វើឱ្យប្រសើរឡើង នូវវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងព្រះរាជាណាចក្រកម្ពុជាដែលស្របទៅតាមគោលដៅរបស់រាជរដ្ឋាភិបាលដែលបានប្រកាសដាក់ចេញតាំងពីដើមអាណត្តិ»។*

*អនុសាសន៍ទាំង ១០ ចំណុចនោះរួមមាន៖ ១ ការកសាងជំនឿទុកចិត្តពីគ្រប់ភាគីពាក់ព័ន្ធមកលើប្រសិទ្ធភាពការងាររបស់ប្រតិបត្តិកររបស់ក្រសួង។ ២ ការបង្កើតអនុលោមភាពលក្ខខណ្ឌការងារ និងលក្ខខណ្ឌសុខភាព* (OSH), *៣ ការពង្រឹងប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទការងារ (ក្រុមប្រឹក្សាអាជ្ញាកណ្ដាល),* *៤ ការពង្រីកវិសាលភាព បេឡាសន្តិសុខសង្គម, ៥ ពលករទេសន្តរប្រវេសន៍។ ៦ ការលុបបំបាត់ចោលទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ,៧ កាតព្វកិច្ចហ្វឹកហ្វឺនកូនជាងដើម្បីបង្កើនប្រសិទ្ធភាពសិក្ខាកាម,៨ ការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈតាមរយៈកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនគោលដៅ ១,៥ លាននាក់, ៩ ការលើកកម្ពស់យេនឌ័រដល់កម្មករនិយោជិតជាស្ត្រី តាមគោលការណ៍សមធម៌និង ១០ ការពង្រឹងយន្តការត្រីភាគី។*

*លោក ហេង សួរ បញ្ជាក់ថា៖ «ខ្ញុំរំពឹងថា ការពិភាក្សាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិស្តីពីការរៀបចំកម្មវិធីការងារសមរម្យប្រចាំប្រទេសកម្ពុជា ឆ្នាំ ២០២៤-២០២៨នេះ នឹងឈរលើការពិភាក្សា ដែលយកនូវឧត្តមប្រយោជន៍របស់កម្មករនិយោជិតប្រមាណ ១០ លាននាក់នៅកម្ពុជា ជាមូលដ្ឋានគ្រឹះសម្រាប់ធាតុចូលក្នុងផែនការថ្នាក់ជាតិរបស់រាជរដ្ឋាភិបាល»។*

*បើតាមឯកសារទស្សនទាន សិក្ខាសាលានេះ គឺជាការពិនិត្យឡើងវិញនៃកម្មវិធីការងារសមរម្យប្រចាំប្រទេសម្ពុជា (DWCP ២០១៩-២០២៣) ដែលត្រូវបានអនុវត្ត ដើម្បីជាធាតុចូលក្នុងការពិនិត្យមើល អ្វីដែលបានដំណើរការនិងមិនបានដំណើរការ និងចំណុចគួរកែលម្អ ឬបន្តអនុវត្តសម្រាប់កម្មវិធីនេះបន្ទាប់ ក្នុងគោលបំណងគាំទ្រដល់ការរៀនសូត្រ និងជម្រាបជូនពីការសម្រេចចិត្តពាក់ព័ន្ធនឹងការរចនាកម្មវិធី DWCP ឆ្នាំ ២០២៤-២០២៨។*

# ថ្ងៃទី២៤ ខែ វិច្ឆិកា ឆ្នាំ២០២៣

## ក្រសួង ២ នឹងធ្វើការសិក្សាលើបញ្ហាការរំលោភពលកម្មកុមារនៅតាមសិប្បកម្មឡឥដ្ឋ

https://www.postkhmer.com/national/2023-11-21-1827-256189 *២១ វិច្ឆិកា ២០២៣ | ១៨:២៤ អ្នកយកព័ត៌មាន:ជា សុខនី*

***ភ្នំពេញ:*** *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើការសិក្សាដោយយកចិត្តទុកដាក់ លើបញ្ហាការរំលោភពលកម្មកុមារ នៅតាមសិប្បកម្មឡឥដ្ឋ បន្ទាប់ពីអង្គការការពារសិទ្ធិមនុស្សលីកាដូ រកឃើញថា ការប្រើប្រាស់កម្លាំងពលកម្មកុមារ នៅតែបន្តរីកពលដាលនៅតាមសិប្បកម្មផលិតឥដ្ឋ។*

*លោក ឯម ច័ន្ទមករា អ្នកនាំពាក្យក្រសួងសង្គមកិច្ច បានប្រាប់ឱ្យដឹងនៅថ្ងៃទី២១ ខែវិច្ឆិកាថា មកដល់ពេលនេះ ក្រសួងមិនទាន់ទទួលបានរបាយការណ៍ណាជាក់លាក់ពីអង្គការលីកាដូនៅឡើយទេ ប៉ុន្តែចំពោះករណីនេះ ក្រសួងនឹងសិក្សាមើល និងធ្វើកិច្ចការងារនេះដោយយកចិត្តទុកដាក់ជាមួយក្រសួងការងារ។ លោកបន្តថា ទោះបីជាយ៉ាងណាទាំងរាជរដ្ឋាភិបាល ក៏ដូចជាក្រសួង គឺមិនគាំទ្រ និងមិនលើកទឹកចិត្តឱ្យមានករណីប្រើប្រាស់កម្លាំងពលកម្ម និងកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារនោះទេ ខណៈដែលកម្ពុជា ជាប្រទេសរដ្ឋហត្ថលេខីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។*

*លោក ឯម ច័ន្ទមករា បានថ្លែងថា៖ «ក្រសួងមិនមានការគាំទ្រឱ្យមានការប្រើប្រាស់កម្លាំងពលកម្មលើកុមារដែលមានអាយុក្រោម ១៨ឆ្នាំនោះទេ ដូច្នេះការប្រើប្រាស់កម្លាំងពលកម្មលើកុមារក្រោមអាយុនេះ គឺជាការខុសទៅនឹងអ្វីដែលបានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ»។ បើតាមលោក ឯម ច័ន្ទមករា កន្លងមកនេះក្រសួងសង្គមកិច្ច ក៏ដូចជានាយកដ្ឋានជំនាញ បានយកចិត្តទុកដាក់ណាស់*

ទៅលើការអនុវត្តលើកកម្ពស់សិទ្ធិកុមារ ក៏ប៉ុន្តែនៅតែមានកន្លែងខ្លះ បានលួចប្រើប្រាស់កម្លាំងពលកម្មកុមារ នៅតាមសិប្បកម្មផលិតឥដ្ឋ និងការងារតាមផ្ទះ ឬក៏ការលក់ផ្កាជាដើម។

ចំណែក លោក កត្តា អ៊ិន អ្នកនាំពាក្យក្រសួងការងារ ក៏បានប្រាប់ឱ្យដឹងដែរថា រាជរដ្ឋាភិបាលតាមរយៈក្រសួងការងារបានយកចិត្តទុកដាក់ខ្ពស់ ចំពោះការអនុវត្តច្បាប់ការងារឱ្យមានប្រសិទ្ធភាពនៅគ្រប់រោងចក្រ សហគ្រាស ក្រុមហ៊ុន សិប្បកម្ម និងស្ថាប័នសាធារណៈ និងឯកជន ដែលស្ថិតក្រោមច្បាប់ស្តីពីការងារ។ លោកបានបន្តថា គិតចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣នេះ ក្រសួងការងារបានខិតខំប្រឹងប្រែងក្នុងការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារដូចជាការចុះធ្វើអធិការកិច្ចការងារនៅតាមរោងចក្រ សហគ្រាស និងសិប្បកម្មជាប្រចាំ និងការចុះធ្វើយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ពីការប្រើប្រាស់កម្លាំងពលកម្មកុមារនៅតាមសិប្បកម្មផលិតឥដ្ឋ និងឧស្សាហកម្មផ្សេងៗទៀតផងដែរ។

លោក កត្តា អ៊ិន បញ្ជាក់ថា៖ «ក្រសួងនឹងធ្វើការស៊ើបអង្កេត ក្នុងករណីសង្ស័យរកឃើញម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្មណាដែលមានការប្រើប្រាស់កម្លាំងពលកម្មកុមារ ឬទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលល្មើសច្បាប់ស្តីពីការងារ នឹងត្រូវទទួលរងការផាកពិន័យ ឬក៏អាចឈានដល់ការបិទអាជីវកម្មឬអាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌផងដែរ»។ ទន្ទឹមនេះ លោកក៏បានអំពាវនាវឱ្យអង្គការសង្គមស៊ីវិលនានា និងសាធារណជន ចូលរួមរាយការណ៍ពីករណីមានការប្រើប្រាស់កម្លាំងពលកម្មកុមារ ដើម្បីឱ្យក្រសួងចាត់វិធាន និងផ្តល់កិច្ចអន្តរាគមន៍បានទាន់ពេលវេលា។

## ក្រសួងកិច្ចការនារី ស្នើដល់អ្នកសារព័ត៌មាន ប្រើពាក្យពេចន៍ឱ្យបានត្រឹមត្រូវចំពោះពលករទេសន្តរប្រវេសន៍ជាស្ត្រី

https://www.kampucheathmey.com/local-news/617211 ថ្ងៃព្រហស្បតិ៍ ២៣ វិច្ឆិកា ២០២៣

ដោយ អុន ស្រីមាន

លោកស្រី ញាន សុចិត្រា អគ្គនាយក នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងកិច្ចការនារី បានសំណូមពរដល់អ្នកសារព័ត៌មានគ្រប់រូប អ្នកសរសេរមាតិកា ចេះប្រើពាក្យពេចន៍បានត្រឹមត្រូវ និងសមរម្យ ចំពោះពលករទេសន្តរប្រវេសន៍ (ពលករចំណាកស្រុក) ដែលជាស្ត្រី ព្រោះអ្នកសារព័ត៌មានជាអ្នកដើរតួនាទីសំខាន់ណាស់ក្នុងការទប់ស្កាត់អំពើហិង្សា និងផ្សាព្វផ្សាយឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ។ លោកស្រីលើកឡើងបែបនេះ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងពិធីប្រកាសឱ្យប្រើប្រាស់ សន្ទានុក្រមសម្រាប់ប្រព័ន្ធផ្សព្វផ្សាយផ្តោតលើពលករទេសន្តរប្រវេសន៍ (ពលករចំណាកស្រុក) ជាស្ត្រី និងការបញ្ឈប់អំពើហិង្សាលើស្ត្រី ដែលទើបតែបកប្រែជាភាសាខ្មែរហើយរួចរាល់

ដែលមានការគាំទ្រពីអង្គការ UN Women និងអង្គការ ILO។ លោកស្រី ញាន សុចិត្រា បន្តថា ក្រសួងកិច្ចការនារីគាំទ្រយ៉ាងខ្លាំងចំពោះការដាក់ឱ្យប្រើប្រាស់សទ្ទានុក្រមនេះ ព្រោះឯកសារនេះមានសារសំខាន់ក្នុងការប្រើប្រាស់ភាសា និងជាការចូលរួមទប់ស្កាត់ដល់ទេសន្តរប្រវេសន៍ជាស្ត្រីពីអំពើហិង្សានានា។

លោកស្រី បាននិយាយថា ការប្រើពាក្យពេចន៍នេះគឺសំខាន់ណាស់ ប្រសិនជាប្រើប្រាស់មិនបានត្រឹមត្រូវ នឹងក្លាយជារឿងវិជ្ជមាន និងអវិជ្ជមាន តាមការលើកដាក់សំឡេងរបស់អ្នករាយការណ៍ព័ត៌មាន។ លោកស្រីបន្តទៀតថា មានអ្នកព័ត៌មានមួយចំនួន ផ្សព្វផ្សាយពីព័ត៌មានរំលោភបំពានផ្លូវភេទ ប៉ុន្តែបែរជានិយាយបែបសើចសំអកឱ្យជនរងគ្រោះ បញ្ចេញបញ្ចូលតាមអារម្មណ៍របស់ខ្លួនដោយមិនបានយល់ពីអត្ថន័យនៃការផ្សព្វផ្សាយព័ត៌មានបែបណានោះទេ ដែលធ្វើឱ្យអ្នកទស្សនាខឹងសម្បារចំពោះអ្នកអត្ថាធិប្បាយ។ លោកស្រី ក៏បានសំណូមពរឱ្យអ្នកសារព័ត៌មានគោរពតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមក្រមសីលធម៌របស់អ្នកសារព័ត៌មាន។ ចំពោះការបញ្ឈប់អំពើហិង្សា គឺភាគីពាក់ព័ន្ធ រួមទាំងរដ្ឋាភិបាលផងមានតួនាទីចាំបាច់ណាស់ក្នុងការចូលរួមទប់ស្កាត់។

ជាមួយគ្នានេះ លោកស្រី ឃុន សុភា អ្នកសម្របសម្រួលកម្មវិធីថ្នាក់ជាតិនៃ UN Women ប្រចាំប្រទេសកម្ពុជា បានលើកឡើងថា ការប្រើប្រាស់ពាក្យពេចន៍ដែលបានប្រើរាល់ថ្ងៃមានឥទ្ធិពលធំធេងណាស់នៅក្នុងសង្គមរាល់ថ្ងៃ។ ដោយមើលឃើញពីឥទ្ធិពលនៃភាសានេះហើយ អង្គការ UN Women យកចិត្តទុកដាក់ខ្លាំងពីពាក្យពេចន៍ផ្តោតលើយេនឌ័រ នៅពេលសរសេរចេញទៅមានផលអវិជ្ជមានបែបណាខ្លះចំពោះ បុរស ក្មេងស្រី និងកុមារ។ លោកស្រីនិយាយថា ៖ "**ពាក្យពេចន៍ដែលមានចរិតលក្ខណៈគិតគូរពីលក្ខណៈទូលំទូលាយនៃភាពចម្រុះនៃយេនឌ័រ និងសង្គម គឺមិនដាក់ទម្ងន់ មិនបំភ្លេចចោលនៃការរួមចំណែកសំខាន់នៃយេនឌ័រណាមួយទេ គឺឃើញពីគ្រប់រូបភាពយេនឌ័រនៅក្នុងសង្គមចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សហគមន៍**"។

លោកស្រី ឃុន សុភា ស្នើឱ្យអ្នកសរសេរព័ត៌មាន អ្នកសរសេរក្នុងបណ្តាញសង្គម និងអ្នកបង្កើតមាតិកាជាដើម គួរមានការរំលឹកខ្លួនឯងជារឿងៗ ចំពោះពាក្យពេចន៍ណាដែលសរសេរទៅមិនធ្វើឱ្យមានការរើសអើង និងបង្កើតឱ្យមានផ្នត់គំនិតវិជ្ជមានក្នុងសង្គម។

សូមជម្រាបថា សទ្ទានុក្រមនេះ ផ្តល់ការណែនាំសម្រាប់អ្នកសារព័ត៌មាន អ្នកស្រាវជ្រាវ អ្នកបណ្តុះបណ្តាល និងអ្នកពាក់ព័ន្ធដែលពាក់ព័ន្ធនឹងការសរសេរអំពីការធ្វើចំណាកស្រុកពលកម្មរបស់ស្ត្រី និងអំពើហិង្សាលើស្ត្រី។ ឈរលើមូលដ្ឋាននៅក្នុងច្បាប់អន្តរជាតិ និងការណែនាំដែលបានព្រមព្រៀងគ្នា មានគោលបំណងបង្កើតមូលដ្ឋានរួមសម្រាប់ការសន្ទនា និងរួមចំណែកដល់ពិភពលោក

ដែលសិទ្ធិត្រូវបានគោរព ហើយសំឡេង ការជ្រើសរើស និងទីភ្នាក់ងារត្រូវបានទទួលស្គាល់របស់ស្ត្រី៕

## អង្គការ IOM រកឃើញជនចំណាកស្រុកនៅកម្ពុជា ប្រឈមនឹងឧបសគ្គក្នុងការទទួលបានសេវាថែទាំសុខភាព ដើម្បីបង្ការជំងឺឆ្លង

https://www.postkhmer.com/national/2023-11-22-1748-256221 ២២ វិច្ឆិកា ២០២៣ | ១៧:៤៤ អ្នកយកព័ត៌មាន:ជា សុខនី

***ភ្នំពេញៈ*** *របាយការណ៍របស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) បានរកឃើញជនចំណាកស្រុកនៅកម្ពុជា ប្រឈមមុខនឹងឧបសគ្គជាច្រើនក្នុងការទទួលបានសេវាថែទាំសុខភាព ដើម្បីបង្ការជំងឺឆ្លង ខណៈដែលរបាយការណ៍នេះក៏បានផ្តល់អនុសាសន៍ក្នុងការបង្កើតគោលនយោបាយរួមបញ្ចូលជនចំណាកស្រុកផងដែរ។ ការរកឃើញបែបនេះ តាមរយៈការសិក្សាស្រាវជ្រាវនៅក្នុងខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តស្ទឹងត្រែង ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដែលជាខេត្តមានព្រំដែនជាប់ប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសឡាវ ជាប្រទេសដែលមានប្រជាជនខ្មែរធ្វើចំណាកស្រុកទៅរស់នៅ និងប្រកបការងារ។*

*នេះបើយោងតាមរបាយការណ៍ចុងក្រោយរបស់អង្គការ IOM ដែលមានចំណងជើងថា «ជំងឺឆ្លង និងការទទួលបានសុខភាពក្នុងចំណោមជនចំណាកស្រុកនៅកម្ពុជា» ដែលបានចេញផ្សាយកាលពីសប្តាហ៍មុន និងអ្នកសារព័ត៌មានទទួលបាននៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ បានឱ្យដឹងថា ជនចំណាកស្រុកសរុបចំនួន ៤៦២ នាក់ មកពីខេត្តចំនួន ៥ នៅកម្ពុជា បានធ្វើការស្ទង់មតិទៅលើចំណេះដឹង និងឥរិយាបថ ពីការផ្តល់សេវាទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺរបេង ជំងឺរលាកថ្លើមប្រភេទ B ជំងឺរលាកថ្លើមប្រភេទ C ជំងឺគ្រុនឈាម គ្រុនចាញ់ និងជំងឺឆ្លងផ្សេងៗទៀត។*

*ប្រភពដដែលបន្តថា លទ្ធផលស្ទង់មតិនេះ រកឃើញថា ជនចំណាកស្រុក កំពុងប្រឈមនឹងឧបសគ្គជាច្រើនទាំងការយល់ដឹង ភាសា កង្វះខាតគោលនយោបាយ យុទ្ធសាស្ត្រជាតិ ដែលរួមបញ្ចូលជនចំណាកស្រុក។ ទន្ទឹមនឹងនេះដែរ ក៏បានរកឃើញថា ការអប់រំ ផ្សព្វផ្សាយទាក់ទងនឹងជំងឺទាំងអស់នោះក៏បានថយចុះដែរ ហើយអត្រានៃការធ្វើតេស្តស្វែងរកជំងឺទាំងនេះ ក៏មិនមានជនចំណាកស្រុកណាម្នាក់ធ្លាប់បានធ្វើតេស្តរកផងទេ។*

*របាយការណ៍បញ្ជាក់ថាៈ «ជនចំណាកស្រុក ប្រឈមមុខនឹងឧបសគ្គជាច្រើនក្នុងការទទួលបានសេវាថែទាំសុខភាពសំខាន់ៗ ដោយសារកត្តាមួយចំនួនរួមមាន ស្ថានភាពចំណាកស្រុកមិនទៀងទាត់ ឧបសគ្គភាសា កង្វះគោលនយោបាយសុខភាពរួមបញ្ចូលជនចំណាកស្រុក និងលទ្ធភាពមិនអាចសម្រេចបាននូវគោលដៅសុខភាពសកលដូចជា ការការពារនិងបង្ការជំងឺឆ្លងផ្សេងៗ»។ ប្រភព*

ដដែលថា ហេតុនេះធ្វើឱ្យមានអត្រាឈឺ និងការស្លាប់ខ្ពស់ក្នុងចំណោមជនចំណាកស្រុក ជាពិសេសក្នុងស្ថានភាពចំណាកស្រុកខុសច្បាប់ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម គឺជាការព្រួយបារម្ភផ្នែកសុខភាពដែលភាគីពាក់ព័ន្ធត្រូវយកចិត្តទុកដាក់។

អង្គការ IOM បានលើកឡើងជាអនុសាសន៍ដែរថា ដើម្បីអាចចូលរួមចំណែកដោះស្រាយបញ្ហាឧបសគ្គទាំងអស់បាន ក្រសួងសុខាភិបាល ក៏ដូចជាក្រសួងពាក់ព័ន្ធ ត្រូវបង្កើតទំនាក់ទំនងល្អជាមួយអង្គការដៃគូពាក់ព័ន្ធ ទៅលើការគាំទ្រ អប់រំ និងធ្វើយុទ្ធនាការផ្សព្វផ្សាយពីជំងឺទាំងអស់ទៅកាន់សហគមន៍មូលដ្ឋាន ជាពិសេសក្រុមជនគោលដៅ។ លើសពីនេះទៀត ត្រូវកសាងគោលនយោបាយយុទ្ធសាស្ត្រសម្រាប់ការពារជនចំណាកស្រុក និងពង្រឹងការអនុវត្តផែនការដែលមានស្រាប់តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ។

ប្រធាននាយកដ្ឋានជំងឺឆ្លងនៃក្រសួងសុខាភិបាល លោក លី សូវ៉ាន់ នៅថ្ងៃទី២២ ខែវិច្ឆិកា មិនអាចសុំអត្ថាធិប្បាយបានទេ ដោយហេតុជាប់ប្រជុំ។

# ថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ២០២៣

## កម្ពុជា-ថៃ បង្ហាញឆន្ទៈ ក្នុងការបន្តកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទ្វេភាគី

https://www.postkhmer.com/national/2023-11-28-1646-256349 ២៨ វិច្ឆិកា ២០២៣ | ១៦:០៣ អ្នកយកព័ត៌មាន:ជា សុខនី

នៅក្នុងជំនួបពិភាក្សាការងារ រវាងអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់កម្ពុជា និងលេខាធិការអចិន្ត្រៃយ៍ នៃក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខរបស់ថៃ ភាគីទាំងពីរបានបង្ហាញនូវឆន្ទៈ ក្នុងការបន្តកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងជួញដូរមនុស្សឱ្យកាន់តែល្អប្រសើរ។ ជំនួបពិភាក្សាគ្នានេះ បានធ្វើឡើងស្របពេលលោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទៅចូលរួមសន្និសីទថ្នាក់តំបន់ស្ដីពី អំពើពុករលួយពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស (TIP) និងអំពើរត់ពន្ធជនទេសន្តរប្រវេសន៍ (SOM) ដែលបានប្រព្រឹត្តទៅចំនួន ២ថ្ងៃចាប់ពីថ្ងៃទី២១-២២ ខែវិច្ឆិកា នៅទីក្រុងបាងកក ប្រទេសថៃ។ លោកស្រី ជូ ប៊ុនអេង បានឱ្យដឹងតាមរយៈហ្វេសប៊ុក កាលពីថ្ងៃទី២៣ ខែវិច្ឆិកាថា ក្រៅពីចូលរួមសន្និសីទ លោកស្រីក៏មានជំនួបពិភាក្សាជាមួយលោក Anukul Peedkaev លេខាធិការអចិន្ត្រៃយ៍ នៃ

ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខ និងជាមួយតំណាងស្ថាប័ន កម្មវិធីជានាំពប់រងសុខភាព Migration-Fund (M-Fund) របស់ប្រទេសថៃផងដែរ។

លោកស្រីបន្តថា ក្នុងជំនួបនេះ ភាគីទាំងពីរ បានធ្វើការពិភាក្សាទៅលើការពន្លឿន បញ្ចប់ឯកសារនីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស (SOP) និងពិនិត្យបន្ថែមលើអនុស្សរណៈ (MOU)។ លោកស្រីបញ្ជាក់ថា៖ «ទាំងភាគីកម្ពុជា និងថៃ បានសន្មត់ថាជួបគ្នា នៅត្រីមាសទី១ ខែមករា ឆ្នាំ២០២៤ ក្នុងការបន្តកិច្ចសហការគ្នាបន្ថែមទៀត ទៅលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ក្នុងនោះដែរទាំងភាគីកម្ពុជា និងភាគីថៃ គឺសុទ្ធតែមានឆន្ទៈក្នុងកិច្ចសហការគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស»។ បើតាមលោកស្រី ជូ ប៊ុនអេង សន្និសីទថ្នាក់តំបន់ខាងលើ បានរៀបចំឡើងក្នុងគោលបំណង ដើម្បីចែករំលែកបទពិសោធន៍ ការអនុវត្តល្អៗ ស្វែងរកដំណោះស្រាយនានាពីភាគីពាក់ព័ន្ធ រួមមានសកម្មភាពរបស់រាជរដ្ឋាភិបាល វិស័យឯកជន និងអង្គការសង្គមស៊ីវិល ដើម្បីទទួលបានចំណេះដឹងថ្មីៗ។

សន្និសីទនេះ ក៏មានគោលបំណងជំរុញការសន្ទនារវាងភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងតំបន់ ដើម្បីបង្កើតអនុសាសន៍ និងមធ្យោបាយឆ្ពោះទៅមុខ ដើម្បីលើកកម្ពស់វិធានការពុករលួយដែលមានប្រសិទ្ធភាព និងពាក់ព័ន្ធបន្ថែមទៀតនៅក្នុងបរិបទនៃការជួញដូរមនុស្សនិងឧក្រិដ្ឋកម្មរត់ពន្ធជនចំណាកស្រុក។ ក្នុងសន្និសីទនេះដែរ លោកស្រីក៏បានផ្តល់អនុសាសន៍ ក្នុងការពិនិត្យមើលការបញ្ចូលច្បាប់ ប្រឆាំងការជួញដូរ និងច្បាប់ប្រឆាំងអំពើពុករលួយ សម្អាតប្រាក់ ដោយត្រូវដាក់ចូលក្នុងផែនការជាតិ និងបន្ថែមសមាជិកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សពីស្ថាប័នដែលពាក់ព័ន្ធ។

ទាក់ទងរឿងនេះ លោក អំ សំអាត នាយកទទួលបន្ទុកកិច្ចការទូទៅ នៃអង្គការការពារសិទ្ធិមនុស្សលីកាដូ បានឱ្យដឹងថា ការបន្តកិច្ចសហការជាមួយបណ្តាប្រទេសជិតខាង ទៅលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺវាជារឿងសំខាន់ ពីព្រោះបញ្ហាជួញដូរមនុស្សក្នុងប្រទេសកម្ពុជាត្រូវបានប្រទេសមហាអំណាច និងអង្គការអន្តរជាតិ បានចាត់ទុកកម្ពុជា ជាប្រទេសដែលស្ថិតនៅក្នុងចំណាត់ថ្នាក់មួយដែលមិនល្អ។ លោកថ្លែងថា៖ «នៅពេលកម្ពុជាយើង មានកិច្ចសហប្រតិបត្តិការល្អជាមួយបណ្តាប្រទេសជិតខាង នោះការងាររួមគ្នាទប់ស្កាត់អំពើជួញដូរមនុស្ស ក៏ដូចជាជាមួយបណ្តាអន្តរជាតិ វានឹងងាយស្រួលក្នុងការកំណត់មុខសញ្ញាជនឧក្រិដ្ឋ ដែលប្រព្រឹត្តបទល្មើសជួញដូរមនុស្ស»។ លោកបន្ថែមថា ក្រៅពីមានកិច្ចសហការគ្នាល្អហើយ អ្វីដែលសំខាន់មួយទៀត គឺការលុបបំបាត់អំពើពុករលួយ ដើម្បីធ្វើយ៉ាងណាឱ្យបញ្ហាការជួញដូរមនុស្ស ត្រូវបានដោះស្រាយតាមរយៈ

ប្រព័ន្ធយុត្តិធម៌ ទោះបីជនដែលពាក់ព័ន្ធនោះ មានបុណ្យស័ក្តិ អំណាចធំប៉ុនណាក៏ដោយ គឺត្រូវតែអនុវត្តតាមផ្លូវច្បាប់។

## ពលករ និងមន្ត្រីអង្គការសង្គមស៊ីវិលស្នើរដ្ឋាភិបាលពន្លឿនការបញ្ចុះតម្លៃលិខិតឆ្លងដែន

https://www.rfa.org/khmer/news/social-economy/workers-and-civil-society-officials-call-on-government-to-speed-up-passport-discounts-11242023042016.html *ដោយ ថា ថៃ* 2023.11.24

*ពលករ និងមន្ត្រីអង្គការសង្គមស៊ីវិលស្នើរដ្ឋាភិបាលពន្លឿន ការបញ្ចុះតម្លៃធ្វើលិខិតឆ្លងដែន។ ពួកគាត់លើកឡើងថា ការបញ្ចុះតម្លៃលិខិតឆ្លងដែននេះ នឹងអាចធ្វើឲ្យពលករ រួចផុតពីទាសករសម័យទំនើប។ ពលករ ដែលចំណាកស្រុកទាំងប្រថុយប្រថានទៅប្រទេសថៃ កំពុងតែជួបបញ្ហាជីវភាព ក្រោយពីបង្ខំចិត្តនាំកូននាំចៅចាកឆ្ងាយពីគ្រួសារ ដើម្បីទៅធ្វើការនៅប្រទេសថៃ រកលុយសងបំណុលធនាគារ។ ពលករទាំងនោះជាពលករឆ្លងដែនខុសច្បាប់ទាំងនោះ នៅពេលថៅកែកេងប្រវ័ញ្ចកម្លាំង និងមិនបើកប្រាក់ខែឲ្យ គឺពួកគាត់មិនត្រឹមតែ មិនត្រូវបានការពារដោយក្រសួងការងារនៃប្រទេសថៃទេ ថែមទាំងប្រឈមនឹងថៅកែដាក់ពាក្យបណ្ដឹងទៅអាជ្ញាធរថៃ ឲ្យឃាត់ខ្លួនពួកគាត់នៅក្នុងករណីគ្មានលិខិតឆ្លងដែនទៀតផង។*

*ពលករធ្វើការសំណង់នៅប្រទេសថៃ លោក សឿន ឌីន ដែលមានប្រពន្ធ និងកូនចំនួន៥នាក់ ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី២២ វិច្ឆិកា ថា គ្រួសាររបស់លោកបានចំណាកស្រុកមកដើម្បីរកការងារធ្វើ ដោយមិនមានលទ្ធភាពធ្វើលិខិតឆ្លងដែននោះទេ។ លោកបន្តថា ថ្មីៗនេះ ថៅកែមិនបានបើកលុយឲ្យលោក និងពលករចំនួន ១៥នាក់ផ្សេងទៀតនោះ ជាហេតុធ្វើឲ្យគ្រួសារលោកជួបបញ្ហាសេដ្ឋកិច្ច និងគ្មានលទ្ធភាពសងបំណុលធនាគារ។ លោក សឿន ឌីន៖ «ធ្វើម៉េចបើអត់ទៅហើយមានតែធ្វើការឡើងមកហ្នឹងហើយ ដល់ពេលឡើងមកបើកលុយអត់បានទៀត អត់ដឹងគិតថាម៉េច ។ ជួបដែរផលលំបាក គេអត់បើកលុយឲ្យ អីចឹងទៅពិបាកដែរបង មានថ្ងៃខ្វះដើររើសអេតចាយ»។*

*កម្មករ នៅប្រទេសថៃ ម្នាក់ទៀត គឺលោក គួ សារឿន ប្រាប់វិទ្យុអាស៊ីសេរីថា លោកក៏ជួបប្រទះបញ្ហា ដូចពលករដទៃទៀតដែរដូចជា ការធ្វើការពីមួយខែទៅមួយខែ ប្រាក់ខែសម្រាប់តែបន្តសុពលភាពឯកសារការងារ ។ លោកស្នើដល់រដ្ឋាភិបាល បញ្ចុះតម្លៃលិខិតឆ្លងដែន និងរៀបចំកន្លែងធ្វើលិខិតឆ្លងដែនឲ្យបានច្រើនកន្លែងក្នុងប្រទេសថៃ ដើម្បីកាត់បន្ថយការចំណាយរបស់ពលករ។ លោក គួ សារឿន៖ «ស្នើឲ្យរាជរដ្ឋាភិបាលមកធ្វើលិខិតឆ្លងដែន* (Passport) *នៅប្រទេសថៃ ចង់ឲ្យគាត់មកធ្វើទៅ ដើម្បីកុំឲ្យបងប្អូនយើងទៅតាមជាយដែនទៅថតរូបថតអី គាត់មានផលវិបាកអាថ្ងៃឡានទៀត ។ ថ្ងៃឡានគេយកពីគាត់ក្នុងមួយនាក់ ៤ពាន់ ៥រយបាត អ៊ីចឹងគាត់ទៅធ្វើការរាល់ថ្ងៃហ្នឹង*

ចិញ្ចឹមតែប៉ាស្ព័រ និងឯកសារប៉ុណ្ណឹងឯង អ៊ីចឹងគាត់អត់មានលុយបង់ធនាគារ គាត់ខ្វះខាតច្រើន។ អ៊ីចឹងរួបរួមទៅគាត់ធ្វើការមួយថ្ងៃ ៣រយហាសិបបាតទៅ ៤រយបាត មានន័យថា គាត់យកលុយចំណូលហ្នឹងយកទៅចាយឯកសារវាអត់គ្រប់អត់គ្រាន់ហាបង៉»។

ចំណែកពលករខ្មែរធ្វើការសំណង់នៅខេត្តជាប់ទីក្រុងបាងកក (Bangkok) លោក អែម ពិសិដ្ឋ ថ្លែងថា ដោយសារការធ្វើលិខិតឆ្លងដែន និងទិដ្ឋាការការងារនៅប្រទេសថៃ មានតម្លៃថ្លៃ និងត្រូវធ្វើជាប្រចាំ លោកស្នើដល់រដ្ឋាភិបាលឲ្យបញ្ចុះតម្លៃលិខិតឆ្លងដែន និងផ្អាកការបង់សងបំណុលធនាគាររយៈពេលមួយឆ្នាំដើម្បីឲ្យពលរដ្ឋ មានលទ្ធភាពស្តារសេដ្ឋកិច្ចឡើងវិញ។ លោក អែម ពិសិដ្ឋ៖ « ហើយណាមួយបារម្ភនៅពេលយើងធ្វើការខែវស្សាការងារសំណង់ពេលខ្វះយើងត្រូវទឹកភ្លៀងយើងត្រូវអីទៅវា ផ្តាសាយវាឈឺ ហើយយើងអត់បានធ្វើការ សុំសម្រាកមួយថ្ងៃទៅ២ថ្ងៃ អីចឹងហើយយើងត្រូវខ្ចីលុយគាត់ហ្នឹងដើម្បីមើលថែទាំខ្លួនថែមទៀត អ៊ីចឹង។ អ៊ីចឹងហើយធ្វើឲ្យយើងធ្វើការចាប់ពី៣ខែទៅ៤ខែបានយើងអាចដោះគ្រាន់តែរួច និងមានលុយផ្ញើទៅអ្នកផ្ទះខ្លះ»។

វិទ្យុអាស៊ីសេរី នៅពុំទាន់អាចទាក់ទងអ្នកនាំពាក្យរដ្ឋាភិបាល លោក ប៉ែន បូណា ដើម្បីសុំការឆ្លើយតបចំពោះការលើកឡើងនេះ បាននៅឡើយទេ នៅថ្ងៃទី២២ វិច្ឆិកា។

ទាក់ទងនឹងការស្នើសុំបញ្ចុះថ្លៃធ្វើលិខិតឆ្លងដែននេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស សុខា កាលពីដើមខែកញ្ញា ថ្លែងទទួលស្គាល់ថា តម្លៃធ្វើលិខិតឆ្លងដែននៅកម្ពុជា មានតម្លៃខ្ពស់ បើធៀបនឹងប្រទេសក្នុងតំបន់ ។ លោក ណែនាំដល់ស្ថាប័នពាក់ព័ន្ធ គួរពិនិត្យឡើងវិញ ចំពោះតម្លៃធ្វើលិខិតឆ្លងដែននេះ។ លោក ស សុខា៖ «និយាយរួមសូមឲ្យពិនិត្យបញ្ហានេះហើយ សូមឲ្យលើកយោបល់ក្នុងការសម្រេចធ្វើម៉េចផ្តល់ភាពកក់ក្តៅជូនប្រជាពលរដ្ឋ កុំឲ្យការវិវត្តពីមួយអាណត្តិទៅមួយអាណត្តិ លិខិតឆ្លងដែនមានការឡើងថ្លៃរហូត ហើយយើងដឹងហើយការបោះពុម្ព ឬមួយការផលិតនៃលិខិតឆ្លងដែននេះ មិនដល់ប៉ុណ្ណឹងពេកទេ»។

ប្រធានផ្នែកប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ អង្គការសង់ត្រាល់ (Central) លោក ឌី ថេហូយ៉ា ថ្លែងក្នុងកិច្ចពិភាក្សារបស់អង្គការសង់ត្រាល់ ក្រោមប្រធានបទថា៖ « ធ្វើដូចម្តេច ដើម្បីកាត់បន្ថយហានិភ័យ នៃការចំណាកស្រុក?» នៅថ្ងៃទី២២ វិច្ឆិកា ថា ពលករចំណាកស្រុកដោយខុសច្បាប់ទៅប្រទេសថៃ កំពុងតែជួបប្រទះបញ្ហាតាំងពីដំណាក់កាលស្វែងរកការងារ អំឡុងពេលការងារ និងក្រោយឈប់បំពេញការងារ។ លោកបន្តថា នៅពេលពលករទាំងនោះ ត្រូវបានថៅកែរំលោភសិទ្ធិការងារ ដោយកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬថៅកែមិនបើកប្រាក់ខែឲ្យ ឬថៅកែបង្ខំឲ្យធ្វើការក៏ដោយ ក៏ពួកគាត់ស្ទើរតែមិនទទួលបានការការពារពីក្រសួងការងារ នៃប្រទេសថៃដែរ។

លោក ឌី ថេហូយ៉ា៖«ទាសភាពក្នុងសម័យទំនើបនេះ ទាសករក្នុងសម័យទំនើបហ្នឹង វាអត់មានឯករាជ្យ អត់មានសេរីភាព អត់មានសេរីភាពក្នុងការដើរហើរ អត់មានសេរីភាពក្នុងការតវ៉ា មិនទទួលបានប្រាក់ឈ្នួលសមរម្យ ការងារដោយបង្ខំទាំងអស់ហ្នឹង គេហៅថា បើយើងនិយាយភាសាសាមញ្ញគេហៅថា ទាសករក្នុងសម័យទំនើបសំណួរសួរថា បើការធ្វើការរបស់ប្រជាពលរដ្ឋភាគច្រើនដែលធ្វើការក្នុងភាពជាទាសភាពក្នុងសម័យទំនើប សំណួរសួរថា ទី១ សុខភាពគាត់រឹងមាំឬអត់នៅពេល ដែលគាត់ចប់កិច្ចសន្យាការងារ ឬក៏ត្រឡប់មកខ្មែរ? ទី២ សំណួរសួរថា គាត់សល់លុយត្រឡប់មកវិញអត់?»។

ប្រៀបធៀបជាមួយធ្វើលិខិតឆ្លងដែនជាមួយប្រទេសជិតខាងវិញ ការធ្វើលិខិតឆ្លងដែនកម្ពុជាមានតម្លៃថ្លៃជាងគេ។ ដើម្បីធ្វើលិខិតឆ្លងដែនប្រើប្រាស់ ប្រជាពលរដ្ឋខ្មែរត្រូវចំណាយចាប់ពីជាង ១រយដុល្លារ (១១០ដុល្លារ) ទៅដល់ជាង ២រយដុល្លារអាមេរិក (២៣០ដុល្លារ) ខណៈការធ្វើលិខិតឆ្លងដែន ប្រទេសថៃ (Thailand) និងប្រទេសឡាវ (Lao) ប្រជាពលរដ្ឋនៃប្រទេសទាំង ២នេះ ត្រូវចំណាយប្រមាណ ៥០ដុល្លារតែប៉ុណ្ណោះ។

## ពលករខ្មែរនៅថៃ ស្នើឱ្យរដ្ឋាភិបាលជួយពន្យារពេលបង់សងបំណុលធនាគារ

ក្រុមសកម្មជន និងពលរដ្ឋខ្មែររស់នៅប្រទេសថៃប្រមាណ១០០នាក់ បានប្រមូលផ្តុំគ្នាទាមទារឱ្យរដ្ឋាភិបាលកម្ពុជាពិចារណាពន្យារពេលការបង់សងត្រឡប់នៃបំណុលធនាគារ និងមីក្រូហិរញ្ញវត្ថុដែលពួកគេកំពុងជំពាក់។ ការស្នើឱ្យពន្យារពេលបែបនេះ ដោយពួកគេលើកហេតុដូចៗគ្នាថា ពួកគេអស់លទ្ធភាពបង់សងត្រឡប់ក្រោយជីវភាពធ្លាក់ដុនដាប ហើយពលរដ្ឋខ្មែរខ្លះក៏បាត់បង់ការងារជាដើម។

https://www.rfi.fr/km//20231127?utm_medium=social&utm_campaign=telegram&utm_source=shorty ចុះផ្សាយនៅថ្ងៃ៖ 27/11/2023 - 10:17

កញ្ញា អេង ម៉ាឡៃហៅ ស៊ូ មេត្តានៅរសៀលថ្ងៃទី២៧ ខែវិច្ឆិកាបានឱ្យដឹងថា ពលរដ្ឋខ្មែរដែលជាពលករចំណាកស្រុក ពួកគេកំពុងជួបប្រទះបញ្ហាជីវភាពកាន់តែខ្លាំង ដោយពលករខ្លះប្រឈមនឹងការដាច់បាយ និងខ្លះទៀតកំពុងបាត់បង់ការងារធ្វើថែមទៀត ខណៈកញ្ញាផ្ទាល់តែងរស់ពឹងអាស្រ័យទៅលើបងប្អូនសាច់ញាតិ ឬអ្នកស្គាល់គ្នាតែប៉ុណ្ណោះ។

កញ្ញា ស៊ូ មេត្តាបន្តថា ពលករខ្មែរប្រមាណ៩០%ហើយដែលកំពុងជាប់ជំពាក់បំណុលធនាគារ។ ចំណែក ស្ថានភាពការងារនៅប្រទេសថៃបច្ចុប្បន្ន មិនអំណោយផលទើបពលករខ្មែរស្ទើទាំងអស់ត្រូវជួបប្រទះបញ្ហាជីវភាព ដោយម្យ៉ាងពួកគេត្រូវបែងចែកប្រាក់មួយផ្នែកមើលជម្ងឺប្រចាំកាយ មួយ

ផ្នែកទៀតត្រូវប្រើប្រាស់សម្រាប់ការចំណាយប្រចាំថ្ងៃ និងមួយចំណែកទៀតត្រូវផ្ញើទៅក្រុមគ្រួសារដែលរស់នៅប្រទេសកម្ពុជា។ ប៉ុន្តែការផ្ញើប្រាក់ទៅឱ្យក្រុមគ្រួសារ កញ្ញា ស៊ូ មត្តាបញ្ជាក់ថា មានចំនួនតិចតួចណាស់ដែលស្មើតែមិនគ្រប់ការបង់សងបំណុលធនាគារផង។

បញ្ហាទាំងនេះ ទើបសកម្មជន និងពលរដ្ឋខ្មែរដែលរស់នៅប្រទេសថៃជាង១០០នាក់ សម្រេចប្រមូលផ្តុំគ្នាសម្តែងមតិអំពាវនាវឱ្យរដ្ឋាភិបាលថ្មី ពិនិត្យការអំពាវនាវរបស់ពលករដែលកំពុងជួបប្រទះបញ្ហាជីវភាពឱ្យពន្យារពេលការបង់សងត្រឡប់នៃបំណុលធនាគារក្នុងរយៈពេលសមស្រប ណាមួយ។ ការពន្យារពេលបង់សងត្រឡប់នៃបំណុលធនាគារ ពលករខ្មែរម្នាក់បង្ហាញសុំមិនអត្តសញ្ញាណបានប្រាប់វិទ្យុបារាំងអន្តរជាតិRFIថា ខ្លួនមិនទាមទារអ្វីច្រើនពីរដ្ឋាភិបាលឡើយ ពោលគឺស្នើសុំត្រឹមការពន្យារពេលការបង់សងបំណុលធនាគារក្នុងរយៈពេល១ឆ្នាំ ឬ៦ខែដើម្បីអាចឱ្យខ្លួនមានពេលដោះស្រាយបញ្ហាជីវភាពមួយរយៈសិន។

ពលកររូបនេះបន្តថា ប្រសិនបើខ្លួនមិនជួបបញ្ហាជីវភាពនោះទេ ម៉្លោះខ្លួនមិនស្នើសុំកិច្ចអន្តរាគមន៍ពីប្រមុខរដ្ឋាភិបាលអ្វីឡើយ។ ពលករដដែលរូបនេះអះអាងទៀតថា ការស្នើឱ្យពន្យារពេលបង់សងបំណុលធនាគារនេះ ពលករខ្មែរជាច្រើននាក់ផ្សេងទៀតតែងចេញមកប្រមូលផ្តុំគ្នាសម្តែងមតិដើម្បីធ្វើយ៉ាងណាឱ្យរដ្ឋាភិបាលបានដឹង ប៉ុន្តែគិតមកទល់ពេលនេះ ការស្នើរបស់ខ្លួនហាក់មិនមានប្រសិទ្ធភាព ពីព្រោះថាមន្ត្រីឥណទានរបស់ធនាគារ និងមីក្រូហិរញ្ញវត្ថុនៅតែបន្តទារប្រាក់ដដែល។

ឆ្លើយតបទៅហ្នឹងបញ្ហានេះ លោក កាំង តុងងី អ្នកនាំពាក្យសមាគមមីក្រូហិរញ្ញវត្ថុបានបញ្ជាក់ថា ការចេញមកស្នើឱ្យរដ្ឋាភិបាលពន្យារពេលបង់សងបំណុលមិនមែនជាជម្រើសដែលត្រឹមត្រូវឡើយ។ ជម្រើសដែលត្រឹមត្រូវ លោកកាំង តុងងី ជំរុញឱ្យពលរដ្ឋដែលកំពុងជួបប្រទះបញ្ហាជីវភាពត្រូវស្នើសុំទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារដែលពលរដ្ឋខ្ចី ដើម្បីធ្វើការរៀបចំឥណទានឡើងវិញ។

ពាក់ព័ន្ធនឹងបញ្ហានេះ ប្រមុខរដ្ឋាភិបាលកម្ពុជា លោកនាយករដ្ឋមន្ត្រីហ៊ុន ម៉ាណែតក៏ធ្លាប់បានអំពាវនាវឱ្យប្រតិបត្តិករធ្វើការក្នុងវិស័យហិរញ្ញវត្ថុជួយសម្រួលបន្ទុករបស់អតិថិជនដែលភាគច្រើនពួកគេកំពុងជួបប្រទះបញ្ហាសេដ្ឋកិច្ច បើពុំនោះទេ ទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារ រួមនឹងរដ្ឋាភិបាលត្រូវជួបបញ្ហាធ្ងន់ធ្ងរ៕

# អ្នកជំនាញថា
# ការប្រើភាសាត្រឹមត្រូវអាចបន្ថយការរើសអើង និងអំពើហិង្សាលើពលករចំណាកស្រុក

https://khmer.voanews.com/a/experts-say-using-the-right-language-can-reduce-discrimination-and-violence-against-migrant-workers/7371609.html ២៧ វិច្ឆិកា ២០២៣កាន់ វិច្ឆិកា

ភ្នំពេញ៖ អ្នកជំនាញផ្នែកស្ត្រី និងយេនឌ័រលើកឡើងថា ការប្រើប្រាស់ពាក្យពេចន៍ពាក់ព័ន្ធនឹងពលករចំណាកស្រុកដោយត្រឹមត្រូវ អាចជួយកាត់បន្ថយការរើសអើង និងអំពើហិង្សាលើពួកគេ។ ការលើកឡើងរបស់អ្នកជំនាញពាក់ព័ន្ធនឹងការប្រើពាក្យពេចន៍អំពីពលករចំណាកស្រុកនេះ ធ្វើឡើងក្នុងពិធីសម្ពោធកម្រងសន្ទានុក្រមវាក្យសព្ទ ស្តីអំពីទេសន្តរប្រវេសន៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ផ្តោតលើពលករទេសន្តរប្រវេសន៍ជាស្ត្រី និងបញ្ឈប់អំពើហិង្សាលើស្ត្រី កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣។ សន្ទានុក្រមនេះចងក្រងដោយកម្មវិធីសុវត្ថិភាព និងយុត្តិធម៌នៃអង្គការអន្តរជាតិខាងការងារ (ILO) និងទីភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រី (UN Women)។

លោកស្រី Deepa Bharathi ប្រធានទីប្រឹក្សាបច្ចេកទេសនៃការិយាល័យប្រចាំតំបន់របស់អង្គការអន្តរជាតិខាងការងារ (ILO) សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ថ្លែងក្នុងពិធីសម្ពោធនោះថា ពលករចំណាកស្រុកមានឯកសារមានប្រមាណជា ១១,៦ លាននាក់នៅអាស៊ីអាគ្នេយ៍ និងតំបន់ប៉ាស៊ីហ្វិក។ ក្នុងនោះ ពលករជាស្ត្រីចំនួន៥,២លាននាក់។ លោកស្រី Deepa Bharathi បន្ថែមថា ពលករចំណាកស្រុកតែងប្រឈមមុខនឹងការរើសអើង អំពើហិង្សា និងការយាយីក្នុងប្រទេសដើម និងប្រទេសគោលដៅរបស់ពួកគេ ខណៈដែលពាក្យពេចន៍ ឬភាសាអាចធ្វើឱ្យស្ថានភាពពួកគេប្រសើរឡើង ឬកាន់តែទាញទម្លាក់ពួកគេ។

សន្ទានុក្រមវាក្យសព្ទ ស្តីពីទេសន្តរប្រវេសន៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ មាន៤៦ទំព័រ និងមាន៨២ពាក្យ ត្រូវបានបកប្រែជាភាសាខ្មែរ មកពីច្បាប់ដើមជាភាសា អង់គ្លេស។ សន្ទានុក្រមនេះប្រើជាមគ្គុទេសន៍សម្រាប់អ្នកសារព័ត៌មាន អ្នកស្រាវជ្រាវ អ្នកបណ្តុះបណ្តាល និងអ្នកពាក់ព័ន្ធដទៃទៀត ដែលរៀបចំវគ្គបណ្តុះបណ្តាល ឬសរសេរអត្ថបទអំពីទេសន្តរប្រវេសន៍ការងាររបស់ស្ត្រី និងសម្រាប់អ្នកដែលសរសេរអត្ថបទអំពីអំពើហិង្សាលើស្ត្រី ក្នុងបរិបទទេសន្តរប្រវេសន៍ ឬចំណាកស្រុក។ នេះបើតាមសេចក្តីផ្តើមក្នុងសន្ទានុក្រម។

អ្នកស្រី យុន សុភា អ្នកសម្របសម្រួលកម្មវិធីថ្នាក់ជាតិនៃ UN Women ប្រចាំកម្ពុជាថ្លែងក្នុងកម្មវិធីនោះថា ពាក្យពេចន៍ដែលបុគ្គលម្នាក់ៗប្រើ មានឥទ្ធិពលដល់ផ្នត់គំនិតរបស់បុគ្គល និងសង្គមជាវិជ្ជមាន ឬអវិជ្ជមាន។ អ្នកស្រីថា ទាំងអស់គ្នា ជាពិសេសអ្នកសារព័ត៌មាន និងអ្នកមានឥទ្ធិពលក្នុង

សង្គម គួរតែប្រើពាក្យពេចន៍ ឬភាសាដែលមានឥទ្ធិពលជាវិជ្ជមានសម្រាប់សង្គម ពិសេសក្នុងបរិបទពលករចំណាកស្រុក។ អ្នកស្រីបន្ថែមថា៖ «បងប្អូនពលករចំណាកស្រុកជាស្ត្រីបានចូលរួមចំណែកយ៉ាងធំធេងចំពោះសេដ្ឋកិច្ចរបស់ទាំងប្រទេសគោលដៅ ក៏ដូចជាប្រទេសរបស់ខ្លួន ប្រទេសដើម។ អ៊ីចឹងគឺឃើញថាចាំបាច់ដែលត្រូវមានការទទួលស្គាល់ គឺការចូលរួមចំណែករបស់ពួកគាត់ ជាពិសេសគឺទិដ្ឋភាពអំពើហិង្សាលើស្ត្រី ក៏ដូចជា អំពើហិង្សាលើយេនឌ័រទៅទៀតនោះ គឺរិតតែសំខាន់ទៅទៀតក្នុងការប្រើប្រាស់នូវពាក្យពេចន៍ទាំងឡាយណាដែលមិនកាន់តែធ្វើឱ្យស្ត្រីពលករចំណាកស្រុកហ្នឹង ត្រូវបានរើសអើងបន្ថែមមួយជាន់លើទៀត»។

បើតាមអ្នកស្រី យុន សុភា សន្ទានុក្រមនេះនឹងផ្សព្វផ្សាយពីសារៈសំខាន់នៃពាក្យដែលងាយស្រួលប្រើក្នុងប្រព័ន្ធផ្សព្វផ្សាយ និងឥទ្ធិពលរបស់ពាក្យនីមួយៗទៅលើពលករចំណាកស្រុក។ ក្នុងសន្ទានុក្រមវាក្យសព្ទស្តីពីទេសន្តរប្រវេសន៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ មានការបញ្ជាក់អំពីពាក្យមួយចំនួនដែលគួរប្រើ និងចៀសវាងប្រើ ដូចជា ចៀសវាង ប្រើពាក្យជនចំឡែកឬជនក្រៅគព ដោយគួរប្រើពាក្យថាពលករទេសន្តរប្រវេសន៍ ឬពលករចំណាកស្រុក។ ចៀសវាងការប្រើពាក្យអ្នកជួយការងារផ្ទះ ឬឈ្នួលបម្រើ មកជាពាក្យ អ្នក ឬកម្មករធ្វើការតាមផ្ទះ និងជៀសវាងការប្រើពាក្យជនរងគ្រោះ មកជាពាក្យអ្នកដែលរស់រានពីអំពើហិង្សាជាដើម។ បើតាមរបាយការណ៍របស់ក្រសួងការងារកម្ពុជា គិតត្រឹមឆ្នាំ២០២២ ពលករចំណាកស្រុកមានឯកសារដែលកំពុងធ្វើការនៅក្រៅប្រទេសមានចំនួនជាង១លាន៣សែននាក់ ក្នុងនោះពលករជាស្ត្រីមានប្រមាណជា៤០ភាគរយ។

លោកស្រី ញាណ សុចិត្រា អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គមនៃក្រសួងកិច្ចការនារីលើកឡើងថា ពលករចំណាកស្រុកពីកម្ពុជាទៅធ្វើការនៅក្រៅប្រទេសមានការកើនឡើង ហើយពលករជាស្ត្រីក៏មានការកើនឡើងផងដែរ។ អ្នកស្រីថា ពួកគេបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកំណើត និងប្រទេសគោលដៅ ព្រមទាំងសេដ្ឋកិច្ចក្នុងតំបន់ផងដែរ ប៉ុន្តែអ្នកស្រីថា ពួកគេបែរជាត្រូវបានផ្តល់តម្លៃទាបទៅវិញ។ លោកស្រី ញាណ សុចិត្រា បន្ថែមថា អ្នកសារព័ត៌មានត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមសាធារណជនអំពីសារៈសំខាន់នៃការទប់ស្កាត់ការជួញដូរមនុស្ស និងការការពារពលករចំណាកស្រុក។ លោកស្រីថ្លែងថា៖ «ខ្ញុំសូមលើកទឹកចិត្តដល់បងប្អូនដែលជាអ្នកសារព័ត៌មាន សូមមេត្តាអាននូវក្រមសីលធម៌ហ្នឹង ថាតើ ក្នុងនាមយើងជាអ្នកផ្តល់សារជូនប្រជាជន យើងផ្តល់សារមានន័យថាយើងចង់ផ្តល់ព័ត៌មាន និងចំណេះដឹងជូនប្រជាជន អ៊ីចឹងគួរតែអានសារ ត្រូវតែអានសារហ្នឹង ហើយគោរពការសរសេរសារព័ត៌មានរបស់យើងហ្នឹង»។

ក្នុងរបាយការណ៍របស់អង្គការសហប្រជាជាតិចេញកាលពីខែសីហា ឆ្នាំ២០២១ ការធ្វើចំណាកស្រុកអាចទទួលបានការងារដែលមានប្រាក់ខែខ្ពស់ និងជាប្រភពចំណូលដ៏សំខាន់សម្រាប់ស្ត្រី។ ប៉ុន្តែស្ត្រីជាពលករចំណាកស្រុកក៏ប្រឈមនឹងការរើសអើងជាលក្ខណៈប្រព័ន្ធ ហើយបញ្ហាប្រឈមនិងឧបសគ្គជាច្រើន បានរារាំងពួកគេមិនឱ្យស្វែងរកជំនួយ ទាំងតាមរយៈបណ្តាញផ្លូវការ និងក្រៅផ្លូវការ ថែមទាំងមិនដឹងថា ត្រូវស្វែងរកសេវាកម្មដែលមានការគាំទ្រនៅទីណាជាដើម។ របាយការណ៍បន្ថែមថា ការរើសអើងនេះបង្កជាគ្រោះថ្នាក់ ជាពិសេសនៅពេលប្រែទៅជាអំពើហិង្សាដែលនឹងធ្វើឱ្យ ប៉ះពាល់ដល់ សេដ្ឋកិច្ច សង្គម និងបុគ្គល៕

# ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០២៣

## លោកជំទាវ ឡុងឌី សាន់ណារ៉ា ៖ ការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ជាភាតព្វកិច្ចរបស់យើងទាំងអស់គ្នា

https://btv.com.kh/article/35622 2023/11/29 07:21:55 pm

ភ្នំពេញ ៖ លោកជំទាវ ឡុងឌី សាន់ណារ៉ា រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានបញ្ជាក់ថា ការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា រួមគ្នាធ្វើ បង្កើតស្នាដៃថ្មី ជាទម្រង់សិល្បៈ ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងការបង្ការ ទប់ស្កាត់ និងកិច្ចការពារជនរងគ្រោះពីការជួញដូរមនុស្ស។

ការថ្លែងរបស់លោកជំទាវ ឡុងឌី សាន់ណារ៉ា យ៉ាងដូច្នេះ ក្នុងសិក្ខាសាលា ស្តីពី«តួនាទី នៃវិស័យវប្បធម៌ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» រៀបចំដោយក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, នារសៀលថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣នេះ និងមានការចូលរួមធ្វើបទបង្ហាញពីលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងលោកជំទាវបណ្ឌិត សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។

លោកជំទាវ រដ្ឋលេខាធិការ បានបន្តថា ការរៀបចំសិក្ខាសាលានេះ នឹងធ្វើឱ្យយើង ដែលមានវត្តមាននៅទីនេះ បានយល់ដឹង និងចូលរួមបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដោយការបង្កើតជាស្នាដៃថ្មីៗលើវិស័យសិល្បៈ ដើម្បីជួយផ្សព្វផ្សាយ បណ្តុះគំនិត និងជម្រុញឱ្យមានការចូលរួមលុបបំបាត់ការជួញដូរមនុស្សតាមគ្រប់រូបភាព ក្នុងគោលដៅរួមចំណែក រក្សាសុខសន្តិភាព ស្ថេរភាពសង្គម និងការអភិវឌ្ឍប្រកបដោយចិរភាព។ មានតែការរួមកម្លាំងសហការគ្នា បង្កើតការឯកភាពគ្នា

*និងធ្វើការផ្សព្វផ្សាយតាម គ្រប់មធ្យោបាយប៉ុណ្ណោះ ទើបអាចយកឈ្នះលើបទល្មើសគួរឱ្យស្អប់ខ្ពើមនេះបាន។ អំពើជួញដូរមនុស្សត្រូវបានគេចាត់ទុកជាទាសភាពសម័យទំនើប ដែលមានចរិកស្មុគ្រស្មាញប្រកបដោយល្បិចកល ពាក់ព័ន្ធទៅនឹងរបត់នៃផ្នត់គំនិត ចិត្តសាស្ត្រសង្គម ការរីកចម្រើននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា ការវិវត្តន៍នៃសេដ្ឋកិច្ច នយោបាយជាតិ និងអន្តរជាតិជាដើម ដែលត្រូវការចាំបាច់នូវការប្តេជ្ញាចិត្តរួមគ្នា ដើម្បីរិះរកវិធានការ ដែលមានប្រសិទ្ធភាពក្នុងការបង្ការ ទប់ស្កាត់ ដើម្បីកាត់បន្ថយឈានទៅលុបបំបាត់ឱ្យបាន។*

*លោកជំទាវ រដ្ឋលេខាធិការ បានបន្តថា កន្លងមកព្រះរាជាណាចក្រកម្ពុជា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហានេះ ហើយក្រសួងស្ថាប័នក្នុងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើន ក៏បាននឹងកំពុងតែធ្វើការងារយ៉ាងសកម្មពាក់ព័ន្ធ នឹងការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស។ ឥឡូវនេះ យើងមានផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិ ដែលត្រូវបានក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់រួមគ្នាដាក់បញ្ចូលនូវសម្មភាពដែលពាក់ព័ន្ធ នឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។*

*ជាមួយគ្នានោះដែរ លោកជំទាវ ឡុង សាន់ណាក់ សូមជូនជាគំនិតខ្លះៗដើម្បីអង្គសិក្ខាសាលាយកទៅពិភាក្សា៖ ១-យើងរួមគ្នាគិតនិងពិភាក្សា សំដៅស្វែងរកយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីអប់រំ ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់ស្រទាប់មហាជនលើសកម្មភាពជួញដូរមនុស្ស។ ២-ត្រូវបន្តជម្រុញនិងលើកកម្ពស់កិច្ចសហការជាប្រចាំជាមួយក្រសួង ស្ថាប័នជាតិ អង្គការ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងឡាយ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើយ៉ាងណាទប់ស្កាត់ឱ្យបាននូវអំពើ ឬ សកម្មភាពជួញដូរមនុស្ស និង៣-បន្តអនុវត្តយន្តការ ដែលមានស្រាប់ តាមរយៈការតម្លើងស្នាដៃក្នុងទំរង់សិល្បៈផ្សេងៗ និងបង្កើតការ ផលិតឯកសារជារូបភាព ឬឯកសារជាវីដេអូ តាមបច្ចេកវិទ្យាឌីជីថល ទាន់សម័យ ដើម្បីបង្កើតភាពងាយ ស្រួលដល់អ្នកផ្សព្វផ្សាយផង និងអ្នកទទួលព័ត៌មានផង៕ អត្ថបទ ៖ រដ្ឋា*